ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Oct-2012, 14:04
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី១១២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ដាវ អានសាន

លោក ឌុច ផារី

លោក រ៉ូជើ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆរ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្យាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី បេនី យេ *(Ms. Beini YE)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោក ខៀវ អេន (TCW-320) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ខៀវ អេន** (TCW-320)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ......... ទំព័រ ៣
សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី៖ ......... ទំព័រ ៦
សួរដោយ ឌេល លីសាក់ ផ្ដើមពី៖ ......... ទំព័រ ៤០
សួរដោយលោក ឡោ ជុនធី ផ្ដើមពី៖ ......... ទំព័រ ៤៤
សួរដោយលោកស្រី បេនី យេ ផ្ដើមពី៖ ......... ទំព័រ ៦៣
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖ ......... ទំព័រ ៧៤
សួរដោយ លោក សុន អរុណ ផ្ដើមពី៖ ......... ទំព័រ ៧៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៥៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងថ្ងៃនេះ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនកាលពីចុងសប្ដាហ៍មុនរួចហើយថា អង្គជំនុំជម្រះនៅថ្ងៃនេះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-320។ ហើយមុននឹងកោះអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ សូមក្រឡាបញ្ជីលោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៥:៣៣]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន នៅក្នុងសវនាការយើងថ្ងៃនេះ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ គ្រប់ភាគីទាំងអស់នៃរឿងក្ដីមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព។ ប៉ុន្តែយោងតាមពាក្យលះបង់សិទ្ធិរបស់ខ្លួន ឯកសារ E229 ជនជាប់ចោទបានស្នើលះបង់សិទ្ធិវត្តមាននៅក្នុងដំណើរការសវនាការនៃការស្ដាប់សក្ខីកម្មសាក្សី TCW-320 ដែលអង្គជំនុំជម្រះសាលាដំបូងនឹងគ្រោងស្ដាប់សក្ខីកម្មនៅថ្ងៃនេះ។ សាក្សី TCW-320 មានវត្តមានរួចជាស្រេចរង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬដើមបណ្ដឹង ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយឡើយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខតុលាការដំបងដែក ចំពោះ -- សូមទោស ចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។

[០៩:០៦:៤៣]

សូមជម្រាបលោកប្រធានផងដែរថា មិនមានសាក្សីបម្រុងនាពេលនេះឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំះ**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មចំនួនប្រាំពីររូប និងដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប ក្នុងចំណោមសាក្សីចំនួនប្រាំពីររូបក៏មានឈ្មោះសាក្សីដែលមានរហស្សនាម TCW-320 ម្នាក់ដែរ។

យោងតាមរបាយការណ៍ស្ដីពីការព្យាបាលលោក អៀង សារី របស់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត លេខ៦៦២ មមខស ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ ហើយជារបាយការណ៍ចុងក្រោយបានបញ្ជាក់ថា លោក អៀង សារី បច្ចុប្បន្នកំពុងតែសម្រាកទទួលការព្យាបាលនៅផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ហើយនៅពេលនេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មសាក្សី ដោយមានលក្ខខណ្ឌ ដោយគាត់មានបញ្ហាសុខភាពត្រូវសម្រាកដើម្បីទទួលការព្យាបាលនៅមន្ទីរពេទ្យ តែរូបកាយនិងស្មារតីរបស់គាត់សមស្រប។

[០៩:០៨:០៥]

អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយល់ព្រមតាមសំណើសុំរបស់លោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មដែលមាន -- សាក្សីដែលមានរហស្សនាម TCW-320 ហើយធ្វើការសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្ស TCW-320 ដោយមិនមានវត្តមានលោក អៀង សារី ដែលអនុវត្តតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ដែលបានចែងថានៅពេលដែលមានបញ្ហាសុខភាព ឬក៏មូលហេតុធ្ងន់ធ្ងរដទៃទៀត ជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែរូបកាយ និងបញ្ញាស្មារតីសមស្របអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបាន អង្គជំនុំជម្រះអាចបន្តកិច្ចដំណើរការនីតិវិធីមិនមានវត្តមានជនជាប់ចោទដោយមានការយល់ព្រមពីជនជាប់ចោទ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី TCW-320 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[០៩:០៩:០៩]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១០:២៧]

**ប្រធានអង្គជំនុំ៖**

អរុណសួស្ដីសាក្សី។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកឈ្មោះអី?

**លោក ខៀវ អេន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ខៀវ អេន។

**ស៖** បាទអរគុណ។ ហើយក្រៅពីឈ្មោះ ខៀវ អេន តើលោកធ្លាប់ប្រើប្រាស់ឈ្មោះអ្វីផ្សេងទៀតទេ? ជាពិសេសនៅក្នុងសម័យបដិវត្តន៍ឆ្នាំ -- អំឡុងឆ្នាំ៧០, ៧៩?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយ! បាទៗ ចាំភ្លើងសញ្ញាក្រហម។

**លោក ខៀវ អេន៖**

**ឆ៖** បាទ ឈ្មោះខ្ញុំអត់មានអីប្រែប្រួលទេ គឺថាឈ្មោះនេះគឺជាឈ្មោះកំណើត ហើយពេលដែលចូលបដិវត្តន៍នោះ ក៏ឈ្មោះនៅដដែល។

**ស៖** បាទ អរគុណ។ ហើយតើលោកមានអាយុប៉ុន្មាន?

[០៩:១១:២៤]

**ឆ៖** ខ្ញុំអាយុមកឥឡូវនេះ គឺបើគិតកំណើត វាកើតនៅឆ្នាំ១៩៥៨។

**ស៖** តើលោកអាចប្រាប់ដល់អង្គសវនាការបានដែលទេ អំពីលំនៅដ្ឋានរបស់លោក តើលោកសព្វថ្ងៃរស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំសព្វថ្ងៃរស់នៅប៉ៃលិន ក្នុងភូមិវត្ត ខេត្តប៉ៃលិន ក្រុងប៉ៃលិន។

**ស៖** តើលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** សព្វថ្ងៃខ្ញុំជាមន្ត្រីរាជការ។

**ស៖** ឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ ខៀវ អុន ហើយម្ដាយឈ្មោះ ឃឹម ឃន។

[០៩:១២:២៥]

**ស៖** បាទ អរគុណ។ ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ប្រពន្ធឈ្មោះ ឃួន ចាន់ធី។

**ស៖** ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** មានកូន៥នាក់។

**ស៖** បាទ អរគុណ។ ហើយលោក ខៀវ អេន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិតឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូបនាក់ដែរ -- ទាំងបីនាក់ដែរ គឺលោក នួន ជា, អៀង សារី, លោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ នេះគឺជាការពិតចំពោះខ្លួនខ្ញុំ គឺអត់មានទាក់ទំនងទំនាក់ជាសាច់ឈាមទេ។

**ស៖** ហើយតាមរបាយការណ៍អម្បាញ់មិញដដែលគឺថាលោកបានធ្វើសម្បថរួចហើយនៅមុខអ្នកតាដំបងដែកនៅមុខ នៅខាងកើតសាលសវនាការនេះ។ ហើយមុននឹងលោកអញ្ជើញចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនាពេលនេះ។ តើពិតមែនដែរទេ?

**ឆ៖** បាទ ការនេះជាការពិតដែលខ្ញុំបានធ្វើហើយ។

[០៩:១៣:៥៤]

**ស៖** អង្គជំនុំជម្រះសូមជម្រាបជូនលោកអំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីដែលចូលរួមផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អំពីសិទ្ធិលោក ខៀវ អេន ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ នៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ការធ្វើអំណះអំណាងមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬក៏សេចក្ដីអំណះអំណាងរបស់លោកនោះហើយដែលនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ គឺលោកត្រូវឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែករណីដែលឆ្លើយតបទៅនឹងសំណួរ ឬក៏ធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានជម្រាបជូនអំពីសិទ្ធិខាងលើ។

ហើយក្នុងនាមលោកជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏ការធ្វើសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមអង្គជំនុំជម្រះបានសួរ។ តើលោកយល់ដែរទេ អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ ដែលយើងបានប្រាប់អម្បាញ់មិញនេះ?

**ឆ៖** បាទ ការលោកប្រធានបានបញ្ជាក់ប្រាប់អំមិញខ្ញុំបានយល់នូវបញ្ហានេះហើយ។

**ស៖** បាទ អរគុណ។ ហើយលោក ឌៀវ អេន តើកន្លងមកលោកធ្លាប់បានផ្តល់សក្ខីកម្មជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ? ហើយប្រសិនបើធ្លាប់ ថាតើធ្វើសម្ភាសន៍នោះប្រព្រឹត្តនៅទៅប៉ុន្មានដង? ហើយនៅពេលណា? ហើយនៅទីកន្លែងណា?

**ឆ៖** ខ្ញុំធ្លាប់បានផ្តល់សក្ខីកម្មទៅលើ អ.វ.ត.ក នេះម្តង គឺថានៅប៉ៃលិន។ នៅចម្ការកាហ្វេ ហើយបើគិតកាលបរិច្ឆេទខ្ញុំមិនបានចាំ។ ព្រោះការដែលខ្ញុំនិយាយទៅហ្នឹង ដល់គិតពេលវេលាមកខ្ញុំហាក់ដូចជាភ្លេច ពេលភ្លេចវេលាហ្នឹងអស់។

[០៩:១៦:៣៣]

**ស៖** បាទ អរគុណ។ ហើយមុនពេលចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាន ឬក៏បានស្តាប់ការអានបុគ្គលណាម្នាក់នូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោក ដែលលោកបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេត ដែលលោកអះអាងអំមិញថា នៅចម្ការកាហ្វេ នៅប៉ៃលិន ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ឯកសារដែលខ្ញុំបានផ្តល់ជាសម្ភាសមួយអស់លោកហើយ ខ្ញុំ បើគិតរយៈពេលមកខ្ញុំនៅមានការចងចាំខ្លះ តែមួយចំនួនក៏ហាក់ដូចជា បាត់ការចងចាំមួយចំនួន នូវការសម្ភាសហ្នឹងដែលថាដូចជានិយាយវាមិនដឹងរឿងអីខ្លះ វាចាំមិនបានមកឥឡូវហ្នឹង។ តែគ្រាន់តែថា បើឯកសារហ្នឹងខ្ញុំមើលទៅ

គឺថាបានដឹងមួយចំនួន។ ហើយឯកសារដែលបាននិយាយហ្នឹងគឺថា មានខ្ញុំមានធ្វើការបញ្ជាក់ពីរឿងសម្ដីពាក្យពិតរបស់ខ្ញុំ នៅក្នុងឯកសារនោះហើយអស់។

[០៩:១៧:៤៩]

**ស៖** បើតាមលោកសមត្ថភាពដែលលោកដឹង និងលោកអាចចាំបាន តើកំណត់ហេតុស្ដាប់សក្ខីកម្មដែលលោកបានអាន បានពិនិត្យមើលឡើងវិញហ្នឹង វាស៊ីសង្វាក់គ្នា ឬក៏វាស្របគ្នាទៅនឹងចម្លើយដែលបានផ្ដល់កន្លងមកនៅចម្ការកាហ្វេ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដល់អ្នកស៊ើបអង្កេតដែរឬទេ?

**ឆ៖** ការស្ដាប់ ការឮខ្លះ កន្លែងខ្លះខ្ញុំស្រប តែកន្លែងខ្លះខ្ញុំមិនស្រប ដោយកន្លែងខ្លះដែលមិនស្របដោយសារខ្ញុំមិនបានឃើញ ខ្ញុំមិនបានដឹង។ តែកន្លែងខ្លះដែលខ្ញុំស្រប ខ្ញុំបានដឹង បានឃើញ។ ដល់អ៊ីចឹងខ្ញុំផ្ដល់ក្នុងនាមដែលខ្ញុំដឹង ខ្ញុំឮ ខ្ញុំឃើញ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនដល់តំណាងសហព្រះរាជអាជ្ញាថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីនេះ មុនភាគីដទៃទៀត។ ហើយសូមជម្រាបផងដែរថា តំណាងសហព្រះរាជអាជ្ញា រួមទាំងតំណាងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសួរសាក្សីរូបនេះ មានរយៈពេល១ថ្ងៃ។

អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:១៩:២៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ហើយជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ហើយក៏សូមសួរលោកសាក្សី លោក ខៀវ អេនផងដែរបាទ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក ខៀវ អេន ខ្ញុំនឹងសួរសំណួរមួយចំនួនទាក់ទងទៅនឹងបញ្ហាដែលលោកបានដឹង បានចាំ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សំណួរជាដំបូងរបស់ខ្ញុំគឺចង់ជម្រាបលោកថា នៅក្នុងបទសម្ភាសន៍របស់លោក ដែលបានធ្វើជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតពោលគឺនៅក្នុងឯកសារលេខ E3/438។ នៅត្រង់ ERN ជាភាសាខ្មែរគឺ 00373430, ជាភាសាអង់គ្លេសគឺ 0037575-- សុំទោសម្តង ទៀត ជាភាសាអង់គ្លេស 00375871 ដល់72 ហើយជាភាសាបារាំងគឺ 00426428។ នៅក្នុងចម្លើយ នោះគឺលោកបានជម្រាបអ្នកស៊ើបអង្កេតថា លោកបានចូលរួមក្នុងចលនាបដិវត្តន៍ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៣ ហើយបន្ទាប់មកលោកក៏មានតួនាទីជាឈ្លបឃុំ ដែលជាកម្លាំងត្រៀមបម្រុងនៅក្នុងអំឡុងឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥។ ខ្ញុំចង់ឲ្យលោកជម្រាបជូនអង្គសវនាការថាតើនៅពេលដែលលោកធ្វើជាឈ្លបឃុំ ដែលជាកម្លាំងត្រៀមបម្រុង តើទីតាំងរបស់លោកនៅពេលនោះនៅកន្លែងណាដែរ?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំសូមឆ្លើយនឹងសំណួរលោកដែលបានសួរ ពីរឿងខ្លួនខ្ញុំផ្ទាល់ដែល ជាជំហានដំបូងដែលខ្ញុំបានចូលក្នុងជួរកម្ពុជាប្រជាធិបតេយ្យហ្នឹង កាលហ្នឹងវាមិនទាន់មានឈ្មោះថា "កម្ពុជាប្រជាធិបតេយ្យ"នៅឡើយទេ វាឈ្មោះហ្នឹងវាក្រោយទេ។ តែគ្រាន់តែអង្កាល់ហ្នឹង គេហៅថាធ្វើបដិវត្តន៍ហ្នឹង គឺថា ខ្ញុំចូលហ្នឹងគឺនៅក្នុងឆ្នាំ១៩៧៣។ ហើយដល់៧៣ហ្នឹង គឺភូមិខ្ញុំបានកើតទៅជាការវ៉ៃគ្នា ភ្លើងឆេះ អស់ផ្ទះ អស់សម្បែងហើយ។ ហើយដល់អ៊ីចឹងក៏មានការដែលថាខាងបដិវត្តន៍ហ្នឹងគឺថាគេរៀបចំកម្លាំងដែលជាយុវជននៅមានកម្លាំងហ្នឹង ចូលធ្វើបដិវត្តន៍ ហើយដល់អ៊ីចឹងខ្ញុំក៏ -- ព្រោះអាហ្នឹងដូចខ្ញុំបញ្ជាក់ក្នុងឯកសារហើយថា ខ្ញុំមិនមានចំណង់អីចង់ទេ តែដោយសារសភាពការណ៍ហ្នឹងវាមិនដឹងទៅណាមកណា ផ្ទះក៏ឆេះអស់ទៅ ហើយក៏ត្រូវចូលធ្វើបដិវត្តន៍ហ្នឹង ហើយដល់ចូលខ្លះ អង្កាល់ហ្នឹងគេថាគេចូលក្នុងទ័ព តែដល់យើងនៅមិនព្រមចង់ចូល គេឲ្យយើងធ្វើឈ្លបឃុំ ធ្វើឈ្លបឃុំ ហើយគ្រាន់តែថា យូរទៅគង់តែទៅទ័ពដដែលទេ អាហ្នឹងដំណើរអ៊ីចឹង។ ហើយឈ្លបឃុំហ្នឹងកាលណាខាងស្រុកខាងអីត្រូវការ គេរុញពីឃុំហ្នឹងទៅស្រុកទៀត ដំណើរអ៊ីចឹងទេ។ ហើយដល់អ៊ីចឹង ខ្ញុំមិនមានតួនាទីក្នុងហ្នឹង គ្រាន់តែនៅជាឃុំហ្នឹងយាមភូមិ យាមឃុំដែលខ្លួននៅតែប៉ុណ្ណឹងទេ ហ្នឹងសូមអស់មតិ។

[០៩:២៣:៣៩]

**ស៖** បាទ អរគុណ។ អម្បាញ់មិញលោកបានជម្រាបជូនអង្គសវនាការថា កាលដែលលោកធ្វើជា ឈ្លបឃុំហ្នឹងយូរទៅគង់ក្លាយជាកងទ័ពទេ។ អ៊ីចឹងចង់ដឹងថាលោកបានធ្វើជាកងទ័ពហ្នឹង កងទ័ពរបស់អ្នកណា? ហើយនៅពេលណាដែរ?

**ឆ៖** កាលបរិច្ឆេទដែលខ្ញុំត្រូវចេញពីឈ្លបហ្នឹងមកធ្វើជាទ័ពហ្នឹង ដូចជាអត់យូរទេ តែខ្ញុំគ្រាន់កំណត់ថ្ងៃខែ មិនបាន។ ព្រោះនៅដូចថា ឲ្យតែខាងស្រុកត្រូវការគេឲ្យតាមភូមិឃុំមួយៗហ្នឹងបញ្ជូនកម្លាំងឡើងមក។ អាហ្នឹងដំណើរវាអ៊ីចឹង។ ព្រោះកាលណាវៃទៅបែកបាក់កម្លាំងអីទៅ ខាងលើនេះចង់ខើច គេរុញពីខាងក្រោមមក អ៊ីចេះបញ្ជាឃុំ។ ដល់អ៊ីចឹងកាលបរិច្ឆេទខ្ញុំឲ្យទៅជាពេលវេលាជាទ័ពពេញសិទ្ធិ ពេញអង្គរបស់ថាមានកងមានអីស្រួលបួលហ្នឹងដូចរកពេល រកវេលាអត់ឃើញទេ។ ខ្ញុំចាំមិនបាន។

**ស៖** បាទ អរគុណ។ តើលោកអាចជម្រាបបានទេថា នៅពេលដែលលោកក្លាយជាកងទ័ពហ្នឹងលោកស្ថិតក្នុងអង្គភាពណាដែរ?

**ឆ៖** ខ្ញុំ កាលដែលខ្ញុំចេញពីឃុំមកហើយហ្នឹងមក នៅស្រុក កាលនុ៎ង កន្លែងខ្លះគេហៅ ឈ្លបស្រុកទៀត។ តែខាងខ្ញុំនេះ មិនហៅឈ្លបទេ ហៅទ័ពស្រុកៗ។ ដល់អ៊ីចឹង ខ្ញុំមកនៅក្នុងទ័ពស្រុកហ្នឹងហើយអង្គាល់នុ៎ង វាស្រុក ពីជំនាន់ហ្នឹងមិនទាន់មានស្រុកបំបែកដូចឥឡូវទេ ហៅថា ស្រុកកំពង់លែងហើយពេលវេលាដែលខ្ញុំនៅហ្នឹង គឺខ្ញុំនៅតែស្រុកហ្នឹង រហូតដល់ពេល ១៧មេសា ហ្នឹង។ សូមអស់មតិ។

[០៩:២៥:៤៣]

**ស៖** បាទ អរគុណ។ ចុះលោកមានដឹងទេថា កាលដែលនៅអង្គភាពទ័ពស្រុកកំពង់លែងរបស់លោកហ្នឹង តើពេលនុ៎ង អង្គភាពហ្នឹងស្ថិតនៅក្រោមផ្នែកណាមួយនៃកងទ័ពបដិវត្តន៍អីដែរទេ?

**ឆ៖** នៅពីជំនាន់ហ្នឹង គឺថាក្នុងស្រុកមួយៗ ដែលខ្ញុំដឹងខ្លះ អង្គាល់ដែលយល់ដឹងកាលជំនាន់ហ្នឹងគឺថាទ័ពស្រុកមួយៗ គេមានស្រុក -- អឺ! ក្នុងស្រុកមួយៗគេមានទ័ពរបស់គេ។ បាទ ប្រចាំស្រុកសម្រាប់គេការពារទឹកដីស្រុករបស់គេហ្នឹង។ តែបើខាងខេត្ត ឥឡូវនិយាយថាខេត្តទៅចុះ តែកាលណោះគេហៅតំបន់ បើតំបន់គេត្រូវការ គេទារសាច់ទ័ពហ្នឹង ពីស្រុកហ្នឹង ឡើងមកខេត្តទៀត។ ហើយដល់ស្រុកហ្នឹងខ្វះ ទារពីឃុំមកទៀត។ តែគ្រាន់តែកាលខ្ញុំនោះ គឺថាមានតែមួយអនុសេនា អ៎! មានតែមួយវរសេនាធំទេ -- អ៎ វរសេនាតូច ទ័ពមួយស្រុកហ្នឹង។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ បើពិនិត្យទៅលើនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ដែលមានឯកសារ E3/438 គឺបានបញ្ជាក់ថា ស្រុកកំណើតរបស់លោកគឺនៅភូមិព្រៃគី ឃុំព្រៃគី ស្រុកកំពង់លែង ដែលបច្ចុប្បន្ននេះគេហៅ ស្រុកជលគិរី ហ្នឹង នៃខេត្តកំពង់ឆ្នាំង។ តើលោកអាចជម្រាបជូនអង្គសវនាការ

បានទេ ថាចម្ងាយពីស្រុកកំណើតរបស់លោក ទៅឧដុង្គហ្នឹង មានចម្ងាយប៉ុន្មានដែរ?

[០៩:២៧:៤៣]

**ឆ៖** ខ្ញុំ សំណួរលោកនេះ ខ្ញុំស្តាប់មិនទាន់យល់ពីរឿងថា ចម្ងាយពីភូមិខ្ញុំ ទៅឧដុង្គ មិនដឹងចង់សួររឿងអី។

**ស៖** សំណួរខ្ញុំ គឺអ៊ីចេះ គឺចង់ដឹងចម្ងាយពីស្រុកកំណើតដែលលោកនៅ ចម្ងាយពីហ្នឹងទៅឧដុង្គ តើវាមានចម្ងាយប៉ុន្មានគីឡូម៉ែត្រ ឬក៏ប៉ុន្មានម៉ែត្រ លោកអាចដឹងទេ ពីចម្ងាយនេះ?

**ឆ៖** ចម្ងាយពីភូមិខ្ញុំមកឧដុង្គនេះ ខ្ញុំអត់បានដឹង អត់បាន។

**ស៖** បាទ អរគុណ។ នៅក្នុងបទសម្ភាសន៍របស់លោកជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ គឺឯកសារដដែល គឺ E3/438 ត្រង់ ERN ជាភាសាខ្មែរ គឺ00373431 និងជាភាសាអង់គ្លេស គឺ 00375872 និងជាភាសាបារាំង 00426478។ លោកបានលើកឡើងថា សភាពការណ៍នៅពេលនោះ គឺថា "ភូមិខ្ញុំត្រូវបដិវត្តន៍វាយជាមួយទាហាន លន់ នល់ ដែលបោះទីតាំងនៅភូមិរបស់ខ្ញុំ"។ សំណួរចង់ដឹងថា តើការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម ហើយនិងទាហាន លន់ នល់ ដែលនៅទីនោះ តើលោកចាំទេថា ពេលនោះស្ថិតនៅក្នុងខែណា? ឆ្នាំណាដែរ?

[០៩:២៩:៣៦]

**ឆ៖** ខ្ញុំសូមជម្រាបជូនលោកប្រធាន ពេលវេលាដែលទាហានលន់ នល់ ចូលទៅ អ៎! ដែលត្រូវចាញ់ៗពួកបដិវត្តន៍វ៉ៃនៅភូមិខ្ញុំនោះ គឺថាកាលបរិច្ឆេទ ខ្ញុំមិនបានចាំទេ។ តែគ្រាន់ថា នៅក្នុងឆ្នាំ៧៣ មុនជំនាន់អាមេរិកាំងដកយន្តហោះ ជំនាន់នោះ គឺថាដកសង្គ្រាមអាកាសហើយ គឺថាភូមិខ្ញុំហ្នឹងចប់ដែរ។ ត្រូវៗ -- ទាហាន លន់ នល់ ត្រូវដកចេញពីហ្នឹងដែរ។ ខ្ញុំសូមជូនមតិប៉ុណ្ណឹង។

**ស៖** បាទអរគុណ។ ចុះតើលោកធ្លាប់ត្រូវបានគេបញ្ជូនឲ្យទៅប្រយុទ្ធជាមួយនឹងទាហាន លន់ នល់ ដែរទេ?

**ឆ៖** ខ្ញុំធ្លាប់បានចូលរួមប្រយុទ្ធក្នុងជំនាន់ លន់ នល់ ហ្នឹងគឺថា នៅក្នុងស្រុករបស់ខ្ញុំហ្នឹង ស្រុកកំពង់លែង។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ នៅពេលដែលលោកឡើងទៅប្រយុទ្ធជាមួយទាហាន លន់ នល់ តើលោកកម្លាំងបដិវត្តន៍របស់ខ្មែរក្រហមហ្នឹងធ្លាប់ចាប់បានទាហាន លន់ នល់ ដែរទេ? ហើយបើចាប់បាន តើគេធ្វើយ៉ាងម៉េចខ្លះចំពោះទាហាន លន់ នល់ ទាំងនោះ?

[០៩:៣១:៥២]

**ឆ៖** ក្នុងការប្រយុទ្ធ ខ្ញុំមិនជួបប្រទះទេ អត់ដែលជួបប្រទះ។ ថា១ សង្គ្រាមវ៉ៃគ្នាទៅមក តែដល់ថាចាប់បានអ៊ីចឹងមក ខ្ញុំអត់មានបានជួបទេ។ ហ្នឹងសូមអស់។

**ស៖** បាទ អរគុណ។ ចុះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើលោករស់នៅកន្លែងណាដែរ?

**ឆ៖** ថ្ងៃ១៧ មេសា ១៩៧៥ហ្នឹង កាលណោះថាជាថ្ងៃជ័យជម្នះ ខ្ញុំមែនទែនខ្ញុំនៅនឹងមាត់ទន្លេនៅឡើយ។ ខ្ញុំនៅកំពង់លែងនោះ ស្រុកកំពង់លែង តែខ្ញុំនៅមាត់ទន្លេ ខ្ញុំនៅត្រៀមកាន់កាំភ្លើងនៅត្រៀមប្រយុទ្ធគ្នានៅឡើយទេ។ តែដល់គេខាងគេនៅឯដីគោក ដែលនៅឯដីខ្ពស់ឯណោះគេប្រាប់ថា អ្ហឹស! យើងទទួលជ័យជម្នះហើយ ខ្ញុំនោះក៏គ្មានជំនឿថា ឈ្នះអីៗក៏អត់ជឿដែរ។ គេហៅខ្ញុំឱ្យផ្អាកត្រៀមផ្អាកអីឈប់។ នេះសុំជូនមតិ។

**ស៖** បាទ នៅកន្លែងដែលលោកស្នាក់នៅហ្នឹង នៅកំពង់លែងហ្នឹង តើលោកបានដឹងថា អំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញដែរទេ? ហើយបើដឹង ដឹងនៅពេលណាដែរ?

**ឆ៖** កាលនោះខ្ញុំ រឿងចេញពីភ្នំពេញអី ខ្ញុំដឹង តែមិនឃើញសកម្មភាពជាក់ស្តែងទេ។ ដឹងតែត្រឹមខេត្តខ្ញុំនោះ ព្រោះខ្ញុំអ្នកនៅក្បែរហ្នឹង គេជម្លៀសចេញពីខេត្តមក មកបញ្ជូនទៅខាងស្រុកដែលខ្ញុំនៅហ្នឹង។ សូមអស់មតិ។

[០៩:៣៤:១៩]

**ស៖** បាទ អរគុណ។ ចុះនៅក្នុងស្រុករបស់លោក ដែលលោកនៅហ្នឹង ក្រៅពីជម្លៀសពីខេត្តទីរួមខេត្តទៅស្រុក តើមានអ្នកដែល ប្រជាជនដែលគេជម្លៀសពីទីក្រុងភ្នំពេញទៅរស់នៅកន្លែងលោកដែរទេ?

**ឆ៖** បញ្ហានេះ ខ្ញុំមិនបានជួបប្រទះទេ។ តែគ្រាន់ថា ខ្ញុំជួបតែអ្នកនៅនឹងខេត្តខ្ញុំ ហើយរឿងគេនៅឯណា អីឯណាហ្នឹង ដូចជាអត់បានជួបប្រទះទេបាទ។

**ស៖** បាទ អរគុណ។ លោកអាចជម្រាបបានទេថា ការដែលលោកដឹង ឬក៏ឃើញការជម្លៀសប្រជាជនចេញពីទីរួមខេត្តរបស់លោកហ្នឹង តើការជម្លៀសនុ៎ងយ៉ាងម៉េចខ្លះ លោកអាចជម្រាបជូនអង្គសវនាការអំពីសកម្មភាពនុ៎ងបានទេ?

**ឆ៖** បញ្ហាជម្លៀស ខ្ញុំ ខ្លួនខ្ញុំក៏មិនបានទៅជម្លៀស តែគេជម្លៀសមកខ្ញុំបានឃើញ បានដឹង។ តែគ្រាន់ថា អ្នកទៅពីភ្នំពេញអីនេះ ខ្ញុំអត់ដឹងទេ តែបើនៅក្នុងខេត្តខ្ញុំ គេជម្លៀសទៅ ទៅដល់កន្លែងខ្ញុំមិនមែន

អ្នកជម្លៀសគេចេញពីខេត្តទេ តែខ្ញុំអ្នកនៅនឹងស្រុកហ្នឹង ទៅទទួលកម្លាំងពីស្រុកហ្នឹង នៅនឹងស្រុកហ្នឹង ទទួលអ្នកជម្លៀសហ្នឹង។ ជួយគ្រប់គ្រង ជួយមើល។

[០៩:៣៦:១៨]

**ស៖** បាទ អរគុណ។ ចុះអ្នកណាដែលបញ្ជាលោកឲ្យទៅទទួលកម្លាំងដែលជាប្រជាជនជម្លៀសចូលទៅក្នុងស្រុកលោកហ្នឹង លោកនៅចាំទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់ប្រតិបត្តិការផង ក្បាលមីក្រូមិនទាន់ប្រតិបត្តិការនិយាយទៅអត់ប្រយោជន៍ទេ។ អត់បានចូលទៅប្រព័ន្ធបកប្រែភាសាទេ។

**លោក ខៀវ អេន៖**

**ឆ៖** បាទ ខ្ញុំសូមមានមតិ។ សូមគោរពលោកប្រធាន។ ខ្ញុំនឹកសាឡើងវិញទៅ គឺថាអង្កាល់ហ្នឹង គឺថាមានតែមេកងរបស់ខ្ញុំហ្នឹងទេ គេអ្នករៀបចំខ្ញុំ។ បើក្រៅពីហ្នឹងទៀត ខ្ញុំអត់ដឹងរឿងទេ គេបញ្ជាអីពីលើទៀត ខ្ញុំអត់ដឹងទេ អាហ្នឹងខ្ញុំនៅក្រោមជាបុគ្គលដែលមហាជនសុទ្ធសាធអត់មានតួនាទីអីបាទ។ គេឲ្យធ្វើអីយើងធ្វើតាមគេ ខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:៣៧:៣២]

**លោក សេង ប៊ុនឃាង៖**

**ស៖** បាទ អរគុណ។ តើលោកនៅចាំទេថា មេកង មេក្រុងរបស់លោកដែលបញ្ជាឲ្យលោកទៅត្រួតពិនិត្យ និងរៀបចំកម្លាំងប្រជាជនដែលគេជម្លៀសពីទីរួមខេត្តរបស់លោកហ្នឹង គាត់បញ្ជាឲ្យធ្វើយ៉ាងម៉េចខ្លះលោកនៅចាំបានទេ?

**ឆ៖** ខ្ញុំនៅចាំបានមួយចំនួន គឺថាក្នុងពេលហ្នឹងគឺថាគ្រាន់តែបញ្ជូនកម្លាំងហ្នឹងទៅបញ្ចូលតាមឃុំដើម្បីឲ្យឃុំមួយៗជួយទទួលកម្លាំងហ្នឹង។ នេះខ្ញុំដឹងបានតែប៉ុណ្ណឹង ដល់ក្រោយមកមានចំណែកខ្លះគឺថារៀបចំធ្វើលើកទំនប់លើកអីប៉ុណ្ណឹង។ លើកទំនប់ប្រឡាយទឹក។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ តើលោកមានដឹងទៀតទេថា ប្រជាជនដែលលោកបាននាំទៅឃុំហ្នឹងគឺគេបានបញ្ចូលគាត់ទៅក្នុងសហករណ៍ នៅជនបទអីដែរទេ?

**ឆ៖** ប្រជាជនដែលជម្លៀសចេញទៅនេះ គឺថាគេយកទៅដាក់ក្នុងឃុំ ហើយក្នុងឃុំហ្នឹងមាន

សហករណ៍បាទ។ បាទ សូមអស់មតិ។

[០៩:៣៩:៤៥]

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងប្រជាជនដែលៗគេជម្លៀសចូលទៅក្នុងកន្លែងដែលលោករស់នៅហ្នឹង តើលោកមានដឹងទៀតទេថា ប្រជាជនទាំងនោះត្រូវបានគេតម្រូវឲ្យពួកគាត់ធ្វើជាប្រវត្តិរូបអីដែរទេ?

**ឆ៖** ការងារនេះ ខ្ញុំអត់បានដឹងទេ។ ព្រោះទៅប្រគល់ឲ្យខាងឃុំអី អាហ្នឹងឃុំគេរៀបចំយ៉ាងម៉េច ខ្ញុំអត់មានចូលដឹងរឿងការងាររបស់គេ ខ្ញុំអត់ដឹង។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចូលមកប្រធានបទមួយទៀត ដែលទាក់ទងទៅនឹងប្រវត្តិរូបរបស់លោកនៅក្រោយឆ្នាំដប់ -- នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដដែលហ្នឹង គឺឯកសារ E3/438។ នៅត្រង់ ERN ជាភាសាខ្មែរ គឺ 00373431, និងជាភាសាអង់គ្លេស 00375872, និងជាភាសាបារាំងគឺ 00426429។ លោកបានជម្រាបអ្នកស៊ើបអង្កេតថា លោកបានទទួលបណ្តុះបណ្តាលផ្នែកតេឡេក្រាម នៅក្រសួងឃោសនាការ និងព័ត៌មាននៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦។ តើលោកអាចបញ្ជាក់បានទេថា នៅពេលណាដែលលោកផ្លាស់មកធ្វើការនៅទីក្រុងភ្នំពេញវិញនេះ?

[០៩:៤២:០១]

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន ខ្ញុំដែលត្រូវចេញពីខេត្តហ្នឹងមក មកនៅភ្នំពេញហ្នឹងគឺ ខ្ញុំមិនមានកាលបរិច្ឆេទអី តែខ្ញុំគ្រាន់តែចាំពេលវេលាដែលខ្ញុំមកហ្នឹងគឺ ខ្ញុំនៅនឹងមុខរាំង ហើយពេលហ្នឹងខ្ញុំស្រមៃដែលៗទឹកទៅក្រោយវិញហ្នឹងគឺថា ខែរំហើយ។ ដល់អ៊ីចឹងអាចៗខែដែលត្រីចុះហ្នឹង ខ្ញុំទៅគេយកទៅទុកនៅនុ៎ង យកពីខេត្តយើងទៅហ្នឹង។ ដល់អ៊ីចឹង ខ្ញុំចូលទៅហ្នឹង ទៅនៅហ្នឹងប្រហែលជិតកន្លះខែបានខ្ញុំចូលទៅអាកន្លែងដែលបញ្ជាក់ជូនក្នុងឯកសារហ្នឹង។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ តើលោកនៅចាំទេថា កាលដែលលោកទៅនៅមុខរាំងប្រហែលជាកន្លះខែហ្នឹង គេឲ្យលោកធ្វើអ្វីខ្លះនៅពេលនុ៎ង?

**ឆ៖** ខ្ញុំចាប់បានកាលដែលខ្ញុំទៅនៅនុ៎ង គេអត់មានឲ្យធ្វើអីទេ មែនទែនខ្ញុំដេករង់ចាំមើលថាតើគេយកខ្ញុំទៅណា។ វាអត់ទាន់ដឹងថាទិសថាទៅណា។ អ៊ីចឹង ខ្ញុំសូមមានមតិប៉ុណ្ណឹង។

[០៩:៤៣:២៩]

**ស៖** បាទ អរគុណ។ ចុះនៅកន្លែងដែលលោករង់ចាំហ្នឹង តើមាននរណាដែលជាអ្នកគ្រប់គ្រងនៅកន្លែងនោះដែរទេ? លោកនៅចាំ ស្គាល់ឈ្មោះទេ?

**ឆ៖** កន្លែងនេះ ខ្ញុំដូចជាការចាំហ្នឹងដូចបាត់បង់អស់ហើយ។ មិនដឹងឈ្មោះអី មិនដឹងឈ្មោះកន្លែងហ្នឹង កន្លែងអីផង ព្រោះកាលនុ៎ងដូចថាវាទើបទៅស្គាល់ភ្នំពេញអ៊ីចឹង វាចេញពីនេះទៅ គេយកទៅដាក់ហ្នឹង។ វាអត់ដឹងថាស្អីយ៉ាងម៉េចអីយ៉ាងម៉េច អត់ដឹងទាំងអស់។

**ស៖** ចុះលោកបានដឹងអំពីអ្នកដែលគ្រប់គ្រងនៅទីនោះទេ បើលោកមិនស្គាល់ឈ្មោះកន្លែងហ្នឹង?

**ឆ៖** ខ្ញុំសូម្បីអ្នកនៅនុ៎ងក៏ខ្ញុំអត់ស្គាល់ដែរ ព្រោះខ្ញុំដូចថាជាមនុស្សថ្មីដែលចូលទៅ។ ខ្ញុំអស់មតិ។

**ស៖** បាទ អរគុណ។ ចុះទាក់ទងទៅនឹងការដែលផ្លាស់កន្លែងលោកមកភ្នំពេញហ្នឹង ហើយឲ្យទៅធ្វើការនៅក្រសួងឃោសនាការវិញ។ តើលោកដឹងទេ អ្នកណាដែលឲ្យលោកទៅធ្វើការនៅក្រសួងឃោសនាការ និងព័ត៌មាននុ៎ង?

[០៩:៤៥:០៥]

**ឆ៖** អ្នកដែលបញ្ជូនខ្ញុំទៅ ក៏ខ្ញុំអត់ដឹង។ គ្រាន់តែការហ្នឹង គេឌុបខ្ញុំឲ្យជិះម៉ូតូទៅតែឯងហ្នឹង គេថាឲ្យជូនទៅកន្លែង បងភាស់។ ដឹងតែប៉ុណ្ណឹង សូមចប់។

**ស៖** បាទ អរគុណ។ តើលោកអាចបញ្ជាក់បានទេថា បងភាស់ ហ្នឹងគាត់មានឈ្មោះអ្វីពេញដែរ?

**ឆ៖** កាលណោះ បងភាស់ ហ្នឹង ខ្ញុំមិនដឹងមួយណាទេ។ គេថាទៅឮៗអ្នកដែលគេជូនខ្ញុំហ្នឹង ខ្ញុំសួរថា យកខ្ញុំទៅណា? អ្ហ៎ ទៅកន្លែង បងភាស់។ ហើយខ្ញុំ ភាស់ ហ្នឹងក៏ខ្ញុំអត់ដឹងមួយណាដែរ។ ខ្ញុំជិះម៉ូតូហ្នឹង។ ទៅដល់កន្លែងហ្នឹង ក៏គេឲ្យថា ចុះហ្នឹងហើយ អីហើយ ក៏ខ្ញុំនៅតាមគេឲ្យខ្ញុំនៅហ្នឹងទៅ។ ហ្នឹងសូមអស់មតិ។

[០៩:៤៦:២០]

**ស៖** ហើយ តើលោកដឹងទេថា បងភាស់ ហ្នឹងគាត់មានតួនាទីអ្វីដែរ?

**ឆ៖** ឈ្មោះ បងភាស់ៗ នេះ កាលដែលខ្ញុំទៅដំបូង ចូលនៅប្រហែលកន្លះខែហើយ ខ្ញុំមិនដឹងមួយណាផង។ ខ្ញុំ ទាល់តែក្រោយមកទៀត ដែលខ្ញុំនៅហ្នឹងយូរហើយ បានខ្ញុំចេះតែ ដូចថាស្វែងយល់ និងសួរនាំទៅបានដឹង។ សូមជូនមតិប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ បន្ទាប់ពីលោកបានដឹង បានស្វែងយល់ហើយថា បានដឹងបានស្វែងយល់ហើយ។ អ៊ីចឹងថាតើលោកដឹងថា បងភាស់ ហ្នឹងឈ្មោះអីពេញ ហើយគាត់មានតួនាទីអ្វីដែរ នៅពេលដែលលោកបានដឹង?

**ឆ៖** នៅពេលដែលខ្ញុំបានដឹងថា ភាស់ ហ្នឹងដោយសារខ្ញុំចេះតែសួរគេ ភាស់ ហ្នឹងមួយណា? ដល់យូរៗថា ភាស់ ហ្នឹងមានអ្នកណា, ភាស់ ហ្នឹងបង ហ៊ូ នឹម នេះ។ បានខ្ញុំចាប់អារម្មណ៍ថា អូ! ភាស់ ហ្នឹង ហ៊ូ នឹម ទេ។ នេះខ្លួនខ្ញុំ វាគិតខ្លួនឯង។ ដល់អ៊ីចឹងបានខ្ញុំ គិតថា អូ! ខ្ញុំមកនៅកន្លែងរបស់ ហ៊ូ នឹម។ បាទ នេះខ្ញុំមានមតិប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ ចុះតួនាទីរបស់លោក ហ៊ូ នឹម ហ្នឹងគាត់ធ្វើអ្វីដែលនៅពេលនុ៎ង?

**ឆ៖** កាលនុ៎ង គ្រាន់តែខ្ញុំដឹងជាការឮដែលគេកំណត់ហ្នឹង ជាក្រសួងឃោសនាការ និងព័ត៌មានជារដ្ឋមន្ត្រី។ សូមអស់មតិ។

[០៩:៤៨:៣៩]

**ស៖** បាទ អរគុណ។ ត្រឡប់មកក្រោយបន្តិច នៅពេលដែលលោកចាកចេញពីស្រុកកំណើតរបស់លោក តើនៅពេលនុ៎ង លោកនៅចាំទេថា នរណាជាអ្នកចាត់តាំងឲ្យលោកចេញពីស្រុកកំណើតរបស់លោកមកនៅទីក្រុងភ្នំពេញហ្នឹង?

**ឆ៖** បញ្ហាដែលខ្ញុំចាកចេញពីៗស្រុករបស់ខ្ញុំមកនៅភ្នំពេញហ្នឹង ខ្ញុំអត់ដឹងអ្នកណាចាត់តាំងទេ ហើយមិនដឹងជាបទបញ្ជាមកពីណា អីពីណា ឲ្យខ្ញុំទៅទេ តែគ្រាន់តែថា ពីមុនគេធ្លាប់រុញទៅ តែដល់ខ្ញុំហ្នឹងគេឲ្យទៅហ្នឹង គេៗដូចថា ខុសពីខ្ញុំហ្នឹង គេអត់មានប្តូរអីទេ អ្នកផ្សេងទៀត គេអត់ឲ្យទៅ គេឲ្យតែខ្ញុំទៅ។ ហើយអ៊ីចឹងមិនដឹងជាអ្នកណា អីអ្នកណា ខ្ញុំអត់ដឹង។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ ចុះលោកបានជម្រាបជូនអង្គសវនាការថា ខុសពីលោក គេមិនឲ្យទៅទេ គឺគេឲ្យទៅ។ តើគេនុ៎ងជាអ្នកណាដែរ ដែលគេឲ្យលោកទៅហ្នឹង?

[០៩:៥០:០៨]

**ឆ៖** អ្នកដែលឲ្យខ្ញុំទៅនោះ ក៏ខ្ញុំមិនដឹង តែគ្រាន់តែថាកន្លងមកដែលមានគេឡើងទៅខ្លះ ខាងមេខ្ញុំដែលនៅគ្រប់គ្រងខ្ញុំផ្ទាល់ គេឲ្យទៅ។ តែដល់ពេលខ្ញុំទៅនេះ គឺថាទោះជាមេនឹងឃាត់ ក៏គេអត់នេះដែរ គេនៅតែ ព្រោះកន្លងមកមេៗដែលទទួលខុសត្រូវខ្ញុំហ្នឹង គឺថាភូមិស្រុកអីនៅជាមួយគ្នា។ ហើយដល់ពេលចប់សង្គ្រាម លន់ នល់ ហ្នឹងហើយបែកគ្នាវិញ ក៏មិនចង់ឲ្យបែក ចង់នៅជាមួយគ្នា។ ដល់អ៊ីចឹង

ពេលមុនៗ គេរុញទៅ គេរុញអ្នកផ្សេងៗទៅ។ តែដល់លើកនេះ គេថាគេកំណត់ថាឲ្យខ្ញុំ ហើយអ្នកក៏ណាក៏មិនបាច់ទៅ ឲ្យខ្ញុំទៅ។ អ៊ីចឹងខ្ញុំថា វាដូចជាអ្នកមុនក៏ចេះតែរុញអ្នកផ្សេងទៅ ហើយដល់ពេលនេះម៉េចក៏អត់ឲ្យអ្នកផ្សេងទៀត ហើយតែខ្ញុំទៅ។ នេះខ្ញុំឆ្លើយសំណួរនេះក្នុងន័យអ៊ីចឹង។

**ស៖** បាទ អ៊ីចេះ ខ្ញុំចង់ដឹងថាគេដែលៗលោកបានបញ្ជាក់ថាឲ្យលោកទៅហ្នឹង តើដឹងទេថា "គេ" ហ្នឹងឈ្មោះអី ហើយមានតួនាទីអ្វីដែរ?

[០៩:៥១:៤១]

**ឆ៖** អ្នកដែលបញ្ជាពីលើទៀត ខ្ញុំមិនដឹងទេ។ តែគ្រាន់តែអ្នកដែលឲ្យខ្ញុំទៅផ្ទាល់នេះ គឺថ្នាក់កាលជំនាន់ហ្នឹងគេហៅអនុសេនាធំ បាទ។ អនុសេនាធំ ជាមេរបស់ខ្ញុំ។ គាត់ទទួលខុសត្រូវមនុស្ស១០០នាក់បាទ។ បាទ ឲ្យខ្ញុំសូមជូនមតិប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ តើមេរបស់លោកដែលនៅអនុសេនាធំហ្នឹងគាត់ឈ្មោះអ្វី?

**ឆ៖** មេដែលទទួលខុសត្រូវខ្ញុំពេលហ្នឹងឈ្មោះ ព្រឹង។ ហ្នឹងស្រុកកំណើតអីនៅជាមួយគ្នាទេ តែអ្នកនេះឯង មកឥឡូវគឺស្លាប់បាត់ហើយ។

**ស៖** បាទ អរគុណ។ ចុះលោកអាចបញ្ជាក់បានទេថា ឈ្មោះអនុសេនាធំដែលលោកធ្វើការនៅជាមួយមេរបស់លោកហ្នឹងឈ្មោះអ្វីដែរ ឈ្មោះនុំង?

**ឆ៖** ឈ្មោះអំមិញខ្ញុំដូចជាបានបញ្ជាក់ហើយ ខ្ញុំសូមប្រាប់ថា ឈ្មោះ ព្រឹង អំមិញ គាត់ៗឈ្មោះ ព្រឹង តែត្រកូលអីខ្ញុំមិនដឹងទេ តែគ្រាន់តែធ្លាប់ហៅគ្នាទៅវិញទៅមកហ្នឹង គឺថា ព្រឹង ឈ្មោះ ព្រឹង។

[០៩:៥៣:៣៥]

**ស៖** អ៊ីចេះខ្ញុំចង់ដឹងឈ្មោះអំពីអនុសេនាធំហ្នឹង តើមានឈ្មោះអ្វីដែរ?

**ឆ៖** កាលនុំង ក្នុងស្រុកនុំងវាមានបីកងអនុសេនាធំ។ តែគ្រាន់តែកងដែលមេខ្ញុំឈ្មោះ ព្រឹង គឺជាកង ហៅ កង៣៣។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចូលមកមួយទៀត គឺបើយោងតាមកំណត់ហេតុស្តាប់ចម្លើយរបស់លោកនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលនៅក្នុងឯកសារ E3/438 ត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00373431 និងជាភាសាអង់គ្លេសគឺ 00375872 និងជាភាសាបារាំងគឺ 00426429។ លោកបានជម្រាបជូនអ្នកស៊ើបអង្កេតថា លោកបានធ្វើនៅមន្ទីរ ក-៣ នៃក្រសួងឃោសនាការ និងព័ត៌មាន។ តើលោកអាចជម្រាបបានទេថា មន្ទីរក-៣ ហ្នឹង មានទីតាំងនៅ

កន្លែងណាដែរ?

**ឆ៖** សំណួរនេះ សួរនេះមិនចំចំណុចនេះទេ ព្រោះខ្ញុំនៅៗមន្ទីរ ក-៣៣ តែកងមុនអំមិញនេះក៏កង៣៣ ដែរ ចម្លើយមុនអំមិញហ្នឹង។ ចម្លើយដែលខ្ញុំនៅស្រុកទេណា។ តែដល់ទៅកន្លែងសួរអំមិញ សួរចុងក្រោយ ក-៣៣ ដែរ។

**សៈ** បាទ អរគុណហើយលោក គឺត្រឹមត្រូវហើយ គឺនៅមន្ទីរ ក-៣៣ បាទសូមកែតម្រូវ។ តើមន្ទីរក-៣៣ ហ្នឹង មានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** មន្ទីរក-៣៣ ពេលហ្នឹងគឺនៅខាងត្បូង --ដែលយើងឥឡូវនេះហៅ លីសេដេកាត នៅខាងត្បូងជាប់របង។ និយាយចំសួនច្បារកន្លែងសច្ចមុនីចេតិយ ទៅមុខ ទៅទន្លេ បានន័យថានៅខាងជើងហ្នឹង ខាងជើងសួនហ្នឹង ពីផ្លូវមុនីវង្សទៅហ្នឹង។

[០៩:៥៦:៣៦]

**សៈ** បាទ អរគុណ។ តើលោកមានដឹងទេថា មានអ្នកធ្វើការនៅមន្ទីរក-៣៣ ហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** ចំនួននេះ ខ្ញុំមិនបានចាំទេ ដឹងតែចំនួន អំ! ដឹងតែផ្នែកការងាររបស់ខ្ញុំ។ សូមអស់មតិ។

**សៈ** ចុះទាក់ទងទៅនឹងអ្នកគ្រប់គ្រងនៅមន្ទីរក-៣៣ ហ្នឹង តើលោកនៅចាំទេ ថាអ្នកណាគេជាអ្នកគ្រប់គ្រងនៅមន្ទីរ ក-៣៣ ហ្នឹង?

**ឆ៖** អ្នកដែលគ្រប់គ្រងនៅក្នុងមន្ទីរក-៣៣ហ្នឹង ដែលខ្ញុំចូលនៅដំបូងហ្នឹង ខ្ញុំដឹងថា ឈ្មោះសំ។

**សៈ** បាទ អរគុណ។ នៅក្នុងចម្លើយរបស់លោក នៅក្នុងបទសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងឯកសារ E3/438 ផងដែរ គឺនៅត្រង់ ERN ជាភាសាខ្មែរ 00373431 និងជាភាសាអង់គ្លេសគឺ 00375872 និងជាភាសាបារាំងគឺ 00426429។ គឺលោកបានជម្រាបជូនអ្នកស៊ើបអង្កេតថា ក្រោយពេលបណ្តុះបណ្តាល គេបានចាត់តាំងលោកឲ្យធ្វើការនៅផ្នែកចាប់ព័ត៌មានខាងក្រៅប្រទេស។ តើលោកអ្នកជម្រាបជូនអង្គសវនាការបានទេថា កន្លែងដែលលោកធ្វើការទាក់ទងនឹងការចាប់ព័ត៌មានក្រៅប្រទេសហ្នឹង មានអ្នកធ្វើការប៉ុន្មាននាក់ដែរ?

[០៩:៥៩:០៨]

**ឆ៖** និយាយទាក់ទងនឹងការងារខ្ញុំផ្ទាល់។ ខ្ញុំចង់បញ្ជាក់ថា ការងារហ្នឹងវាមានចែកជាពីរ ជាបីផ្នែកឯណោះ បាទ ប៉ុន្តែផ្នែកការងារដែលខាងខ្ញុំ វគ្គបណ្តុះបណ្តាលហ្នឹង តែគ្រាន់តែគេបំបែក អាមួយ

រៀនខាងអីៗ ដល់ខ្ញុំហ្នឹង ខ្ញុំរៀនខាងជួសជុលអង្គុលីលេខទេ តែគ្រាន់តែថា ជួសជុលផង ចាប់ព័ត៌មានហ្នឹងផងអីចេះ។ តែដល់ចំនួន គឺថា ផ្នែកគេខ្ញុំអត់និយាយទេ ខ្ញុំនិយាយតែរឿងផ្នែកខ្ញុំ គឺថា ដែលត្រូវចាប់អាអ្នកបញ្ចេញ ខ្ញុំអត់និយាយទេ ដែលត្រូវចាប់ព័ត៌មានហ្នឹង និងជួសជុលហ្នឹង។ ដែលខ្ញុំចាំអង្គាល់ខ្ញុំហ្នឹងដូចដំបូងតែបីនាក់ទេ។ បីនាក់ហើយ បួននាក់នឹងប្រធាន និងមេខ្ញុំហ្នឹង។ មេទទួលផ្នែកខ្ញុំ។ នេះខ្ញុំសូមជូនយោបល់ប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ ចុះមេទទួលផ្នែករបស់លោកហ្នឹង ឈ្មោះអីដែរ?

**ឆ៖** មេទទួលខាង ទទួលខ្ញុំអាផ្នែកដែលខ្ញុំចាប់ព័ត៌មានហ្នឹង ឈ្មោះ អុល។ តែឈ្មោះដើមគេយ៉ាងម៉េចនោះ គ្រាន់តែពេលនោះ ស្គាល់ថាឈ្មោះ អុល នៅចាំបាន។

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងតួនាទីរបស់លោក និងការទទួលខុសត្រូវរបស់លោកនៅក្នុងការងារចាប់ព័ត៌មានក្រៅប្រទេស។ សូមលោកជម្រាបជូនអង្គសវនាការ ថាលោកមានតួនាទីធ្វើខ្លះ នៅពេលនុ៎ង?

[១០:០១:២២]

**ឆ៖** ខ្ញុំសូមជូននូវសភាពខ្លះដែលខ្ញុំរស់នៅពេលហ្នឹង។ កាលហ្នឹងខ្ញុំ បើគិតថាថ្នាក់មានតួនាទីដឹកនាំអីនៅក្នុងកន្លែងហ្នឹង ខ្ញុំមិននេះទេ ខ្ញុំជាបុគ្គលិកសុទ្ធសាធម្នាក់ដែលចូលទៅធ្វើការនៅកន្លែងហ្នឹងដោយមាន អុល ហ្នឹង គឺថាជាមេនៅពីលើខ្ញុំ។ ដល់អីចឹង ខ្ញុំធ្វើនៅក្នុងស្នារតីមួយថា ជាប្រព័ន្ធម៉ាស៊ីនចាប់ព័ត៌មានហ្នឹង គ្នាបីបួននាក់ហ្នឹង គ្រាន់តែផ្លាស់ប្ដូរម៉ោងគ្នា ដែលៗចំនួនមនុស្សដែលខ្ញុំដាក់អំមិញហ្នឹង ថាប៉ុន្មាននាក់ហ្នឹង គឺថាផ្លាស់ប្ដូរម៉ោងគ្នាទៅ។ ហើយដំបូងមុននឹងធ្វើការងារហ្នឹង អ៎! មុននឹងចូលការងារហ្នឹង ដំបូងគឺថារៀនចាប់អានុ៎ង តែដល់ក្រោយមក មានដែលខ្ញុំសូមបញ្ជាក់ថា ប្រវត្តិខ្ញុំ គឺថាក្រោយមក បានទៅរៀនវគ្គបណ្ដុះបណ្ដាល។ អាដំបូងទៅ គេឲ្យចាប់ទទេទេ អារឿងយល់ដឹងអី យើងអត់ដឹងទេបាទ។ ហើយដល់ក្រោយមក បានទៅរៀនខាងបច្ចេកទេសសម្រាប់ជួសជុលវាហ្នឹង មានវគ្គបណ្ដុះបណ្ដាល។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹង។

[១០:០២:៤២]

**ស៖** បាទ អរគុណ។ ចុះទាក់ទងទៅនឹងការងារចាប់ព័ត៌មានរបស់លោកនោះ តើមានការកំណត់អំពីប្រភេទព័ត៌មានអ្វីខ្លះដែលត្រូវចាប់យកដែរទេ?

**ឆ៖** ខ្ញុំនៅចាំបានមួយចំនួន កាលហ្នឹងខ្ញុំគ្រាន់តែដឹងថា ជាខ្ទឹមសារ ខ្ញុំមើលមិនយល់ទេ គ្រាន់តែ

ដឹងថា ខ្លះជាព័ត៌មានទាក់ទងនឹងផ្នែកសេដ្ឋកិច្ច ដោយនិយាយពីរឿងសណ្ដែក ស្រូវ អង្ករអី នៅហុងកុង អីហ្នឹង ព្រោះពេលវើអង្គាល់ហ្នឹងមាន តែខ្ញុំមើលមិនដឹងខ្លឹមសារទេ តែគ្រាន់តែដឹងអ៊ីចឹង។ ហើយខ្ញុំជូនដើម្បីលោកប្រធានយល់ ថាអង្គាល់ហ្នឹងគឺថាចាប់ព័ត៌មាន អា.អេស.ប៉េ។ ក្នុងនេះ ខ្ញុំមិនទាន់បានផ្ដល់ចម្លើយទេ តែខ្ញុំគ្រាន់តែជម្រាបជូន អា.អេស.ប៉េ, រ៉យទ័រ, អ៊ុយ.ប៉េ.អ៊ី ហើយនិង ស៊ិនហួរ បាទ នុ៎ងប៉ុន្មានទេ។

[១០:០៤:១២]

**ស៖** បាទ អរគុណ។ សូមលោកជួយជម្រាបជូនអង្គសវនាការផងដែរ ថាតើការងារដែលចាប់ព័ត៌មានរបស់លោកហ្នឹង គឺគេបានយកឧបករណ៍អ្វីខ្លះៗសម្រាប់យកមកប្រើហ្នឹង មានឧបករណ៍អ្វីខ្លះ?

**ឆ៖** ឧបករណ៍ដែលយកមកចាប់នេះ កន្លងមកខ្ញុំទៅ ការពិតឧបករណ៍នេះវាមានហើយ ពេលដែលខ្ញុំចូលទៅនៅ។ គេមាន គេដំណើរការហើយ ហើយដល់សួរនាំគេទៅ គេថា គេយកមកទីតាមទូត បាទតាមទូត។ បាទ អ៊ីចឹងរបស់ហ្នឹងវាទៅជារបស់ចម្រុះៗ មិនមានថារបស់សុទ្ធថា មកពីទីនេះ ទីនោះទេ គឺថាមានរបស់អាដែល ទូតនេះមានរបស់នេះ ទូតនោះមានរបស់នោះ។ ដល់អ៊ីចឹងយកប្រមូលមកមកប្រើនៅៗកន្លែងនុ៎ង។ ដល់អ៊ីចឹងមាន តាំងពីម៉ាស៊ីនវាស់ ម៉ាកស៊ីមែន របស់អាល្លឺម៉ង់ អាខាងលិចខាងកើតហ្នឹង។ ម៉ាស៊ីនរបស់អង់គ្លេស អាអង្គុលីលេខគេនុ៎ង។ ម៉ាស៊ីន ឧបករណ៍នោះវាចម្រុះអ៊ីចឹង។ ហើយម៉ាស៊ីនហ្នឹងវាវាយខ្លួន យើងគ្រាន់តែទៅបើក វាបញ្ជាវាយខ្លួនវាទេ។ វាអត់មាន យើងទៅវាយទាល់តែយើងផ្សាយវិញ អាហ្នឹងបានយើងវាយធ្វើខ្សែអាត់បញ្ចេញចាក់ផ្សាយទៅវិញ។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ។ ចុះទាក់ទងនឹងការចាប់ព័ត៌មានបាន នៅពេលដែលចាប់ព័ត៌មានសំខាន់ៗបាន តើលោកត្រូវធ្វើយ៉ាងណាទៀត ការងាររបស់លោកនុ៎ង?

[១០:០៦:០២]

**ឆ៖** ទាក់ទងនឹងព័ត៌មានដែលខ្ញុំចាប់ហើយ ខ្ញុំគ្រាន់តែមើលដឹងថា ព័ត៌មាននេះចប់ហើយ វាឈប់ធ្វើការ ខ្ញុំហែកទៅ ហើយកិបបញ្ជូនទៅកន្លែងគេ ដែលធ្វើការនៅហ្នឹង ដែលគេទទួលសម្រាប់ពិនិត្យឯកសារហ្នឹង ព័ត៌មានហ្នឹង។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ ចុះព័ត៌មានដែលលោកចាប់ហ្នឹង គេធ្វើឡើងជាភាសាអ្វីដែរ លោកនៅចាំទេ?

**ឆ៖** ព័ត៌មានដែលខ្ញុំចាប់ហ្នឹងមានតែពីរភាសាទេ គឺភាសាបារាំងនិងអង់គ្លេស។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ ចុះនៅក្នុងក្រសួងឃោសនាការនិងព័ត៌មាន តើមានក្រុមអ្នកបកប្រែភាសាព័ត៌មានដែលលោកចាប់បានថាជាភាសាបារាំង និងភាសាអង់គ្លេសហ្នឹងដែរទេ ឲ្យទៅជាភាសាខ្មែរហ្នឹង តើមានការបកប្រែអ៊ីចឹងទេ?

**ឆ៖** ខ្ញុំដឹងថា នៅពេលហ្នឹងគឺមាន ព្រោះខ្ញុំហែកបញ្ជូនទៅ ជូនឯកសារហ្នឹងកន្លែងខ្លះមិនមែនវាយតែក្រដាស*កាល់តែស*ហ្នឹង ខ្លះត្រូវបីសន្លឹក ខ្លះត្រូវប្រាំសន្លឹក ដល់អ៊ីចឹងគេប្រាប់ថា អានេះត្រូវយកបីសន្លឹក អាខ្លះត្រូវយកប្រាំសន្លឹកអ៊ីចឹង។ ក្រដាសកាបោនស្រាប់ហ្នឹង យើងដាក់ឲ្យវាយទៅ ហើយហែកកិបតាមនេះទៅ យើងបញ្ជូនឲ្យគេទៅ តែគេបញ្ជូនទៅណាទៀតខ្ញុំអត់ដឹងទេ។ តែគ្រាន់តែថាហ្នឹងដែលខ្ញុំដឹងខ្លះមកថា មានគេអ្នកស្តាប់វិទ្យុ ដល់អ៊ីចឹងគេយកអាព័ត៌មាន អាហ្នឹងយកទៅបន្ទឹមគ្នាជាមួយការស្តាប់វិទ្យុ តើវាត្រូវគ្នាឬអត់។ នេះខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹងបាទ។

[១០:០៨:១៦]

**ស៖** បាទ អរគុណ។

**លោក សេង ប៊ុនឃាង៖**

ហើយជាបន្ត ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីលើកឡើង និងដាក់នៅលើអេក្រង់ផងដែរ គឺនូវឯកសារដែលពាក់ព័ន្ធ ដែលឯកសារនេះអង្គជំនុំជម្រះបានទទួលយកហើយ គឺឯកសារលេខ E3/231 ដែលជាកំណត់ហេតុនៃអង្គប្រជុំការងារឃោសនាការ ដែលធ្វើនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ ហើយដែលមានការចូលរួមដោយសមាជិកអចិន្ត្រៃយ៍ និងសមមិត្ត ភាស់ ផងដែរ។

[១០:០៨:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ឯកសារនេះគឺនៅក្នុងផ្នែកទីII ត្រង់ ERN ជាភាសាខ្មែរ គឺ 00017126 ដល់ 27, ERN

ជាភាសាអង់គ្លេសគឺ 00183362, និងជាភាសាបារាំង គឺ 003239 និង 31។ ដែលមានចំណងជើងថា “មតិអង្គការ ស្ដីពីការតាមដានដំណឹងផ្សេងៗ” ផ្នែកទីពីរនេះបានសរសេរថា “អង្គការណែនាំឲ្យក្រសួងឃោសនាការ តាមដានដំណឹង និងក្ដាប់បញ្ហាឲ្យជាប់រាល់ម៉ោង រាល់ថ្ងៃ រួចចេញជាដំណឹង ដើម្បីមានវិធានការ។ ភារកិច្ចតាមដានដំណឹងចែកជាពីររយៈ។ ទី១ ពេលធម្មតាជូនដំណឹងទៅអង្គការរាល់ថ្ងៃ ដូចធម្មតា តែត្រូវរាយការណ៍សង្ខេបពីព្រឹត្តិការណ៍សំខាន់ៗដែលទាក់ទងនឹងយើង។ មានមតិវិភាគខ្លះដើម្បីអចន្ត្រៃយ៍ចាប់អារម្មណ៍ និងមានវិធានការ។ ម៉ោងប្រាំដប់ប្រាំនាទីល្ងាច មាននីរសាររបស់អង្គការផ្ទាល់យក -- មកយកដំណឹងនៅឃោសនាការ”។ សំណួររបស់ខ្ញុំនៅពេលនេះ គឺចង់ដឹងថាតើលោកបានដឹងអំពីថា ក្រសួងឃោសនាការត្រូវបានណែនាំឲ្យរៀបចំ ឲ្យអង្គការនូវសេចក្ដីសង្ខេបព័ត៌មានសំខាន់ៗដែលគ្រប់គ្រងដោយផ្នែករបស់លោកដែរឬទេ?

**ផះ** ខ្ញុំសូមជម្រាបជូនថា ខ្ញុំហាក់ដូចជាមិននឹកឃើញអីទាំងអស់ ព្រោះខ្ញុំជាអ្នកធ្វើហ្នឹងគឺថាប្រឹងតែធ្វើម៉េចកុំឲ្យការងារខ្លួនឯងប៉ះពាល់ដល់ គេថាខ្ញុំនឹងវាមិនល្អអ៊ីចេះអ៊ីចុះ ខ្ញុំវាដូចថាប្រឹងតែខ្លួនឯងដល់អ៊ីចឹងការងារអីផ្សេងទៀត ខ្ញុំអត់ដឹងទាំងអស់។ ដល់អ៊ីចឹងផ្នែកដែលខ្ញុំបញ្ជាក់ជូនខាងដើមហ្នឹងថា ខ្ញុំគិតតែប៉ុណ្ណឹង។ ដល់អ៊ីចឹងរឿងផ្សេងគឺថា ខ្ញុំអត់ដឹងរឿងទេ។ សូមអស់មតិបាទ។

[១០:១១:៥៦]

**សះ** បាទ អរគុណ។ ចុះទាក់ទងនឹងការងារទីពីរ ក្នុងឯកសារនេះដែរ គឺទាក់ទងនឹងការត្រួតពិនិត្យព័ត៌មានក្រៅប្រទេស ដែលៗមានសរសេរក្នុងកំណត់ហេតុហ្នឹង គឺបានសរសេរថា “ទី២ ពេលពិសេស បើមានអ្វីសំខាន់ជាពិសេសត្រូវទូរស័ព្ទ និងរាយការណ៍ជូនអង្គការភ្លាម ដើម្បីមានវិធានការទាន់ពេល”។ តើលោកដឹង បានដឹងអំពីកិច្ចនីតិវិធី ដែលត្រូវធ្វើប្រសិនជាផ្នែករបស់លោកចាប់ព័ត៌មានសំខាន់ៗបាន តើមានកិច្ចនីតិវិធីយ៉ាងម៉េចខ្លះលោកដឹងដែរទេ?

**ផះ** ខ្ញុំ -- ផ្នែកនេះខ្ញុំអត់មានបានយល់ដឹងអីទាំងអស់ ដូចខ្ញុំបញ្ជាក់ហើយ។ រឿងរបស់គេខ្ញុំអត់លូកដៃទៅដឹងរឿងអីទេ ខ្ញុំគិតតែរឿងរបស់ខ្ញុំ ធ្វើម៉េចឲ្យៗវាល្អសម្រាប់ខ្លួនខ្ញុំ។ ឯការងារដោយឡែកខ្ញុំខុសពីការងារខ្ញុំ ខ្ញុំអត់បានដឹងឮអីទាំងអស់។ សូមអស់មតិ។

**សះ** បាទ អរគុណ។ ចុះនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅកន្លែងនុ៎ង តើលោកមានដែលសង្កេតឃើញថាមាននរណាដែលអាចមានទូរស័ព្ទ ឬក៏មានមធ្យោបាយផ្សេងៗអាចទាក់ -- ដែលអាចទាក់ទងទៅអង្គការអីដែរទេ?

**ឆ៖** ការឃើញជាក់ស្ដែងរបស់ខ្ញុំ អាហ្នឹងជាការលាក់បាំង ដែលភ្នែកខ្ញុំមិនឃើញ ខ្ញុំមិននិយាយទេ តែគ្រាន់តែថា ដែលខ្ញុំរស់នៅវាដូចជាគ្មានលទ្ធភាពអីនឹងៗធ្វើអ៊ីចឹងៗ ដែលការដែលខ្ញុំរស់នៅវាអត់ វាអត់ឃើញសកម្មភាពអីចាប់អារម្មណ៍អីថា អូ! វាអីយ៉ាងម៉េចៗឲ្យខ្ញុំគិតគូរ។ តែដល់ឮរឿងអីផ្សេងមក គឺថា អាហ្នឹងរឿងរបស់គេ ខ្ញុំគិតតែខ្លួនខ្ញុំទេ ហើយប្រឹងតែធ្វើម៉េចកុំឲ្យគេ -- មានជំនឿលើខ្ញុំតែប៉ុណ្ណឹង។ ឲ្យគេជឿលើខ្ញុំថាអ្នក ខ្ញុំធ្វើត្រឹមត្រូវ ខ្ញុំធ្វើត្រូវល្អសម្រាប់ការងារខ្ញុំ។ សូមអស់មតិ។

[១០:១៤:១៥]

**ស៖** បាទ អរគុណ។ លោកបានជម្រាបជូនអង្គសវនាការថា ការងាររបស់លោកគឺធ្វើការផ្លាស់គ្នា គឺផ្លាស់ប្ដូរម៉ោងគ្នាធ្វើការ តើការងារផ្លាស់គ្នាហ្នឹងមាន -- ធ្វើការហ្នឹងមាននៅពេលយប់ដែរទេ?

**ឆ៖** ពេលវេលាធ្វើការដែលចែកជាម៉ោង ជាពេលនេះ យប់ក៏មានថ្ងៃក៏មាន គ្រាន់តែប្ដូរវេនគ្នាក្នុងនាមថា បើការងារហ្នឹងវាជាប់យើងបកមកហូបបាយ គេទៅបំពេញបន្ត ហើយការងារយប់បើគេយប់ខ្លាំង យើងដឹងថាដល់ម៉ោងបាយ បាយហើយយើងទៅជំនួសគេ។ នេះផ្លាស់ប្ដូរគ្នាប៉ុណ្ណឹងទេបាទ។

**ស៖** តើលោកនៅចាំទេថា ការផ្លាស់ប្ដូរគ្នាៗហ្នឹងនៅសល់បុគ្គលិកប៉ុន្មាននាក់ ដែលបានធ្វើការនៅទីនោះ?

**ឆ៖** សំណួរនេះ ខ្ញុំមិនដឹងថាខាងលោកចង់សួរខ្ញុំអីដែលពាក់ព័ន្ធ-- គាត់សួរអំមិញថា ការផ្លាស់ប្ដូរការងារហ្នឹង យ៉ាងម៉េច អីយ៉ាងម៉េចហ្នឹង ព្រោះខ្ញុំដែលឆ្លើយមុនអំមិញ ខ្ញុំចង់បញ្ជាក់ថាពីម្នាក់ទៅម្នាក់ដែលក្នុងពេលធ្វើការហ្នឹង គឺថាបើប្រចាំថ្ងៃហ្នឹង បើគេធ្វើ ខ្ញុំហូបបាយហើយ បើគេមិនទាន់ហូប ខ្ញុំប្ដូរទៅធ្វើជំនួសគេវិញ ឲ្យគេមកហូបម្ដង។ តែដល់លោកសួរអំមិញនេះ តើចង់សួររឿងអីបន្ថែមទៀត ឬមួយក៏អាខ្លឹមសារខាងមុនអំមិញ ខ្ញុំឆ្លើយទៅវាមិនត្រូវ?

[១០:១៦:១១]

**ស៖** អ៊ីចេះទេ លោកបានជម្រាបអង្គសវនាការថា លោកបានផ្លាស់ម៉ោងគ្នាធ្វើការ ហើយនៅកន្លែងដែលលោកធ្វើការគឺមានគ្នាបីបួននាក់។ អ៊ីចឹងនៅពេលដែលផ្លាស់គ្នាម្ដងៗ នៅសល់ប៉ុន្មាននាក់ទៅធ្វើការងារហ្នឹង តើម្នាក់ ឬក៏ប៉ុន្មាននាក់?

**ឆ៖** សូមជម្រាបលោកប្រធាន ការងារនេះមែនទែនវាអត់ត្រូវប្រើគ្នាច្រើនទេ តែម្នាក់អាចធ្វើបាន។ តែមានករណីលើកលែងក្នុងពេលដែលធ្វើយប់ខ្លាំង ហ្នឹងជូនឲ្យនៅពីរនាក់ ព្រោះចៀសវាងការងោកងងុយ។ នេះសូមជូនមតិប៉ុណ្ណឹងបាទ។

**ស៖** ចុះនៅក្នុងទាក់ទងទៅនឹងការងាររបស់លោកហ្នឹងដែរ តើមាននរណាម្នាក់ត្រូវបានគេចាត់តាំងឲ្យតាមដានព័ត៌មានជាប្រចាំដើម្បីរាយការណ៍ជូនថ្នាក់លើដែរទេ?

**ឆ៖** រឿងនេះ ខ្ញុំអត់បានដឹងដែរ។ វាគ្រាន់តែរស់នៅមែន តែអាការងារខុសពីរឿងរបស់ឯង ដូចអត់មានដឹង។ ខ្ញុំអត់ដឹង។ មិនដឹងគេចាត់ម៉េចអីម៉េចអាហ្នឹង ការងាររបស់គេខ្ញុំអត់ដឹង។ សូមអស់មតិបាទ។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចូលមកប្រធានបទមួយទៀត គឺចង់ដឹងថា តើលោកនៅចាំទេថា លោក ហ៊ូ នឹម ធ្វើជារដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មានហ្នឹងបានរយៈពេលប៉ុន្មានឆ្នាំដែរ?

[១០:១៨:២៨]

**ឆ៖** ខ្ញុំមិនដឹងពេលគាត់ធ្វើពីត្រឹមណាមកទេ ហើយគ្រាន់តែដឹងដែលគេដកគាត់ចេញ គឺក្នុងឆ្នាំ ៧៧ តែមិនដឹងជាដើមឆ្នាំ ឬចុងឆ្នាំ អាហ្នឹងវាអត់ៗកំណត់បាន ព្រោះខ្ញុំ ហៅថាភ្លេចពេលភ្លេចវេលា *(ឮមិនច្បាស់)* តែគ្រាន់តែដឹងថាឆ្នាំ គឺថាក្នុងឆ្នាំ១៩៧៧ ហ្នឹង ដូចមានដកគាត់។ តែដែលគាត់ទទួលតំណែងហ្នឹងពីថ្ងៃណាមកអីហ្នឹង ខ្ញុំអត់ដឹងទេ។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។ ជាបន្តខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីអាននូវចំណុចមួយដែលនៅក្នុង -- ដែលមាននៅក្នុងឯកសារ ដើម្បីរំឭកអំពីការចងចាំរបស់សាក្សី ថាតើគាត់នៅចាំអ្វីខ្លះទាក់ទងនឹងបញ្ហានេះ? ឯកសារនេះ គឺមានលេខ E3/1550 ត្រង់ ERN ជាភាសាខ្មែរគឺ 00008923, និងជាភាសាអង់គ្លេសគឺ 00249844 ដល់ 45, និងជាភាសាបារាំងគឺ 00766902 គឺជាឯកសារដែលសរសេរដោយលោក ហ៊ូ នឹម ផ្ញើទៅឲ្យ បងប៉ុល, បងនួន, បងវ៉ាន់, បងវន, សមមិត្ត ខៀវ, និង សមមិត្ត ហែម ដែលទាក់ទងនឹងការចាប់ខ្លួនគាត់ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

[១០:២០:២៣]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ បើសិនជាលោកអាចនៅចាំបានអំពីពេលដែលលោក ហ៊ូ នឹម បានបាត់ខ្លួននោះ។ មានលិខិតមួយដែលលោក ហ៊ូ នឹម បានសរសេរទៅកាន់ បងប៉ុល, បងនួន, បងវ៉ាន់, បងវន, សមមិត្ត ខៀវ និងសមមិត្ត ហែម។ ដែលនៅក្នុងលិខិតនោះបានសរសេរថា "ថ្ងៃនេះ ១០ មេសា ១៩៧៧ ដែលខ្ញុំកំពុងមមាញឹករៀបចំកម្មវិធីផ្សាយវិទ្យុទទួលអំណរបុណ្យខួបទី២ នៃមហាជ័យជម្នះ១៧ មេសា ១៩៧៥។ តាមទូរស័ព្ទសមមិត្ត ប៉ង់ បានហៅខ្ញុំមកធ្វើការជាមួយអង្គការ។ ពេលមិត្តយុទ្ធជនចាប់ខ្ញុំ ខ្ញុំភ្ញាក់ក្រញាង ខ្ញុំមិនស្មានយ៉ាងនេះសោះ"។ នេះនៅមានតទៀត ប៉ុន្តែខ្ញុំ នៅពេលនេះខ្ញុំសូមសួរលោកថា តើខ្លឹមសារដែលបានអានអម្បាញ់មិញនេះ អាចរំឭកការចងចាំរបស់លោកបានខ្លះទេ ទាក់ទងទៅនឹងការចាប់ខ្លួនលោក ហ៊ូ នឹម នៅក្នុងឆ្នាំ១៩៧៧ ពោលគឺបានធ្វើឡើងនៅមុនពេលរៀបចំពិធីខួបលើកទី២ នៃទិវាជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជាថ្ងៃ១៧ មេសា?

[១០:២២:០៣]

**លោក ខៀវ សំផន៖**

**ឆ៖** សូមមានមតិ។ រឿងចាប់របស់លោក ហ៊ូ នឹម នេះខ្ញុំគ្រាន់តែដឹងតែឆ្នាំដែលខ្ញុំបញ្ជាក់ខាងដើម ឯបញ្ហាជ្រៅរឿងហ្នឹង ខ្ញុំអត់មានបានដឹងអីទាំងអស់ អត់យល់អីទាំងអស់។ ហ្នឹងខ្ញុំសូមជូនយោបល់ដោយខ្លី ថាខ្ញុំមិនបានដឹងឮអីទាំងអស់ គ្រាន់តែថាដឹងបាត់ពេលហ្នឹង។ បាត់ក៏មូលហេតុអីយ៉ាងម៉េច ខ្ញុំអត់ដឹងទេ។

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំទេ ថាលោកដឹងថាបាត់ហ្នឹងដឹងដោយរបៀបណាដែរ?

**ឆ៖** ព្រោះដឹងដែលបាត់ក្រោយមកនេះដោយសារឯកសារដែលខ្ញុំបញ្ជូនឲ្យហ្នឹង ក៏មាននៅក្នុងហ្នឹង ហើយដែលខ្ញុំនៅចាំបានថា កាលហ្នឹងដែលចាប់ ហ៊ូ នឹម ហើយគឺលោកស្រី យុន យ៉ាត មកទទួល។ បាទ ដល់មកទទួលក្នុងក្រសួងហ្នឹង ក៏មានការប្រជុំ និងបញ្ជាក់ពីទោសកំហុសរបស់ ហ៊ូ នឹម ដែលចាប់ហ្នឹង ដើម្បីអ្នកនៅនុ៎ងគឺថា យល់ដឹង។ នេះដឹងដោយសារអ៊ីចឹងទេ ហើយឯកសារហ្នឹងក៏មិនបានឃើញផ្ទាល់ដែរ គ្រាន់តែអ្នកដឹកនាំដែលមកក្រោយហ្នឹង គឺថាគេបានបញ្ជាក់ពីរឿងថា បានសារភាពអ៊ីចឹង ហើយរឿងខ្ញុំទៅឃើញឯកសារហ្នឹង អត់ឃើញ អត់ដឹងទាំងអស់ បាទ។ នេះជាការបើកវគ្គបង្រៀនប្រជុំ នាំឲ្យដឹងឲ្យយល់ កុំឲ្យឆ្ងល់ទៀតហ្នឹង។

[១០:២៣:៥១]

**ស៖** បាទ អរគុណ។ ចុះលោកអាចជម្រាបបានទេថា កិច្ចប្រជុំ ឬក៏អាវគ្គបង្រៀនដែលលោកស្រី យុន យ៉ាត ដែលជាមកជំនួសលោក ហ៊ូ នឹម ហ្នឹង គាត់បានយកចម្លើយ -- បានបង្រៀនអំពីមូលហេតុនៃការចាប់ខ្លួន។ តើពេលនុ៎ង គាត់បានលើកឡើងពីមូលហេតុអ្វីខ្លះ ដែលលោកនៅចាំបាន ទាក់ទងទៅនឹងការចាប់ខ្លួនរបស់លោក ហ៊ូ នឹម ហ្នឹង?

**ឆ៖** តាមខ្ញុំនៅចាំបានខ្លះៗ ដឹងតែត្រឹមថា ហ៊ូ នឹម សារភាពថា គាត់ជាភ្នាក់ងារ សេ.អ៊ី.អា។ ហ្នឹងមកៗបញ្ចាក់ហ្នឹង គឺថាបានដឹងត្រឹមប៉ុណ្ណឹង ពីរឿងថាចូលពីឆ្នាំណាអីឆ្នាំណាហ្នឹង ខ្ញុំ ការចាំក៏មិនបានចាំ ហើយការដែលដឹងរហូតមកដល់ពេលនេះក៏អត់មានអីនៅដឹងនៅអីទៀតដែរ គ្រាន់តែដឹងថាកាលហ្នឹងគេថា សេ.អ៊ី.អា ក៏ ថា ដោះអាការដែលៗនៅស្រពេចស្រពិលថាមកពីរឿងអីហ្នឹង ក៏ អូ! មូលហេតុអីចឹងបានគេចាប់។ នេះ យើងគ្រាន់តែដោះខាងអារម្មណ៍របស់យើងអីចឹងទេ។ ហើយយើងចេះតែធ្វើការងារយើងទៀតទៅ អាហ្នឹង វាតែប៉ុណ្ណឹង។ សូមអស់មតិ។

**ស៖** ចុះលោកនៅចាំទេថា កាលដែលលោកស្រី យុន យ៉ាត ដែលមកបង្រៀនអំពីការ ឬក៏មកប្រាប់អំពីមូលហេតុនៃការចាប់ខ្លួនរបស់លោក ហ៊ូ នឹម ហ្នឹង តើមាននរណាខ្លះចូលរួមស្តាប់នៅពេលនោះដែរ ច្រើនគ្នាទេ?

[១០:២៥:៥៦]

**ឆ៖** កាលដែលស្តាប់ពីចម្លើយថាចូល ហ៊ូ នឹម សារភាពនោះ គឺថាមានជាវគ្គបង្ហាញជាធំដុំតែម្តង គឺថាមិនមែនថាបុគ្គលតិចតួចទេ ជាប្រជុំ ជារៀនសូត្រអីចឹង គឺថាលើកបញ្ហាហ្នឹង ឲ្យយល់ដឹង។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ ចុះនៅក្នុងវគ្គបង្ហាញរបស់លោស្រី យុន យ៉ាត ហ្នឹង តើគាត់មានបានលើកឡើងទេ ថាការដែល -- មូលហេតុដែលធ្វើឲ្យគាត់មកបង្ហាញអំពីមូលហេតុនៃការចាប់ខ្លួនរបស់លោក ហ៊ូ នឹម ហ្នឹង តើគាត់ទទួលបញ្ជាពីថ្នាក់ណាមកឲ្យអីចឹងដែរទេ ឬក៏យ៉ាងម៉េច?

**ឆ៖** កន្លែងសំណួរនេះ វា គឺថាហួសសមត្ថភាពដែលខ្ញុំមិនអាចដឹង។ វាកន្លែងហ្នឹង ដែលវាៗ ពីណាបញ្ជាឲ្យគាត់ទៀត គឺថាខ្ញុំអត់ដឹងទេ អាហ្នឹងដូចវាហួសកម្រិតដែលខ្ញុំមិនបានទទួលយកកើត មិនបានត្រូវសិក្សាអីចឹងៗ ដែលដឹងឃើញមក អត់ វាហួស។

[១០:២៧:២០]

**ស៖** មិនថ្វីទេ ប៉ុន្តែសំណួររបស់ខ្ញុំ ដែលចង់ដឹង គឺចង់ដឹងថា នៅពេលដែលបើកវគ្គបង្រៀន

ឬក៏បង្ហាញទុំង តើលោកស្រី យុន យ៉ាត ហ្នឹង គាត់មានបាននិយាយទេ ថាអ្នកណាឲ្យគាត់បើកវគ្គនេះ ដើម្បីបង្ហាញអំពីការចាប់ខ្លួនរបស់លោក ហ៊ូ នឹម ហ្នឹង? បើសិនជាមាន សូមលោកជួយបញ្ជាក់ បើសិនជាគ្មានទេ តាមហ្នឹងទៅ បាទ។

**លោក សុន អរុណ៖**

សូម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

លោកព្រះរាជអាជ្ញាបានសួរម្តងហើយ។ សាក្សីបានឆ្លើយថា អត់ដឹងទេ វាហួសសមត្ថភាពគាត់។ លោកព្រះរាជអាជ្ញានៅតែសួរដដែល ជជីកដដែល។ អានេះជាពាក្យច្រំដែល។ ហើយធ្វើឲ្យសាក្សីឆ្លើយនៅក្នុងការស្មាន។ សូមជំទាស់។

**លោក សេង ប៊ុនឃាង៖**

បាទ លោកប្រធាន។ ខ្ញុំសូមឆ្លើយតបទៅនឹងការជំទាស់របស់លោកមេធាវី សុន អរុណ។ មូលហេតុដែលខ្ញុំបញ្ជាក់អម្បាញ់មិញ ដោយសារសាក្សីបានឆ្លើយមិនត្រូវនឹងសំណួររបស់ខ្ញុំ។ គាត់ឆ្លើយនូវអ្វីដែលគាត់មិនអាចដឹង ប៉ុន្តែសំណួររបស់ខ្ញុំ គឺចង់ដឹងថា ពេលនោះ លោកស្រី យុន យ៉ាត គាត់បាននិយាយទេ នៅពេលដែលគាត់បង្រៀនហ្នឹង។ មិនមែនជាអ្វីដែលឲ្យគាត់ ត្រូវដឹងដោយខ្លួនគាត់ទេ បាទ។

[១០:២៨:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុ នូវសេចក្តីមិនសមស្រប។ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញា ដែលបានសួរលោកអម្បាញ់មិញនេះ។

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរ រឿងអ្នកបញ្ជាពីលើ យុន យ៉ាត ទៀតនេះ ខ្ញុំអត់បានដឹងទេ។ នេះសូមអស់ប៉ុណ្ណឹង។

**ស៖** អ៊ីចេះ ដើម្បីឱ្យច្បាស់សំណួរ។ សំណួររបស់ខ្ញុំគឺអ៊ីចេះ ចង់ដឹងថា នៅពេលដែលលោកស្រី យុន យ៉ាត គាត់បើវគ្គបង្ហាញអំពីការចាប់ខ្លួនលោក ហ៊ូ នឹម នៅកន្លែងដែលលោកធ្វើការនុ៎ង តើនៅពេលនុ៎ង លោកស្រី យុន យ៉ាត បានលើកឡើងទេ នៅក្នុងវកិច្ចបង្ហាញនុ៎ង ថាមូលហេតុដែលគាត់មកបង្ហាញនេះ គឺដោយសារមានថ្នាក់លើណា មកឱ្យគាត់មកធ្វើបែបនេះ។ តើមានគាត់និយាយអ៊ីចឹងដែរទេ?

[១០:៣០:០០]

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ ដើម្បីឱ្យខាងអស់លោកយល់។ បញ្ហាដែល យុន យ៉ាត មកទទួលហើយនេះ ហើយបានយកបញ្ហាដែលរឿងចាប់ ហ៊ូ នឹម ទៅ មកជម្រាបជូនបងប្អូននៅពេលនោះ គឺថា អ្នកដែលត្រូវកំណត់ឱ្យ យុន យ៉ាត ហ្នឹងយកមកពីលើទៀតហ្នឹងគឺថា ខ្ញុំមិនបានដឹងយល់ទេ តែគ្រាន់តែ គាត់ថានេះជាការសម្រេចរបស់បក្ស ដោយមានឯកសារនេះ ថាអ្នកនេះឯងជាភ្នាក់ងារ សេ.អ៊ី.អា។ នេះខ្ញុំៗនិយាយឱ្យ *(ឮមិនច្បាស់)* ហើយដល់អ៊ីចឹង មូលហេតុដែលបាត់មកនេះ មនុស្សក៏វាៗលែងគិតថា អូ! មកពីអ៊ីចឹងបានតែគេចាប់នេះ។ នេះខ្ញុំសូមជូន អស់មតិប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ លោកបានឆ្លើយនឹងសំណួរហើយ។ តើលោកអាចនៅចាំទេថា ការបង្ហាញរបស់លោកស្រី យុន យ៉ាត នៅពេលនោះ គាត់បង្ហាញនៅកន្លែងណាដែរ?

[១០:៣១:២៨]

**ឆ៖** ខ្ញុំចាំបានតែរឿងការបញ្ជាក់ប្រាប់ពីរឿងថា ចាប់ដោយថាជាទីភ្នាក់-- អ៎!ជាភ្នាក់ងាររបស់ សេ.អ៊ី.អា អ៊ីចឹង តែខ្ញុំនឹកគិតទៅវិញគឺថា ខ្ញុំដូចជាដែលត្រូវបានរៀនសូត្រ កាលនោះសន្និបាត ប្រជុំអីហ្នឹងមានតែពីរដងទេ តាមខ្ញុំគិត។ ដល់អ៊ីចឹងខ្ញុំមិនដឹងថា តើនៅលីសេដេកាតហ្នឹង ក្នុងក្រសួងខ្ញុំហ្នឹង ឬមួយក៏នៅកាលនុ៎ងមាន គេហៅអីទេ? បុរីកីឡានុ៎ង។ ដល់អ៊ីចឹងកន្លែងពីរហ្នឹងខ្ញុំកំណត់អត់បាន ដឹងនៅកន្លែងមួយណាអ៊ីចេះ។ ហើយពេលវេលាអីហ្នឹង ខ្ញុំអត់ៗចាំទេ។ តែគ្រាន់ថា ខ្ញុំបានចូលហ្នឹងតែពីរកន្លែងហ្នឹងទេ។ ចៀសពីហ្នឹងអត់មានចូលរួមអីប្រជុំធំអីទេ អានេះជាការដែលៗប្រជុំប្រកាសអីហ្នឹង គឺថាដឹងតែពីរកន្លែងហ្នឹង។ តែមិនដឹងជានៅបុរីកីឡា ឬនៅលីសេដេកាតនេះ។ សូមអស់មតិ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០ នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ ក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:១៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។

[១០:៥៤:០៧]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក ខៀវ អេន ឥឡូវខ្ញុំបន្តសំណួររបស់ខ្ញុំតទៅទៀត។ តើលោកដឹងទេថា បន្ទាប់ពី ហ៊ូ នឹម ត្រូវបានចាប់ខ្លួន តើអ្នកដែលមានការពាក់ព័ន្ធជាមួយ ហ៊ូ នឹម ឬក៏ហៅថា ខ្សែរបស់ ហ៊ូ នឹម ហ្នឹងត្រូវបានគេចាប់ខ្លួនដែរទេ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ ក្រោយពីចាប់ ហ៊ូ នឹម ទៅ អ្នកដែលធ្វើការនៅក្នុងកន្លែងនោះ គឺថាបានដកទៅជាបន្តបន្ទាប់ ទាំងការងារកន្លែងគេ ក៏ដូចជានៅក្នុងកន្លែងខ្ញុំ គឺថាបានដកជាបន្តបន្ទាប់។

នេះសូមមានមតិប៉ុណ្ណឹង។

[១០:៥៥:០៩]

**ស៖** ចុះលោកមានដឹងទេថា ប្រពន្ធកូនរបស់លោក ហ៊ូ នឹម ហ្នឹងត្រូវបានបាត់ខ្លួនដែរទេ?

**ឆ៖** ប្រពន្ធកូន ហ៊ូ នឹម ហ្នឹងក៏បាត់ដែរ តែខ្ញុំក៏មិនដឹងថា បាត់ទៅពេលជាមួយគ្នា ឬក៏ថ្ងៃក្រោយទេ ខ្ញុំក៏អត់ចាំដែរ។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ ចុះលោកស្គាល់ប្រពន្ធលោក ហ៊ូ នឹម ដែរទេ?

**ឆ៖** ខ្ញុំ -- ប្រពន្ធគ្រាន់តែថា ខ្ញុំបានឃើញ តែឈ្មោះអីហ្នឹងខ្ញុំមិនដឹងទេបាទ។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ យោងតាមចម្លើយរបស់លោកដែលបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែលនៅឯកសារE3/438 ផងដែរ លោកបានឆ្លើយថា "ក្រោយពេលចាប់ខ្លួន ហ៊ូ នឹម ហើយអ្នកដែលចូលរួមបណ្តុះបណ្តាលជាមួយខ្ញុំក៏ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ"។ ចម្លើយនេះមាននៅក្នុងឯកសារហ្នឹងនៅត្រង់ERN ជាភាសាខ្មែរគឺ00373433, ជាភាសាអង់គ្លេស 00375873 និងជាភាសាបារាំងគឺ 00426430។ តើលោកដឹងដោយរបៀបណាដែលថា មានការចាប់ខ្លួនអ្នកធ្វើការនៅក្រសួងឃោសនាការជាបន្តបន្ទាប់ក្រោយពេលចាប់ខ្លួន ហ៊ូ នឹម ហ្នឹង?

[១០:៥៧:១៧]

**ឆ៖** ខ្ញុំបានដឹងពីរឿងហៅថា ចាប់ ហ៊ូ នឹម ហើយវាត្រូវចាប់អ្នកបន្តបន្ទាប់ទៀត។ ក្នុងនោះគឺថា អ្នកដែលត្រូវបាត់បន្តបន្ទាប់ ដែលដកចេញទៅគឺថា អ្នកធ្វើការជាមួយខ្ញុំហ្នឹងក៏គេទៅអស់ទៅ។ មែនទៅការងារខាងគេនោះ អាន៎ុងផ្សេង ប៉ុន្តែដល់ខាងខ្ញុំនៅសល់តែខ្ញុំម្នាក់ឯង ក្រោយមកបាទ។ គេដកទៅតែដឹងគេយកទៅណាមកណា អាហ្នឹងរឿងគេ ខ្ញុំអត់ដឹងទេ តែគ្រាន់ថា ចាប់ដកចេញ ដែលៗតាំងពីវគ្គបណ្តុះបណ្តាលជាមួយគ្នាមកប៉ុន្មានហ្នឹង គឺថានៅសល់តែខ្ញុំម្នាក់ឯង។ ហ្នឹងសូមមានមតិ។

**ស៖** បាទ អរគុណ។ នៅក្នុងឯកសារដដែល គឺ E3/438 ត្រង់ ERN ជាភាសាខ្មែរគឺ 00373433, ជាភាសាអង់គ្លេសគឺ 00375874 និងជាភាសាបារាំងគឺ 00426431។ លោកបានលើកឡើងអំពីចាប់ខ្លួនមនុស្សមួយចំនួនដែលនៅក្នុងនោះ ក៏មានឈ្មោះ សល់ ផងដែរ តើលោកអាចបញ្ជាក់បានទេឈ្មោះ សល់ ហ្នឹងគាត់ជានរណាដែរ?

[១០:៥៨:៤៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថាឈ្មោះ សល់ នេះគឺ ហើយនិង អុល នេះគឺថា គេអ្នកនៅមុន ដែលខ្ញុំចូល

ទៅគឺថាឃើញគេនៅនឹងកន្លែងនុ៎ងហើយ។ នៅនឹងកន្លែងការងារនុ៎ងហើយ ដល់អ៊ីចឹងខ្ញុំជាអ្នកចូលទៅនៅថ្មីហ្នឹង ដល់ទៅគេចែកឲ្យខ្ញុំនៅជាមួយ អុល ហ្នឹង ហើយ សល់ ហ្នឹងគឺថា គេទទួលនៅផ្នែកខាងផ្សាយអ៊ីចេះ ផ្សាយ។ អាហ្នឹងដែលខ្ញុំចូលទៅឃើញដំបូង ដឹងរឿងដំបូងបាទ។ តែដល់ក្រោយមកដែលត្រូវចាប់ហ៊ូ នឹម ហើយនេះគឺថា សល់ ហ្នឹងក៏គេដកចេញទៅអស់ដែរ។ ដល់អ៊ីចឹងដែលខ្ញុំបញ្ជាក់ថានៅសល់ គឺខាងៗ សល់ ហ្នឹងមែនទែននៅសល់ម្នាក់។ ហើយដល់ខាងខ្ញុំនឹងនៅសល់ម្នាក់ ហើយដែលខ្ញុំដឹងៗថា ម្នាក់នៅសល់ហ្នឹង នៅជាមួយ សល់ នៅម្នាក់ហ្នឹងគឺឈ្មោះ ទិត បាទ។ ហើយធ្លាប់ដឹងមកថាទិត នោះជាៗអ្នកនៅខាងស្វាយរៀងអ៊ីចេះ។ អាហ្នឹងគ្រាន់តែដឹងបានប៉ុណ្ណឹងបាទ។ សូមអស់មតិបាទ។

**ស៖** បាទ អរគុណ។

[១១:០១:១៦]

**លោក សេង ប៊ុនឃាង៖**

ហើយជាបន្តទៀតនេះដែរ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីលើកឡើងអំពីបញ្ជីអ្នកទោស ស-២១ ដែលបានសួរកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារហ្នឹងមានលេខ IS16.109, នៅត្រង់ERN ជាភាសាខ្មែរ គឺ 00039907, ជាភាសាអង់គ្លេស 00746762, និងជាភាសាបារាំងគឺ 00710269។ ហើយនៅក្នុងឯកសារនេះគឺបានបញ្ជាក់អំពីឈ្មោះម្នាក់ដែលមានឈ្មោះថា ប៊ុន ឈាងស្រ៊ៃ ហៅ សល់។ ដើម្បីរំឭកអំពីការចងចាំរបស់សាក្សីនៅពេលនេះផងដែរបាទ សូមលោកប្រធានអនុញ្ញាត។

[១១:០១:១៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សីនៅក្នុងបញ្ជីឯកសារអ្នកទោស ស-២១ ដែលបានសួរនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ ហ្នឹង គឺនៅក្នុងបញ្ជីនោះមានឈ្មោះមួយដាក់ឈ្មោះថា ប៊ុន ឈាងស្រ៊ៃ ហៅ សល់ ហើយគាត់ហ្នឹងគឺជា មានតួនាទីជាមេពុំ -- មេក្រុមទូរពុម្ពនៅ ក-៣៣ ហើយត្រូវបានគេចាប់ខ្លួននៅក្នុងខែមីនា ឆ្នាំ១៩៧៨។ តើឈ្មោះ សល់ នេះឬដែលលោកបានឆ្លើយថាបានខ្លួនពីក្រសួងឃោសនាការនុ៎ង?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំឆ្លើយថាហ្នឹង ឬមិនមែនក៏ខ្ញុំឆ្លើយអត់កើត។ ដោយសារអី? ដោយសារថាឈ្មោះដើមគាត់ក៏ខ្ញុំអត់ដឹង។ ហើយអ៊ីចឹង ខ្ញុំដឹងត្រឹមតែថាដែលខ្ញុំទៅជួបហើយ គេនៅមុនខ្ញុំ ទៅឮគេហៅសល់ៗ ហ្នឹងក៏ហៅតាមគេទៅ ហើយគេអ្នកទទួលផ្នែកហ្នឹង គេគ្រប់គ្រងផ្នែកហ្នឹង ហើយបាត់ពេលហ្នឹងក៏ខ្ញុំអត់ដឹងថាគេបាត់ទៅណាមកណា អត់ដឹងទេ។ នេះបានត្រឹមប៉ុណ្ណឹង ដែលខ្ញុំ -- សូមអស់មតិបាទ។

[១១:០២:៤៤]

**ស៖** បាទ អរគុណ។ ចុះឈ្មោះ សល់ ដែលៗលោកលើកឡើងអម្បាញ់មិញហ្នឹង គាត់ធ្វើការនៅក្នុងមន្ទីរ ក-៣៣ ជាមួយលោកអ៊ីចឹងដែរមែនទេ?

**ឆ៖** ឈ្មោះ សល់ នេះគឺឈ្មោះដូចខ្ញុំបញ្ជាក់អ៊ីចឹង ខ្ញុំមិនដឹងទេ តែខ្ញុំបានជួប គឺឈ្មោះ សល់ នេះបានធ្វើការនៅក្នុងមន្ទីរហ្នឹងដែរ។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចូលមកប្រធានបទមួយទៀត ដែលទាក់ទៅនឹងតួនាទីរបស់លោក នួន ជា។ តើលោកធ្លាប់ឃើញ ឬក៏ជួបលោក នួន ជា ដែរទេ ក្នុងអំឡុងពេលដែលលោកធ្វើការនៅក្រសួងឃោសនាការនុ៎ង?

**ឆ៖** សូមគោរពលោកប្រធាន។ ខ្ញុំជាមួយលោក នួន ជា គឺថាខ្ញុំធ្លាប់ជួប ធ្លាប់ស្គាល់ ដឹង ដោយគាត់បានទៅធ្វើការនៅកន្លែងហ្នឹងបាទ។ សូមអស់យោបល់។

[១១:០៣:៥៦]

**ស៖** បាទ អរគុណ។ តើលោកជួបលោក នួន ជា ដំបូងគេនៅក្នុងពេលណាដែរ លោកចាំបានទេ?

**ឆ៖** ខ្ញុំសូមមានមតិថា ខ្ញុំរកពេល ឲ្យកំណត់ថាខ្ញុំជួបនៅកន្លែងណាៗអត់ទេ តែគ្រាន់ថាការងារខ្ញុំហ្នឹងគឺបានខាងលោកហ្នឹងទៅអើតព្រឹកល្ងាច។ ពេលព្រឹកៗហ្នឹង ឃើញគាត់ទៅរាល់ព្រឹកអ៊ីចឹង។ តែដល់ទៅជួបប្រាស្រ័យទាក់ទងនិយាយអីហ្នឹងគឺថា វាហៅថាការងាររបស់យើង និងការងាររបស់គាត់ដូចថាវាៗឆ្ងាយ។ ដល់អ៊ីចឹងគឺថា ការទំនាក់ទំនងអីមិនបានជួបអីជាៗញឹកញាប់ ឬមួយក៏ពេលខ្លះជួបដោយមានយកឯកសារ ឬមួយក៏ករណីអីដែលនេះ អាន៎ុងមាន។ ប៉ុន្តែចៀសពីហ្នឹង គឺថាគ្មានអីដែលនេះទេ -- អត់មានទេ ការងារប្រចាំអីជាមួយគាត់អត់ទេ។ សូមអស់មតិ។

**ស៖** បាទ អរគុណ។ ចុះលោកជួបលោក នួន ជា ដែលយកឯកសារមកហ្នឹង តើយកឯកសារអ្វី

ដែរ? លោកនៅចាំទេ?

**ឆ៖** សំណួរនេះ ខ្ញុំដូចជារកចំណុចឆ្លើយអត់ឃើញ មិនដឹងៗសួរខ្ញុំពីរឿងថា នួន ជា ហ្នឹងយកឯកសារអីមកនេះ ខ្ញុំមិនយល់។

**ស៖** អ៊ីចេះ អម្បាញ់មិញលោកបានជម្រាបជូនអង្គសវនាការថា លោកធ្លាប់បានជួប នួន ជា តែមិនសូវជាញឹកញាប់អីប៉ុន្មានទេ។ គឺពេលខ្លះលោក នួន ជា បានយកឯកសារមក តើលោកចាំទេថា ឯកសារដែលលោក នួន ជា យកមកហ្នឹង ជាឯកសារអ្វីខ្លះពាក់ព័ន្ធនឹងបញ្ហាអ្វីដែរ លោកនៅចាំទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញតំណាង -- លោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

[១១:០៦:២៦]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ នៅក្នុងការបកប្រែជាភាសាអង់គ្លេសសាក្សីនិយាយថា ទាក់ទងទៅនឹងឯកសារ អ៊ីចឹងតើសាក្សីគាត់បាននិយាយថា អ៊ីចឹងដែរឬទេថាបានឃើញលោក នួន ជា ឬក៏ឯកសារហ្នឹងជាអ្នកសរសេរទេបាទ?

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន ដើម្បីបញ្ជាក់ឲ្យច្បាស់អំពីបញ្ហានេះ សូមអនុញ្ញាតពីលោកប្រធានដើម្បីឲ្យសាក្សីឆ្លើយបញ្ជាក់ឲ្យបានច្បាស់ថា តើបញ្ហានេះវាយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតាំងសំណួរឲ្យបានច្បាស់លាស់សិន មិនៗដឹងសួរយ៉ាងម៉េច គាត់ម៉េចនឹងឆ្លើយដឹង?

[១១:០៧:២៥]

**លោក សេង ប៊ុនឃាង៖**

អ៊ីចេះទេលោកប្រធាន មុននឹងសាក្សីបានឆ្លើយថា ជួបលោក នួន ជា បានយកឯកសារមកអ៊ីចឹងហើយដើម្បីឲ្យច្បាស់លាស់អំពីបញ្ហានេះ តើចង់សួរសាក្សីទាក់ទងទៅនឹង តើយកឯកសារមករបស់ នួន ជា តើ នួន ជា គាត់យកមកកន្លែងណា? យកមកឲ្យលោកសាក្សី ឬក៏យ៉ាងណា?

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អ៊ីចឹងសំណួររបស់ខ្ញុំទៅលោកសាក្សីនៅពេលនេះគឺថាតើពាក្យដែលលោកបានឆ្លើយជម្រាបជូនអង្គសវនាការអម្បាញ់មិញថាលោក នួន ជា បានយកឯកសារមកហ្នឹង តើលោក នួន ជា យកឯកសារមកខាងណាដែរ មកឲ្យលោក ឬក្រុមរបស់លោក ឬក៏ឲ្យខាងណា?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំស្ដាប់ទៅខ្ញុំដូចអត់ទាន់យល់ពីរឿងសំណួរសោះ ហើយនិងថាខ្ញុំឆ្លើយពីរឿងឯកសារអីទេខ្ញុំ អ្វីដែលខ្ញុំនិយាយហើយ ខ្ញុំហាក់ដូចជាពាក្យហ្នឹងខ្ញុំនិយាយយ៉ាងម៉េចបានខាងនុ៎ងឮទៅអ៊ីចឹងវិញអ៊ីចឹងបានខ្ញុំកំពុងពិចារណាខ្លួនឯងនេះ។ ហើយថាខ្ញុំនិយាយអំមិញ ខ្ញុំនិយាយយ៉ាងម៉េចបានខាងហ្នឹងចោទសួរមកថា លោក -- ថាខ្ញុំ -- ថា នួន ជា យកឯកសារមក ខ្ញុំ -- ដូចថាវាត្រឡប់ទៅៗស្ដាប់ខាងសំណួរលោកវិញ ខ្ញុំរកៗឆែកខ្លួនខ្ញុំវិញ។ ហ្អេ! ខ្ញុំឆ្លើយយ៉ាងម៉េចបានខ្ញុំត្រូវខាងនោះសួរមក ហើយខ្ញុំរកនឹកអត់ឃើញ។ សូមបញ្ជាក់។

[១១:០៨:៤៩]

**ស៖** បាទ អ៊ីចេះដើម្បីឲ្យច្បាស់សំណួររបស់ខ្ញុំ ដើម្បីបញ្ជាក់ឲ្យច្បាស់ថា តើលោក នួន ជាមានបានយកឯកសារទៅកន្លែងដែលលោកធ្វើការនោះដែរទេ?

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ រឿងឯកសារអីរបស់គាត់ៗ ខ្ញុំមិនដឹងរឿងអីទាំងអស់ អាហ្នឹងខ្ញុំនិយាយ។ មានតែខ្ញុំ អ្នកដែលខ្ញុំចាប់ហើយ ខ្ញុំយកឯកសារដែលខ្ញុំចាប់នេះ យកទៅជូនខាងនុ៎ងវិញ។ ចង់និយាយថា ព័ត៌មានអីៗដែលខ្ញុំចង់បញ្ជាក់ថា ពីការងារខ្ញុំហ្នឹង ខ្ញុំបញ្ជូនទៅខាងនុ៎ងវិញ ដើម្បីឲ្យខាងលើហ្នឹងគេចាត់ចែង តែរឿងខាងលើឲ្យមកខ្ញុំវិញនេះ វាអត់ វាអ៊ីចេះ អ៊ីចឹងបានខ្ញុំចេះតែនឹកថា សំណួរហ្នឹងវាយ៉ាងម៉េចបានត្រូវសួរអ៊ីចឹង ហើយខ្ញុំមិនដឹងត្រូវឆ្លើយម៉េច។

**ស៖** បាទ អរគុណ។

**ឆ៖** បាទៗ។

**ស៖** លោកក៏បានជម្រាបជូនអង្គសវនាការផងដែរថា លោក នួន ជា បានទៅអើតព្រឹកៗ តើអើតហ្នឹង ទៅអើតនៅកន្លែងណា? ហើយអើតធ្វើអ្វី?

[១១:១០:០៦]

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ព្រោះគាត់កន្លែងទីស្នាក់របស់គាត់ គឺថាមិននៅទីនេះទេ គាត់

មានកន្លែងស្នាក់របស់គាត់ ដែលខ្ញុំមិនដឹងមិនយល់ទេ។ តែគ្រាន់តែការងារគាត់បានមកអើតកន្លែងខ្ញុំហ្នឹង ព្រោះពេលព្រឹកឡើងគាត់មកហើយ។ ដល់អ៊ីចឹងពេលព្រឹកឡើងមកហ្នឹង ខ្ញុំគ្រាន់តែជម្រាបជូនថា គាត់មកហ្នឹងគ្មានអីទេ ដល់ដូចថាដើរអើតមើល សួរថាមានបាយទឹកហូបអីខ្លះៗ គាត់ដើរអើតតាមកន្លែងសម្រាកកន្លែងអីហ្នឹង បាទ។ នេះជាការដែលអើត ហើយមកមើលដាក់ស្ដែង និងៗកន្លែងការងាររបស់ខ្ញុំហ្នឹង។ ដូចថាទៅអើតចង្ក្រានខ្លះទៅ អើតមើលកន្លែងដេកខ្លះទៅ ហើយអ្នកណាដែលដេកវាមិនរហ័សរហួនអី គាត់ដាស់តឿនទៅ។ អានេះខ្ញុំៗនិយាយពីការពិត ដែលខ្ញុំឆ្លងកាត់បាទ។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹងបាទ។

**ស៖** តើលោកនៅចាំទេថា លោក នួន ជា ទៅទីនុំងក្នុងនាមគាត់មានតួនាទីអ្វីដែរ?

[១១:១១:៣១]

**ឆ៖** ខ្ញុំ ក្នុងសំណួរនេះ ខ្ញុំគ្រាន់តែដឹងថា កាលដែលដក ហ៊ូ នឹម ហើយ យុន យ៉ាត ចូលមកទទួល បន្ទាប់ពី ហ៊ូ នឹម បាទ។ តែដល់ផុតពី យុន យ៉ាត ហើយ លោក នួន ជា គាត់ចូលមកជំនួសម្ដង។ ដល់អ៊ីចឹងរឿងតួនាទីអីរបស់គាត់ ខ្ញុំមិនដឹងថា អ្ហែ! ជាឯកសារអីសរសេរយ៉ាងម៉េចអត់ដឹងទេ គ្រាន់តែអង្កាល់ខ្ញុំដឹងថាជាគណៈអចិន្ត្រៃយ៍ ហើយដូចខ្ញុំសម្ភាសក្នុងនោះថា ខ្ញុំឮតាមវិទ្យុទេកន្លងមក ឧបមាថ្នាក់ដឹកនាំលើៗ ខ្ញុំមិនបានជួបមិនបានស្គាល់មិនបានអីទេ តែដល់ស្ដាប់វិទ្យុនេះទៅ អូ!ឈ្មោះនេះ។ បាទ ដល់ទទួលគាត់មកធ្វើ បានដឹងថាគាត់ជាគណៈអចិន្ត្រៃយ៍អ៊ីចេះ។ នេះសូមជូនមតិប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ តើលោកមានបានដឹងទេថា នៅក្រៅពីតួនាទីរបស់លោក នួន ជា ដែលជាគណៈអចិន្ត្រៃយ៍ហ្នឹង តើគាត់មានតួនាទីអ្វីដែលទេនៅក្នុងក្រសួងឃោសនាការហ្នឹង?

**ឆ៖** ពេលគាត់អញ្ជើញមក ខ្ញុំក៏ក្ដាប់មិនបានថា គាត់មកក្នុងនាមអីជាៗមកទទួលក្នុងក្រសួងហ្នឹង ឬម៉េច តែគ្រាន់តែការងារគាត់មកៗ ព្រលឹមឡើងគាត់មកដល់ៗ។ តែត្រង់ថាឲ្យឮថា គាត់ត្រូវមកទទួលក្រសួងហ្នឹងជំនួសអានេះអានោះ វាៗអត់មានចេញឲ្យខ្ញុំដឹងពេលហ្នឹងអីផង។ សូមអស់មតិ។

[១១:១៣:២២]

**ស៖** ចុះទាក់ទងទៅនឹងកន្លែងធ្វើការរបស់គាត់នៅក្រសួងហ្នឹង តើគាត់មានកន្លែងធ្វើការនៅក្រសួងហ្នឹងដែរឬទេ *អហ្វហ្វីស* របស់គាត់?

**ឆ៖** កន្លែងធ្វើការ ខ្ញុំគ្រាន់តែបានដឹងថា ដូចជាមិនមានបន្ទប់អីធម្មតាឲ្យរៀបរយទេ គឺថាដូចថាគាត់រៀបកន្លែងគាត់មួយ កាលណាគាត់ធ្វើការហើយគាត់ដើប ចុកដៃចុកជើងគាត់ដើរហាត់ប្រាណ

អ៊ីចឹងបន្តិចទៅ ពេលនេះគាត់មកអង្គុយវិញទៅ ហើយដូចជាវាទូលាយ មិនជាសម្ងាត់អីនៅដោយឡែក ដាច់តែឯងទេ។ វានៅក្នុងចំណោមរបស់អស់លោក ដែលធ្វើការនៅហ្នឹងទាំងអស់គ្នាដែរ។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹង បាទ។

**ស៖** អ៊ីចឹងមានន័យថា ទីកន្លែងធ្វើការ ការិយាល័យធ្វើការរបស់លោក នួន ជា ក៏នៅស្ថិតនៅក្នុងទីតាំងដែលធ្វើការនៅនុ៎ងដែរ អ៊ីចឹងមែនទេ?

[១១:១៤:៤០]

**ឆ៖** ខ្ញុំគ្រាន់តែជូនថា អគារវាធំ ដល់អ៊ីចឹងវាមានអាបន្ទប់ដោយឡែកៗ ដែលតលិចកើតច្រើនទៅ។ ដល់អ៊ីចឹងតួអគារធំហ្នឹង គឺថាគាត់នៅធ្វើការហ្នឹងទៅ ហើយមានពួកអ្នកដែលការងារជុំវិញផ្សេងទៀត ដែលគេធ្វើការហ្នឹង គេនៅក្បែរៗហ្នឹងដែរទៅ ឯខ្ញុំវានៅដាច់ដោយឡែក។ តែគ្រាន់តែវាក្នុងបរិវេណដែលក្រសួងហ្នឹងគេរៀបចំហ្នឹង បាទ។

**ស៖** បាទ អរគុណ។ ចុះនៅក្នុងអំឡុងពេលនោះដែរ តើលោក នួន ជា គាត់បានបង្កើត ឬក៏រៀបចំឲ្យមានកិច្ចប្រជុំវគ្គនយោបាយ ឬក៏វគ្គបណ្តុះបណ្តាលអ្វីដែរទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា រឿងវគ្គនយោបាយនេះ អ្នកដែលធ្វើបដិវត្តន៍ហ្នឹង វាៗជាអាជីពរបស់វាមកហើយ។ ដល់អ៊ីចឹង ទាល់តែដូរមេ ចាប់អ្នកនេះ ចាប់អ្នកនោះដកចេញទៅ គឺថាអាកិច្ចដំណើរការហ្នឹង វានៅតែមានរហូត។ ដល់អ៊ីចឹង ពេលគាត់មកហ្នឹង ក៏នៅដដែល ពីមុនយ៉ាងម៉េច ក៏ការប្រជុំអីហ្នឹង វានៅតែមានជាបន្តបន្ទាប់។

[១១:១៦:០៦]

**ស៖** ចុះលោកនៅចាំទេ ថាលោកធ្លាប់បានចូលរួមក្នុងវគ្គនយោបាយ ឬក៏វគ្គប្រជុំ ដែលដឹកនាំដោយលោក នួន ជា ហ្នឹង ប៉ុន្មានដងដែរ? លោកអាចនៅចាំបានទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា ខ្ញុំមានក៏តិចតួចដែរ។ វាអត់មានជាការងារប្រជុំធំដុំអី អត់ទេ។ បើគ្រាន់ថាគ្រាន់តែជួបណែនាំអីចេះចុះ ដូចថាជាគ្រើនរំឭករបស់គាត់អីហ្នឹង អាហ្នឹង ទៅជាប្រជុំទ្រង់ទ្រាយអី ថាជាវេទិកាអីធំដុំ ដូចអត់។ គាត់ច្រើនណែនាំត្រង់ៗ ជួបនិយាយផ្ទាល់ៗ។ នេះ សូមមានមតិប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ នៅក្នុងកិច្ចសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតជាមួយលោក គឺលោកបានលើកឡើងថា “នៅពេលលោក នួន ជា ចូលមក គេបានណែនាំឲ្យឈប់និយាយពីរឿងប្រជាជន ១៧ មេសា ឬក៏ប្រជាជនថ្មី និងប្រជាជនចាស់”។ ហ្នឹងនៅក្នុងឯកសារលេខ E3/438

ត្រង់ ERN ជាភាសាខ្មែរ គឺ 00373436, ជាសាភាអង់គ្លេស 00375875 ហើយជាភាសាបារាំង គឺ 00426433។ លោកបានដឹងអំពីមូលហេតុអ្វីទេ ដែលធ្វើឲ្យគេហាមមិនឲ្យធ្វើការបែងចែករវាងប្រជាជនចាស់និងប្រជាជនថ្មី បែបនេះ?

**ឆ៖** ខ្ញុំសូមឆ្លើយថា រឿងនេះ ខ្ញុំមិនបានវិភាគថា យ៉ាងម៉េចៗអីទេ គ្រាន់តែថា រយៈពេលហ្នឹងគឺគាត់បាន ដូចថា បញ្ជាក់ថា ឥឡូវហ្នឹង កុំឲ្យនិយាយពីរឿងប្រជាជននេះ ប្រជាជន១៧ មេសា ហើយប្រជាជននេះ ជាប្រជាជនថ្មី ហើយអ្នកដែលនៅមូលដ្ឋាននោះ ថាជាប្រជាជនចាស់ អីយ៉ាងនេះ យ៉ាងនោះ គឺថា ដូចថា កាត់បន្ថយ និងលុបបំបាត់ភាសានេះ។ បាទ នេះដឹងបានប៉ុណ្ណឹង តែមូលហេតុ និងទិសដៅ ថាលោកនិយាយអ៊ីចឹង ថាឲ្យដឹងយល់យ៉ាងម៉េចទៀត គឺខ្ញុំអត់ដឹងទេ។

[១១:១៨:៥៤]

**សៈ** បាទ អរគុណ។ ហើយនៅក្នុងចម្លើយរបស់លោកទៅនឹងឯកសារ E3/438 ផងដែរ គឺត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺ 00373435, និងជាភាសាអង់គ្លេស ត្រង់ទំព័រ 00375875, ជាភាសាបារាំង គឺ 00426432។ លោកបានលើកឡើងអំពីកាលណោះ ថា "កាលណោះ មានលើកទ្រឹស្តីមួយថាគឺធ្វើម៉េច ឲ្យតែបានស្អាត កុំឲ្យមានជនក្បត់នៅក្នុងជួរ"។ តើលោកចាំទេ ថានរណាជាអ្នកណែនាំអំពីទ្រឹស្តីហ្នឹង?

**ឆ៖** សំណួរនេះ តាមដែលខ្ញុំចាំបាន គឺជំនាន់ដែលចាប់ ហ៊ូ នឹម ហើយ យុន យ៉ាត មកទទួល។ នេះ សូមផ្តល់មតិប៉ុណ្ណឹងបាទ។

[១១:២០:០៣]

**សៈ** បាទអរគុណ។ ចុះនៅៗក្នុងការជួបប្រជុំជាមួយលោក នួន ជា តើគាត់បានលើកឡើងអំពីបញ្ហាដែលទាក់ទងទៅនឹងជនក្បត់ ឬក៏សត្រូវនោះដែរទេ?

**ឆ៖** សំណួរនេះខ្ញុំ ដូចជាចាំមិនបានទេ។ មិនដឹងជាគាត់បាននិយាយដែរ ឬមួយក៏ ខ្ញុំមានការភ្លេចភ្លាំង ឬមួយក៏គាត់អត់និយាយ អាហ្នឹងខ្ញុំ ដូចថា ខ្លួនឯងហ្នឹងវារកនឹកអត់ឃើញ ឬការចងចាំខ្ញុំវាបាត់បង់ក៏មិនដឹង។ ខ្ញុំៗគិតទៅវិញ ដូចជាមិនៗបាននិយាយអីច្រើននឹងៗសំណួរហ្នឹង ដែលថាឲ្យខ្ញុំថា អ្អេ! សង្ស័យគាត់និយាយឬអត់ទេ។ ខ្ញុំភ្លេចក៏មិនដឹង អីមិនដឹង។ អ៊ីចឹងបានថា សំណួរនេះដូចថា ខ្ញុំឆ្លើយអត់កើត ត្រង់ថា ខ្ញុំមិនចាំ។ បាទវាដូចបាត់ការចងចាំអស់មួយចំនួនដែរហើយ។

[១១:២១:២៣]

**ស៖** បាទ។ ចុះទាក់ទងទៅនឹងការរៀនសូត្រ ឬក៏ការប្រជុំនៅក្រៅក្រសួងឃោសនាការវិញ តើលោកធ្លាប់បានចូលរួមដែរទេ?

**ឆ៖** នៅក្រៅពីក្រសួងដែលខ្លួនធ្វើការ ខ្ញុំមិនដែលបានចូលរួមទៅរៀនសូត្រ ឬក៏ប្រជុំអីជាមួយគេទេ។ សូមអស់។

**ស៖** ចុះទាក់ទងទៅនឹងការប្រជុំទិតៀន ឬក៏ស្វ័យទិតៀនវិញម្តង។ នៅក្នុងក្រសួងឃោសនាការហ្នឹង តើឧស្សាហ៍មានការធ្វើប្រជុំស្វ័យទិតៀន ឬក៏ទិតៀនហ្នឹងដែរទេ?

**ឆ៖** ខ្ញុំឆ្លើយមតិនេះគឺថា សម័យនុ៎ងគឺថាប្រជុំវា ចង់និយាយថា គេចែក មានប្រជុំប្រចាំថ្ងៃ ប្រជុំឬមួយ១០ថ្ងៃម្តង។ តែដល់ប្រជុំ១០ថ្ងៃម្តងហ្នឹង អាហ្នឹងច្រើនធ្វើការទិតៀន ស្វ័យទិតៀនគ្នា។ តែដល់អាប្រជុំប្រចាំថ្ងៃហ្នឹង អាហ្នឹងនិយាយពីការងារដែលធ្វើប្រចាំថ្ងៃហ្នឹង។ នេះសូមជូនមតិប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំទេថា ការប្រជុំប្រចាំថ្ងៃហ្នឹងមានអ្នកណាចូលរួមខ្លះ? ហើយនរណាជាអ្នកដឹកនាំការប្រជុំប្រចាំថ្ងៃនុ៎ង?

**ឆ៖** ការប្រជុំប្រចាំថ្ងៃហ្នឹងគឺមានត្រឹមថ្នាក់ប្រធានមន្ទីរហ្នឹងទេ ដែលជាអ្នកប្រជុំ។ ឯប្រជុំដោយៗប្រជុំពិនិត្យពីការងារប្រចាំថ្ងៃហ្នឹងធ្វើអី បានប៉ុន្មានអីប៉ុន្មាន ដើម្បីរាយការណ៍ជូនអង្គប្រជុំ។ តែដល់១០ថ្ងៃនុ៎ង ប្រជុំរបៀបធ្វើការស្វ័យទិតៀនគ្នាទៅវិញទៅមក។

**ស៖** បាទ អរគុណ។ ទាក់ទងនឹងការប្រជុំស្វ័យទិតៀន ដែលធ្វើ១០ថ្ងៃម្តងហ្នឹង តើនរណា ជាទូទៅនរណាគេជាអ្នកដឹកនាំការប្រជុំហ្នឹង?

[១១:២៤:១៨]

**ឆ៖** ប្រជុំធ្វើការស្វ័យទិតៀននេះគឺថា ជាៗប្រចាំដែលធ្វើជាទូទៅ គឺប្រធានក្រុម។ ឧបមាខ្លះហៅក្រុម តែខ្លះហៅផ្នែក។ ដូចខ្ញុំផ្នែកខាងទូរពុម្ពទទួលហ្នឹង អាហ្នឹងប្រជុំខាងហ្នឹង ទិតៀនគ្នាខាងហ្នឹងទៅ។ អីចឹង។ ដល់ផ្នែកគេទៀត គេប្រជុំផ្នែកគេ គេទិតៀនផ្នែកគេទៅ។ នេះជាកិច្ចដំណើរការពេលនោះ គឺវាៗមានសភាពអ៊ីចឹង។

**ស៖** បាទ អរគុណ។ តើលោកបានដឹងទេ អំពីគោលបំណង ឬក៏គោលដៅនៃការធ្វើការប្រជុំស្វ័យទិតៀនគ្នាហ្នឹង តើគេធ្វើដើម្បីអ្វីដែរ?

**ឆ៖** ខ្ញុំគ្រាន់តែយល់ខ្លួនឯងថា ការប្រជុំនេះវា -- ហើយអង្គាល់នុ៎ងក៏ខាងលើក៏បានណែនាំថា មានតែការប្រជុំទេ ដើម្បីដំណើរការការងារអីក៏ដោយវាធ្វើទៅបានផលសម្រេច បើអត់ប្រជុំគឺថាទាំង

ការងារទាំងអីវារឃើករយាក។ ដល់អ៊ីចឹងប្រជុំក្នុងគោលបំណងថា ពង្រឹងទាំងៗផ្នែកការងារ ពង្រឹងទាំងនយោបាយរបស់យើងហ្នឹងឲ្យៗគឺថា សម្រួចនឹងការងារ សម្រួចជាមួយនឹងភារកិច្ចដែលយើងធ្វើកន្លងមក។

**ស៖** បាទអរគុណ។ ចុះនៅក្នុងកិច្ចប្រជុំស្វ័យទិតៀនទុំង តើធ្លាប់មាននរណាខ្លះដែលបានសារភាពអំពីការខ្វះខាតរបស់ខ្លួនដែរទេ? ហើយបើសិនជាមានតើគេមានវិធានការយ៉ាងម៉េចខ្លះចំពោះគាត់?

[១១:២៦:២៤]

**ឆ៖** ខ្ញុំសូមឆ្លើយអារឿងប្រជុំទិតៀន ស្វ័យទិតៀន។ ការប្រជុំនេះមែនទែនវាជាការលាងសម្អាតខ្លួនឯងហើយ អាស្អីដែលខ្លួនឯងមានហើយសារភាពប្រាប់មហាជន តែកន្លែងនេះក៏ខ្ញុំទទួលស្គាល់ថាកន្លងមកដែលខាងលោកសួរហ្នឹងក៏វាមានប្រតិកម្មចៀសមិនផុតទេ ខ្លះទៅគេជួយទៅខឹងមកវិញមក ហើយខ្លះទៅគាត់ទទួលស្គាល់ថា ការជួយហ្នឹងវាត្រឹមត្រូវ ហើយយកទៅកែលម្អទៅ។ ដោយមានទ្រឹស្ដីមួយថា ខ្លួនឯងមិនអាចមើលឃើញកំហុសខ្លួនឯងបានទេ ទាល់តែគេជួយមើល ដល់អ៊ីចឹងក៏លើកទ្រឹស្ដីហ្នឹងថា ត្រូវតែប្រជុំហើយទិតៀនគ្នា។ នេះដែលគោលបំណង និងទិសដៅប្រជុំមកគឺថា យើងដាក់ខ្លួនឲ្យគេទិតៀនយើង យើងមានសិទ្ធិទិតៀនគេ អ៊ីចេះបាទ។ ដល់អ៊ីចឹងហៅថា ទម្លាក់ដាក់ខ្លួនឲ្យ -- ផ្ដល់សិទ្ធិឲ្យគ្នាទៅវិញទៅមកសម្រាប់ធ្វើការទិតៀនគ្នា។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១១:២៧:៣៣]

**ស៖** បាទ អរគុណ។ លោកបានជម្រាបជូនអង្គសវនាការថា នៅពេលមានការសារភាពអំពីកំហុស ហើយធ្វើដើម្បីឲ្យគេកែលម្អ។ តើការកែលម្អហ្នឹង គេកែលម្អដោយវិធីណាខ្លះលោកនៅចាំបានទេ?

**ឆ៖** ខ្ញុំគ្រាន់តែសុំឆ្លើយថា កំហុសដែលធំៗខ្ញុំមិនអាចដឹង មិនអាចយល់បានទេ តែក្នុងការរស់នៅដែលធ្វើការជាមួយគ្នា ធ្វើអីខុសធ្វើអីត្រូវយើងឃើញគ្នា យើងនិយាយ ដល់និយាយខាងណោះទទួលទៅ។ ឧបមាថា យើងធ្វើនេះគេមិនឲ្យធ្វើយើងទៅធ្វើ ហើយជំនាន់នុំងគេថា ដល់ៗធ្វើខុសពីការណែនាំអានេះសេរីហើយ ដល់ក្នុងន័យនេះហើយដែលគេថា ដែលយើងត្រូវទិតៀនថា កុំធ្វើអ៊ីចឹងវាខុស។ ព្រោះន័យហ្នឹងគេហាមថា មិនឲ្យធ្វើ ដល់យើងធ្វើអ៊ីចឹង វាទៅជាភាពសេរីមួយដែលយើងយកមកវិភាគខ្លួនយើងបាត់វិន័យ ការទទួលការណែនាំ ការដឹកនាំហើយ គឺថាយើងបាត់អាហ្នឹងអស់។ ដល់អ៊ីចឹងយើងត្រូវតែធ្វើតាមដែលអីគេតម្រែតម្រង់ហើយ នេះក្នុងន័យដែលៗ ខ្ញុំបញ្ជាក់ហ្នឹងក្នុងន័យស្វ័យទិតៀន គឺក្នុង

ន័យថា ពង្រឹងអាកម្លាំងហ្នឹងឲ្យវា ស្អីដែលគេប្រាប់ថាកុំឲ្យធ្វើហើយ បើធ្វើខុសគេថា សេរី។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹង។

[១១:២៨:៥៩]

**សះ** បាទអរគុណ។ ចុះចំពោះអ្នកដែលថាធ្វើខុសពីការណែនាំ ហើយត្រូវបានគេថាជាអ្នកសេរី តើបន្ទាប់មកទៀតអ្នកដែលសេរីនុ៎ង គេៗមានវិធានការយ៉ាងម៉េចខ្លះចំពោះគាត់ដែរ?

**ផះ** ខ្ញុំសូមឆ្លើយថា ដែលខ្ញុំធ្លាប់បាននៅ ខ្ញុំឃើញថា អ្នកដែលគោរពក៏ចេះតែគោរពទៅ តែអ្នកខ្លះដែលមិនគោរពក៏ កន្លែងខ្លះចេះតែសេរីច្រើនទៅ តែយូរទៅអាការងារហ្នឹងវាដើរទៅគេប្រើអ្នកហ្នឹងវិញសម្រាប់ការងារហ្នឹងទៅ។ នេះកន្លែងជាក់ស្ដែងខ្ញុំទេ ខ្ញុំនិយាយត្រង់បាទ។ តែអាភាសាដែលថាពង្រឹងគ្នាហ្នឹងនៅតែពង្រឹងអ៊ីចឹង តែជួនអាហ្នឹងឯងវាអត់ស្ដាប់ទេ ចេះតែទៅ ដល់ទៅជួនវាទាញមកមកបើចេះអាហ្នឹងហើយ ប្រើអ្វែងឲ្យធ្វើអាហ្នឹងបណ្ដោយ។ នេះកន្លងមកកន្លែងខ្ញុំមានអ៊ីចឹងដែលខ្ញុំនិយាយលើក តែកន្លែងផ្សេងទៀត ខ្ញុំអត់ដឹងអត់យល់ អាហ្នឹងរឿងផ្សេង។ តែបើសេរីអីដែលធំដុំអីទៀត ខ្ញុំអត់ដឹង ដូចថាអាហ្នឹងទៅបង្កើតរឿងអីធំដុំទៀត ខ្ញុំអត់ទេ ប៉ុន្តែក្របខ័ណ្ឌដែលខ្ញុំនិយាយថាសេរីអីប្រជុំកសាងគ្នាក្នុងផ្ទៃក្នុងអង្គភាពយើងហ្នឹង ជួយគ្នាទៅវិញទៅមកបាទ។ ហ្នឹងសូមមានមតិប៉ុណ្ណឹង។

**សះ** ចំណុចមួយទៀតដែរ លោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញថា នៅពេលដែលមានអ្នកដែលលើកឡើងអំពីការខ្វះខាតរបស់ខ្លួន ហើយបានសារភាពប្រាប់មហាជន តើមហាជនដែលលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញនេះ ចង់សំដៅទៅលើយ៉ាងម៉េចដែរ មហាជនហ្នឹង?

[១១:៣១:០៦]

**ផះ** និយាយចង់សួរបញ្ជាក់ពីមហាជន។ នេះខ្ញុំគ្រាន់តែចង់បញ្ជាក់ន័យហ្នឹងបាទ ន័យហ្នឹងកន្លងមកដែលៗខ្ញុំធ្លាប់ឆ្លងកាត់មកគឺដូចថាប្រព័ន្ធរបស់ -- សម័យហ្នឹងគឺថាមានបក្ស។ បាទ ក្នុងឯកសារហ្នឹងក៏ខ្ញុំមាននិយាយហើយដែរ។ មានបក្ស ហើយនិងហៅថា សម្ព័ន្ធយុវកក។ តែដូចខ្ញុំគឺថា ជាៗមហាជនធម្មតា មិនទាន់ចូលទៅក្នុងមនុស្សដែលគេរៀបចំទៅជាៗកម្លាំង ដែលត្រូវប្រឈមមុខនឹងៗការដឹកនាំអីច្រើនទេ។ ហើយដល់អ៊ីចឹងក្នុងន័យមហាជន គឺមនុស្សដែលគេមិនទាន់ចាប់បញ្ចូលទៅក្នុងក្របខ័ណ្ឌរបស់ផ្ទៃក្នុង។

**សះ** បាទ អរគុណ។ នៅក្នុងការឆ្លើយរបស់លោកជូនដល់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរ គឺលោកបានឆ្លើយថា “ជារៀងរាល់ខែគេបានបញ្ជូនទស្សនាវដ្ដីទាំងនេះមក

កន្លែងលោកដើម្បីចែកគ្នាមើល" ឯកសារនោះគឺ E3/438 ត្រង់ ERN ជាភាសាខ្មែរគឺ 00373435, និងជាភាសាអង់គ្លេសគឺ 00375875, និងជាភាសាបារាំងគឺ 00426432។ តើការដែលគេយកឯកសារទស្សនាវដ្ដីហ្នឹងឲ្យ -- មកឲ្យលោកចែកគ្នាមើលក្នុងគោលបំណងអ្វីដែរ លោកដឹងដែរទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា ការពិតឯកសារនេះដែលបានបញ្ជូនមក ដូចខ្ញុំឆ្លើយនៅក្នុងចម្លើយឲ្យ ពេលមុនអ៊ីចឹង តែគ្រាន់តែពីរឿងគោលបំណងអីយ៉ាងម៉េចៗ ខ្ញុំមិនសូវយល់ដឹងទេ ព្រោះមែនទែនខ្ញុំ -- ក្នុងការយកឯកសារហ្នឹងមកមើលដូចជាអត់សូវមានពេលទេ ដូចដែលខ្ញុំដឹងខ្លួនខ្ញុំ ព្រោះអង្គាល់ហ្នឹងខ្ញុំប្រឹងតែការងាររបស់ខ្ញុំហ្នឹង ហើយវា -- ដូចថាបំពេញជូនកុំឲ្យគេៗមកៗគិតពីរឿងយើងដែលត្រូវទទួលការងារហ្នឹង។ ដល់អ៊ីចឹងប្រឹងធ្វើរបស់ឯងដែលៗត្រូវទទួលហ្នឹង។ ដល់អ៊ីចឹងគ្រាន់ដឹងថាឯកសារហ្នឹងមានចេញចូលយកមកទុកនៅកន្លែងខ្ញុំ។ កន្លែងឯអង្គភាពហ្នឹង តែដែលខ្ញុំឲ្យទៅស្វះស្វែងមើលអាអស់ហ្នឹង ខ្ញុំអត់ គិតតែបច្ចេកវិទ្យាជំនាញដែលយើងត្រូវទទួលនេះ។ នេះសូមមានមតិប៉ុណ្ណឹង។

[១១:៣៤:២២]

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងចំណុចមួយទៀត គឺលោកក៏បានឆ្លើយនៅក្នុងបទសម្ភាសរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ លោកបានលើកឡើងថា "មន្ទីរ៨៨០ គឺជាមន្ទីររបស់ -- ៨៧០ សូមកែតម្រូវ មន្ទីរ៨៧០ គឺជាមន្ទីររបស់មជ្ឈិមដែលជាទីកន្លែងរបស់ថ្នាក់ដឹកនាំកំពូលធ្វើការ" គឺនៅក្នុងឯកសារ E3/438 ត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺ 00373435, និងជាភាសាអង់គ្លេស គឺ 00375875, ហើយជាភាសាបារាំងគឺ 00426432។ សំណួររបស់ខ្ញុំគឺចង់ដឹងថា តើលោកដឹងថាមន្ទីរ៨៧០ នេះជាមន្ទីររបស់មជ្ឈិម ហើយជាកន្លែងរបស់ថ្នាក់ដឹកនាំកំពូលធ្វើការហ្នឹង លោកដឹងដោយរបៀបណាដែរ?

**ឆ៖** សំណួរនេះ ខ្ញុំបានឆ្លើយម្ដងហើយ ហើយក៏បើមិនអស់លោកនៅនេះទេ ខ្ញុំបញ្ជាក់ជូនទៅថាខ្ញុំដឹងបានដោយសារមិត្តភក្ដិទេ ហើយពីរឿងទីតាំងមន្ទីរហ្នឹងនៅត្រង់ណាអីត្រង់ណា គឺខ្ញុំអត់ដឹងទេ គ្រាន់តែឮៗឈ្មោះហ្នឹង ហើយដល់នេះទៅសួរគេថា ៨៧០ នៅណា អីណា? គេក៏មិនមាត់មិនក ហើយយើងហ្នឹងក៏ថាអត់ថាអី។ ចុះមន្ទីរ៨៧០ ហ្នឹងកន្លែង -- កន្លែងថ្នាក់ដឹកនាំ។ ដល់អ៊ីចឹងយើងគ្រាន់តែដឹងបានប៉ុណ្ណឹងទេបាទ។

[១១:៣៦:១០]

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។ ឥឡូវ ខ្ញុំអស់សំណួរទៅលោកសាក្សីហើយ ហើយសូមអរគុណលោកសាក្សីដែលបានឆ្លើយនឹងសំណួរ។ ហើយលោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយជាបន្តសុំឲ្យសហការីខ្ញុំបន្តសំណួរតទៀតបាទ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ អរុណសួស្ដីលោក ខៀវ អេន ខ្ញុំឈ្មោះ ឌេល លីសាក់ ខ្ញុំក៏ជាតំណាងខាង -- ជាមន្ត្រីតំណាងសហព្រះរាជអាជ្ញាផងដែរ។ ខ្ញុំមានសំណួរមួយចំនួនតូចចង់សួរទៅកាន់លោកនៅក្នុងព្រឹកនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជាដំបូង ខ្ញុំសូមឲ្យលោកគិតអំឡុងឆ្នាំ៧៤ ត្រឡប់ក្រោយវិញ នៅពេលដែលលោកជាទាហាននៅស្រុកកំពង់លែង នៅពេលនោះ តើលោកដឹងអំពីការវាយសមរភូមិ ចាប់យកឧដុង្គដោយកងកម្លាំងបដិវត្តន៍ដែរឬទេ?

**លោក ខៀវ អេន៖**

**ឆ៖** កាលឆ្នាំ៧៤ ខាងលោកសួរមកនេះ ខ្ញុំហាក់ដូចថាសំណួរនេះសួរបកក្រោយទៅវិញ គឺថាពេលហ្នឹង ខ្ញុំបានដឹង តែដឹងហ្នឹងក្នុងន័យថាវាមិនដូចជាប្រព័ន្ធឥឡូវទេ។ ប្រព័ន្ធឥឡូវដែលវាងាយថាឲ្យដឹងឲ្យឮភ្លាមៗ ដែលខ្ញុំក៏មកនៅក្នុងព្រៃ នៅហ្នឹងនេះហ្នឹង គ្រាន់តែឮតាមសម័យហ្នឹងគេហៅថានីរសារ១គឺបញ្ជាក់ឲ្យពីមួយទៅមួយ១មាត់ហ្នឹង។ ហើយដល់អីចឹងក៏ឮតាមហ្នឹងថា ឧដុង្គគេវ៉ៃឈ្នះហើយ។ នេះន័យដែលដឹង ដឹងតែប៉ុណ្ណឹងទេ ថាឧដុង្គវ៉ៃដល់ឧដុង្គ ឥឡូវយកឧដុង្គបានហើយ អានេះបានតែប៉ុណ្ណឹងទេ។ ចៀសពីហ្នឹងឲ្យយល់អីពីរឿងថា ការងារវាយ៉ាងម៉េចទេ ខ្ញុំអត់បានដឹង បានយល់ទេបាទ។

[១១:៣៨:២៨]

**ស៖** តើលោកបានដឹងថាមានអ្វីកើតឡើងចំពោះអ្នកស្រុកនៅឧដុង្គដែរឬទេ ក្រោយពីកងកម្លាំងបដិវត្តន៍បានវាយដណ្ដើមយកឧដុង្គនៅក្នុងឆ្នាំ១៩៧៤នោះ?

**ឆ៖** កងកម្លាំងបដិវត្តន៍ដែលវាយយកនៅឧដុង្គនោះ ខ្ញុំ -- ការពិតខ្ញុំអត់មានបានដឹងអីទាំងអស់ព្រោះថាវាបើគិតកាលនោះ ថាសមរភូមិដោយឡែក ខ្ញុំនៅតែស្រុកនោះ ហើយឧដុង្គនៅណេះ ខ្ញុំអត់ដឹងអី

ទាំងអស់។ គ្រាន់តែគេប្រាប់តែពីរឿងជ័យជម្នះប៉ុណ្ណឹង។ ហ្នឹងសូមអស់មតិ។

**ស៖** សូមអរគុណ លោកសាក្សី។ នៅពេលនេះ ខ្ញុំសូមសួរទៅលើប្រធានបទមួយទៀត ដែលលោកបានឆ្លើយជូនសហសេវិករបស់ខ្ញុំកាលពីព្រឹកមិញ លោកបានបញ្ជាក់ថា មានជនដែលត្រូវគេភៀសខ្លួននេះ គឺភៀសពីកំពង់ឆ្នាំង ហើយមកដល់ភូមិកំណើតរបស់លោក គឺឃុំរបស់លោក។ តើលោក -- បើអាចជម្រាបជូនយើងខ្ញុំដែរឬទេ ថាអ្នកទាំងអស់នោះទៅដល់ក្នុងឆ្នាំណាដែរ? ហើយតើគេមានបានធ្វើអ្វីខ្លះដើម្បីស្វែងរកមុខសញ្ញាថាតើមានជាប់នឹងរបប លន់ នល់ ដែរឬទេ? ថាពួកគាត់ហ្នឹងគឺជាទាហានរបប លន់ នល់ ឬក៏ជាខ្សែក្នុងសម័យ លន់ នល់ ដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ គឺថាការដែលជម្លៀសប្រជាជនទៅ គឺថាការពិតប្រជាជននេះជម្លៀសយកទៅប្រគល់ឲ្យឃុំនៅក្នុងសហករណ៍។ ដល់អ៊ីចឹងខ្ញុំជាៗ ផ្នែកកងទ័ព គឺថានៅដាច់ដោយឡែកទេ អត់សួរទៅជាប់ជាមួយនឹងប្រជាជនហ្នឹងទេ។ ព្រោះកាលហ្នឹងដែលអង្គភាពខ្ញុំហ្នឹង ក៏ជាអ្នកលើកទំនប់ លើកភ្លឺស្រែហ្នឹងដែរ ដល់អ៊ីចឹគេជម្លៀសទៅ គេយកទៅដាក់នៅសហករណ៍ទៅ ប្រគល់ឲ្យសហករណ៍ទៅ ឯខ្ញុំអ្នកនេះធ្វើទំនប់ប្រឡាយហ្នឹង ខ្ញុំធ្វើទំនប់ប្រឡាយតាមកងតាមអង្គភាពខ្ញុំ។ ដល់អ៊ីចឹងការងារអីខាងប្រជាជនហ្នឹង ខ្ញុំអត់សួរដឹងរឿងទេ ព្រោះតែនៅកន្លែងមូលដ្ឋានភូមិឃុំតាមសហករណ៍ហើយ ខ្ញុំអត់បានដឹងទេបាទ។ សូមអស់មតិ។

[១១:៤១:២៧]

**ស៖** នៅពេលនេះខ្ញុំសូមសួរអំពីអំឡុងពេល ដែលលោកធ្វើការងារនៅក្រសួងឃោសនាការ។ លោកបានប្រាប់សហព្រះរាជអាជ្ញាថា "នៅពេលនោះព័ត៌មានលេចចេញពីម៉ាស៊ីនមក ហើយលោកបានយកព័ត៌មាននោះយកទៅឲ្យផ្នែកមួយផ្សេង"។ តើលោកយកព័ត៌មានដែលលោកយកចេញពីម៉ាស៊ីននោះយកទៅឲ្យផ្នែកណាដែរ?

**ឆ៖** ព័ត៌មានដែលខ្ញុំហែកយកទៅពីម៉ាស៊ីនទៅជូនទៅ គឺខ្ញុំគ្រាន់តែដឹងថាពេលខ្លះមានបីច្បាប់កិបវាដោយឡែកៗទៅ តែយកទៅបញ្ជូនឲ្យគេហ្នឹង គឺថាគេចាត់ចែងទៅខាងណាៗ អាហ្នឹងវារឿងរបស់គេ វាដូចថាវាហួសពីដំណាក់កាលដែលខ្ញុំត្រូវៗទទួលហើយ ដល់អ៊ីចឹងខាងគេទៀតគេចាត់ចែងទៅណាៗ ខ្ញុំអត់ដឹងទេ។ តែគ្រាន់តែដឹងថា កន្លែងហ្នឹងគឺថាជាអ្នកទទួលឯកសារពីខ្ញុំ។ នេះខ្ញុំសូមមតិប៉ុណ្ណឹង។

**ស៖** លោកក៏បានប្រាប់ផងដែរថា លោកធ្វើការនៅក្នុងការងារជាប្រធាន។ តើលោកមានទទួលការណែនាំថាត្រូវឲ្យបុគ្គលណាម្នាក់ធ្វើការគ្រប់គ្រងទៅលើម៉ាស៊ីននោះដែរឬទេ? តើលោកធ្លាប់ទទួល

បានបញ្ហាពីមេខាងលើនោះ អំពីបញ្ហាដូរពេលវេលាអ្នកណាត្រូវគ្រប់គ្រងទៅលើវេនមើលម៉ាស៊ីននេះដែរឬទេ?

[១១:៤៣:២៨]

**ឆ៖** សំណួរនេះខ្ញុំគ្រាន់តែបញ្ជាក់ថា អ្នកដែលរៀបចំពីលើខ្ញុំទៀត ជាពេលជាវេលាធ្វើការអីហ្នឹង គឺថាមានប្រធានផ្នែករបស់ខ្ញុំ ដែលខ្ញុំបញ្ជាក់ថាឈ្មោះ អុល ហ្នឹង គឺថាគាត់អ្នកទទួលពីលើខ្ញុំទៀត។ ដល់អ៊ីចឹងខ្ញុំហ្នឹងជាមនុស្សខាងបច្ចេកទេស ដែលសម្រាប់ទៅធ្វើតាមការចាត់ចែងរបស់គេ។ សូមអស់មតិបាទ។

**ស៖** តាមការដូរវេន ដែលលោកទទួលពី អុល នោះ តើត្រឹមត្រូវដែរឬទេ ដែលថាគឺគេចាត់តាំងឱ្យបុគ្គលមួយរូបហ្នឹងជាអ្នកមើលថែទាំម៉ាស៊ីននេះទាំងយប់ និងទាំងថ្ងៃ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា កាលដែលគេគ្រប់គ្រង គេណែនាំខ្ញុំឱ្យមើលការខុសត្រូវលើម៉ាស៊ីន ព្រោះសម្ភារៈអស់នេះគឺថា បើវាគាំងវាស្ទះទៅ វាប៉ះពាល់ដល់ការងារ។ ដល់អ៊ីចឹងយើងវាមានតួនាទីអី ដែលខាងបច្ចេកទេសហ្នឹង ធ្វើម៉េចរៀបរយឱ្យធានាដល់ការងារហ្នឹង។ នេះការដែលបញ្ជាក់មកពីខាងលើហ្នឹងគឺថាយើងគិតតែរឿងថាម៉េច កុំឱ្យការងារហ្នឹវាស្ទះ វាប៉ះពាល់ដល់កិច្ចការរបស់គេ។ នេះខ្ញុំមានតែមតិប៉ុណ្ណឹងបាទ។

[១១:៤៥:00]

**ស៖** សូមអរគុណ។ លោកក៏បានឆ្លើយប្រាប់ផងដែរថា នៅពេលដែល នួន ជា នៅដល់ក្រសួងនោះ ពេលខ្លះទៅ លោកយកព័ត៌មានហ្នឹង យកចេញពីម៉ាស៊ីននោះ យកទៅឱ្យគាត់ផងដែរ។ តើព័ត៌មានដែលលោកយកចេញពីម៉ាស៊ីននោះ ទៅឱ្យ នួន ជា ហ្នឹង គឺជាព័ត៌មានចេញពីម៉ាស៊ីន ឬក៏ជាព័ត៌មានអ្វីផ្សេង?

**ឆ៖** ខ្ញុំសូមឆ្លើយថា ឯកសារដែលខ្ញុំបញ្ជូនទៅឱ្យអ្នកផ្នែកផ្សេងពីខ្ញុំនោះ គឺថាវាអត់មានឯកសារអី ដែលក្រៅពីយកពីម៉ាស៊ីនហ្នឹងទេ ព្រោះខ្ញុំការងារវាត្រូវតែអាហ្នឹង។ ដល់អ៊ីចឹង ឱ្យមានអីផ្សេងអ៊ីចឹងវាអត់មាន។ ដូចថាដឹងតែថា ឯកសារហ្នឹងចប់ ហែកយកទៅប្រគល់ឱ្យគេ។ នេះ សូមមានមតិប៉ុណ្ណឹង។

**ស៖** សំណួររបស់ខ្ញុំនោះគឺថា ឯកសារដែលលោកយកទៅឱ្យផ្នែកផ្សេងនោះ គឺឯកសារហ្នឹង ក៏ជាឯកសារដែលលោកយកទៅឱ្យ នួន ជា ផងដែរ នៅពេលដែលគាត់ការនៅក្រសួងនុ៎ង តើអ៊ីចឹងដែរឬទេ?

[១១:៤៦:៥៦]

**ឆ៖** ឯកសារដែលខ្ញុំយកទៅ ខ្ញុំគ្រាន់តែបញ្ជាក់ជូនថា ជូនដល់លោក នួន ជា គឺថាមានតិចតួចណាស់ ហ្នឹងនិយាយ ខ្ញុំមិនបដិសធថា អត់ទេ។ ខ្ញុំដឹងថាមានជូន តែជាៗដំណើរការធម្មតា និងការរៀបរយ គឺថាមានកន្លែងគេអ្នកទទួលដោយឡែក។ៗ តែកន្លែងខ្លះទៅអត់ជួប កន្លែងខ្លះក៏ជួបគាត់ គាត់ ជូនគាត់។ អានេះ ក្នុងសភាពដែលខ្ញុំនិយាយអំមិញនេះ គឺថាមានជូនគាត់ខ្លះ តែមានតិចតួចទេ ព្រោះមានកន្លែងគេទទួលអាឯកសារហ្នឹង ដែលពីខ្ញុំយកទៅហ្នឹង វាមានដោយឡែករបស់គេ មានផ្នែករបស់គេ។ នេះ សូមមតិប៉ុណ្ណឹង។

**សះ** នៅក្នុងពេលដែលយកឯកសារហ្នឹង ទៅឱ្យ នួន ជា តើអ្នកណាគេជាអ្នកណែនាំលោកហ្នឹង ឲ្យយកឯកសារតិចតួចហ្នឹង ទៅឲ្យ នួន ជា នោះ?

**ឆ៖** ខ្ញុំ កន្លែងហ្នឹងខ្ញុំដូចថា ខ្ញុំគ្រាន់តែបញ្ជាក់បន្ថែមថា កន្លែងខ្លះមិនមានអ្នកណាណែនាំទេ តែដល់ពេលឡើងទៅជួនទៅជួបគាត់ ក៏ជូនគាត់ផ្ទាល់ទៅ តែពេលវេលាខ្លះ មានអ្នកនៅចាំទទួល អ៊ីចេះ។ ដល់ពេលមានអ្នកចាំទទួល យើងក៏ជូនទៅអ្នកដែលចាំទទួលហ្នឹងទៅ ឲ្យគេបញ្ជូនបន្តទៀតទៅ។ នេះ ខ្ញុំ -- អ៊ីចឹងបានថា អត់អ្នកចាំទទួលហ្នឹងវាតិចណាស់។ អ៊ីចឹងបានភាគច្រើនសុទ្ធតែមានគេនៅចាំទទួលហ្នឹង ហើយគេចាត់ចែងយ៉ាងម៉េច អាហ្នឹង ខ្ញុំអត់ដឹងទេ។ តែគ្រាន់ថា មានអ្នកនៅប្រចាំ ចាំទទួល តែបើក្នុងករណី ដែលមានតិចតួច ដែលខ្ញុំជូនផ្ទាល់។ នេះសូមមានមតិប៉ុណ្ណឹងបាទ។

[១១:៤៩:១០]

**សះ** សូមអរគុណ ដែលលោកបញ្ជាក់ជូនយើងខ្ញុំ។ សំណួរចុងក្រោយរបស់ខ្ញុំនេះ សូមឲ្យលោកជម្រាបយើងខ្ញុំ ក្នុងអំឡុងឆ្នាំណាដែរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ ដែលលោក នួន ជា មកអើតនៅក្រសួងឃោសនាការនោះ?

**ឆ៖** ខ្ញុំសូមឆ្លើយ នួន ជា ដែលគាត់បានមកទទួលនៅមន្ទីរ ក-៣៣ នេះ អាថ្ងៃខែដែល អំ ឆ្នាំខ្ញុំនិយាយក្នុងនោះក៏មាន តែខ្ញុំគ្រាន់តែនៅចាំថា គាត់មកទទួលពេលចុងក្រោយ ដែលពេលវៀតណាមចូល។ ព្រោះចង់និយាយថា ចន្លោះពីចាប់ ហ៊ូ នឹម ហើយ យុន យ៉ាត មកទទួល ហើយដល់ផុតពី យុន យ៉ាត ហើយ បាននួន ជា បន្តរហូតដល់ពេលដែល៧៩ រត់ រត់ចេញពីភ្នំ -- ដកខ្លួនចេញពីភ្នំពេញ។ ដល់អ៊ីចឹងខ្ញុំកំណត់ថ្ងៃអីហ្នឹង កំណត់អត់កើតទេ តែគ្រាន់តែខ្ញុំចាំបានប៉ុណ្ណឹង។ គ្រាន់ថា ចន្លោះ។ពី ហ៊ូ នឹម មកគឺ យុន យ៉ាត ហើយដល់ចាប់ ហ៊ូ នឹម ៧៧ ប្រហែលជាចុងឆ្នាំ ហើយដល់មក យុន យ៉ាត

ទទួលមក ដល់អ៊ីចឹងផុតពីហ្នឹងមកបានខាង នួន ជា គាត់មកទទួលបន្ត រហូតដល់ដកខ្លួនចេញចុងក្រោយហ្នឹង។ សូមអស់មតិបាទ។

**ស៖** សូមអរគុណច្រើន ដែលលោកបានឆ្លើយនៅព្រឹកនេះ។ ក្នុងនាមជាការិយាល័យសហព្រះរាជអាជ្ញា យើងខ្ញុំសូមថ្លែងអំណរគុណ ដែលលោកបានឆ្លើយជូនយើងខ្ញុំនៅក្នុងព្រឹកនេះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងខ្ញុំពុំមានសំណួរទៀតនោះទេ។ សូមអរគុណ។

[១១:៥១:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជន មេធាវីនាំមុខប្រគល់សិទ្ធិជូនលោក ឡោ ជុនធី និងលោកស្រីមេធាវី បេនី យេ ដើម្បីសួរសំណួរទៅលើសាក្សីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទ ខ្ញុំបាទសូមគោរពអង្គជំនុំជម្រះ! សូមគោរពលោកប្រធាន! ហើយសូមគោរពសហភាតាទាំងអស់! ហើយសូមគោរពបងប្អូនដែលអញ្ជើញចូលរួមនៅទីនេះ! ហើយអ្នកដែលតាមដាននៅតាមប្រព័ន្ធអេឡិចត្រូនិចផងដែរ។

[១១:៥២:៤៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំបាទឡោ ជុនធី ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមជម្រាបសួរលោក ខៀវ អេន។ ខ្ញុំនៅពេលនេះ ខ្ញុំនឹងសួរលោកបរិបទមួយចំនួន ដែលលោកបានជួបប្រទះកន្លងមក។ ជាដំបូង

ដែលខ្ញុំចង់ជម្រាបសួរលោកនោះគឺថា ពាក់ព័ន្ធនឹងរឿងការដែលជម្លៀសចេញ -- របបខ្មែរក្រហមបាន ជម្លៀសប្រជាជនចេញពីទីក្រុង និងប្រជុំជន។ អម្បាញ់មិញខាងសហព្រះរាជអាជ្ញាបានជម្រាបសួរ លោកហើយនៅចំណុចនេះ ប៉ុន្តែមិនទាន់បានច្បាស់ថា តើលោកបានដឹងច្បាស់ដែរឬទេ អំពីថា អ្វីទៅ ដែលជាបញ្ហាសំខាន់ ដែលខាងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង បានជម្លៀសប្រជាជនចេញពីទីក្រុង ភ្នំពេញជាពិសេសបាទ?

[១១:៥៤:២១]

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ កាលខ្ញុំអត់ដឹងថា មានទិសដៅដកប្រជាជនចេញពីភ្នំពេញអី ដែលជាន័យវាឲ្យជ្រាលជ្រៅនៅក្នុងរឿងហ្នឹង ខ្ញុំមិនបានដឹងទេ។ ព្រោះខ្ញុំ ដូចខ្ញុំបញ្ជាក់នឹងសំណួរសួរមុន ថា ពេលដែលចប់ ពេលហ្នឹងគឺថាខ្ញុំនៅតាមទន្លេ ខ្ញុំនៅតាមអីឯនោះឯឡើយ ខ្ញុំមិនដឹងរឿងថា អ៊ូ! គេ ឈ្នះហើយ ឈ្នះភ្នំពេញហើយ អីហើយ ហើយជម្លៀសអីហ្នឹង អត់។ ខ្ញុំនៅទាល់តែគេប្រើថា អ្នក ឥឡូវ ឈ្នះភ្នំពេញហើយ បានទៅហៅមកហ្នឹង ក៏ -- ឯបញ្ហាជម្លៀសអីទៀតនេះ ក៏គ្រាន់តែដឹងថា ជម្លៀសតែ ដែលជាទិសដៅថា អូ! វាម៉េចបានគេជម្លៀសអី ការពិតអត់ដឹងទេ។ អត់ដឹងយើងអត់ដឹង។ ហើយ គ្រាន់តែដឹងថា ខាងខ្ញុំនុះ គេយកប្រជាជនចេញពីខេត្តដែរ។ ដល់អ៊ីចឹងការដកចេញពីភ្នំពេញដែរ អាហ្នឹង ជារឿងរបស់គេឯណោះ ហើយដល់ខាងនុះ គេដកឯនុះ ខ្ញុំដឹងតែដកហើយយកទៅដាក់នៅសហករណ៍។ ដាក់ទៅឃុំ អាហ្នឹងខ្ញុំជូនមតិបានប៉ុណ្ណឹងបាទ។

**ស៖** អរគុណបាទ។ ចំណុចមួយទៀត ខ្ញុំមិនទាន់បានឮថា នៅពេលដែលគេបញ្ជូនលោកមក ភ្នំពេញតើលោកចូលមកដល់ភ្នំពេញប្រហែលជានៅក្នុងឆ្នាំណាដែរបាទ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ការដែលគេបញ្ជូនមកភ្នំពេញហ្នឹង ខាងលោកនៅមិនទាន់ច្បាស់ ក៏ខ្ញុំសូម បញ្ជាក់ថែមថា ព្រោះអាដំបូងអំមិញខ្ញុំក៏បញ្ជាក់ថា ខែឆ្នាំហ្នឹងខ្ញុំមិនច្បាស់ថា ចុងឆ្នាំ៧៥ ឬក៏ដើមឆ្នាំ៧៦ ខ្ញុំឲ្យពេលវេលាហ្នឹងមិនបាន តែខ្ញុំគ្រាន់តែដឹងថា ខ្ញុំមកនៅដល់ភ្នំពេញហ្នឹងនៅក្បែរៗមុខវាំងហ្នឹង ថាគឺ ថាវាមានខ្យល់ពីជើងមកធ្លាក់មក ជាខែរំហើយហើយ។ ដល់អ៊ីចឹងមិនដឹងថា ដល់អ៊ីចឹងខ្ញុំក៏កំណត់ថា បើមិនចុង៧៥ ប្រហែលជាដើមឆ្នាំ៧៦ នេះក្នុងន័យខ្ញុំបញ្ជាក់អ៊ីចឹង។ ខ្ញុំបញ្ជាក់ហ្នឹងគឺខ្ញុំចង់ ដូច្នេះថា -- តែឲ្យច្បាស់ថា អេ្ហ ៧៥ ដូចជាច្បាស់ វាអត់ច្បាស់។ ដល់អ៊ីចឹងខ្ញុំជូនបានប៉ុណ្ណឹងបាទ។

[១១:៥៦:៥៧]

**ស៖** បាទ អរគុណច្រើន។ នៅពេលដែលគេបញ្ជូនលោកមកហើយ ពេលនោះគឺលោកបានចូលធ្វើការនៅក្រសួងឃោសនាការ តើនៅពេលដែលលោកចូលធ្វើការនៅក្រសួងឃោសនាការហ្នឹង តើលោកមានបានទទួលនូវការបណ្តុះបណ្តាលអីដែរអត់ទេ?

[១១:៥៧:៣៥]

**ឆ៖** ខ្ញុំសូមឆ្លើយថា ពេលដែលខ្ញុំមកនៅក្នុងឃោសនាការហ្នឹង ខ្ញុំទទួលហៅថា វគ្គបណ្តុះបណ្តាលជាបច្ចេកទេសសុទ្ធសាធ ក្នុងន័យថា រៀនខាងជំនាញ ក្នុងនេះខ្ញុំ ជំនាន់ហ្នឹងគេហៅថា ទូរពុម្ពៗហ្នឹងគឺខ្ញុំរៀនខាងនុ៎ង ដល់រៀនវាចែកផ្នែកគ្នាទៀត។ ដូចខ្ញុំបញ្ជាក់ខាងដើមសំណួរដែលសួរហើយ គឺថាមានផ្នែកខាងអ្នកទទួល មានផ្នែកអ្នកជួសជុល។ ជួសជុលម៉ាស៊ីនអង្គុលីលេខហ្នឹង មានអ្នកវាយអក្សរអង្គុលីលេខហ្នឹង ហើយនិងខាងជួសជុលអាម៉ាស៊ីនផ្សាយ ម៉ាស៊ីនទទួលហ្នឹង។ ដល់អ៊ីចឹងវាចែកគ្នាអ៊ីចឹងដល់ខ្ញុំនេះ វាដែលចំរបស់ខ្ញុំមែនទែននោះ គឺខ្ញុំអ្នកជួសជុលអង្គុលីលេខ តែគ្រាន់តែខ្ញុំនៅផ្នែកខាងទទួល។ ទទួលអាព័ត៌មាន អាចាប់ព័ត៌មានហ្នឹងអ៊ីចេះ។ ហើយដល់វគ្គបណ្តុះបណ្តាលហ្នឹង រៀនវារយៈពេល៣ខែជាទ្រឹស្តី និង៣ខែ ជាការអនុវត្តនូវអា១ម៉ាស៊ីនហ្នឹងជាក់ស្តែង ដោយគេធ្វើកំហុសអីខ្លះទៅឲ្យយើងដោះស្រាយទៅ រៀនទ្រឹស្តីហើយហ្នឹង។ រៀនដោះស្រាយអាកំហុសអី១ហ្នឹងទៅ ដល់អ៊ីចឹងយើងគិតប្រឹងតែអារឿងហ្នឹងទេមែនទែន។ អារឿងអីទៀតមិនសូវដឹង បាទ មិនសូវដឹង មិនសូវយល់ទេ។ ដឹងថាធ្វើម៉េចឲ្យកើតអាការងារហ្នឹងសម្រាប់គេមានជំនឿថា យើងធ្វើបាននោះ បាទដល់អ៊ីចឹងប្រឹងអាហ្នឹង។ អ៊ីចឹងបានដល់ខ្ញុំបញ្ជាក់ជូនថា វគ្គបណ្តុះបណ្តាលគឺថាមានរយៈពេល៣ខែជាក់ស្តែង អ៊ំ! ៣ខែទ្រឹស្តី និង៣ខែជាក់ស្តែងលើសម្ភារៈដែលមានហ្នឹង។ នេះសូមមានមតិ។

**ស៖** ចុះផ្នែកគ្រូដែលមកបង្ហាត់បង្រៀនហ្នឹងតើគេអញ្ជើញពីខាងណាមកដែរ?

**ឆ៖** ផ្នែកគ្រូដែលមករៀបការបណ្តុះបណ្តាលដល់វគ្គខ្ញុំហ្នឹងគឺមកពីចិន មកពីប្រទេសចិនបាទ។ សូមអស់មតិហ្នឹងបាទ។

**ស៖** អ៊ីចឹង គ្រូហ្នឹងគឺមកបណ្តុះបណ្តាលក្នុងរយៈពេល៣ខែ ឬមួយ ៦ខែ?

[១២:០០:២៥]

**ឆ៖** គ្រូមកបណ្តុះបណ្តាលនោះគឺថា រយៈពេលទាំងពីរវគ្គហ្នឹង គឺថា ទាំងវគ្គបណ្តុះបណ្តាលផង ទាំងឲ្យអនុវត្តជាក់ស្តែងបង្កើតកំហុសឲ្យយើងដោះស្រាយផង វាទាំងអស់៦ខែ។ សូមអស់។

**ស៖** អរគុណ។ ចំណុចមួយទៀត ថាតើកូនសិស្សដែលអញ្ជើញមករៀននៅទីនោះ មានប៉ុន្មាន

នាក់ដែរ? ហើយអញ្ជើញពីខាងណាមកដែរបាទ?

**ឆ៖** កូនសិស្សដែលរៀនពេលហ្នឹងគឺថា វាជាវគ្គរួមគ្នា តែគ្រាន់ថាគ្រូដោយឡែកពីគ្នាតាមជំនាញ។ បាទដែលខ្ញុំបានបញ្ជាក់ក្នុងនេះគឺថា ក្នុងន័យ ដែលខ្ញុំបានជូនឲ្យសាក្សីនោះគឺ ខ្ទង់១០នាក់ឡើងលើ អាច១៥នាក់ចុះក្រោម ១០នាក់ឡើងលើ។ នៅចន្លោះហ្នឹងៗ ខ្ញុំមិនបានចាំ ហើយអ្នកដែលបាត់នេះទៅ ខ្ញុំភ្លេចឈ្មោះភ្លេចអី រាប់មើលទៅវានឹកមិនឃើញណាបាទ។ តែគឺថាចន្លោះពី១៥ មក១០នោះគឺថាមនុស្សក្នុងចន្លោះហ្នឹង។ សូមជូនមតិប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី។ ឥឡូវនេះ ដល់ពេលសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងកំណត់គឺរសៀលនេះម៉ោងមួយ និងសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១២:០២:៣០]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។

លោក នួន ជា មានការឈឺក្បាល ហើយនិងឈឺឆ្អឹងខ្នង ហើយគាត់មិនអាចផ្តង់អារម្មណ៍បានទេ។ ដូច្នេះ គាត់សុំអនុញ្ញាតទៅតាមដានសវនាការល្ងាចនេះ ពីបន្ទប់ខាងក្រោមនេះ។ ដូច្នេះសូមតុលាការអនុញ្ញាតបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព។

សំណើរបស់លោក នួន ជា ធ្វើឡើងមានលក្ខណៈសមស្រប អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១រសៀលថ្ងៃនេះ ដោយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាម នូវពាក្យសុំលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

[១២:០៣:៤៨]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយរសៀលថ្ងៃនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេច ទុកនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣១:៣៧]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការបន្តការតាំងសំណួរដេញដោល

ចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់មួយ លើសំណើ --

[១៣:៣២:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៣:៣១]

បាទ សូមអធ្យាស្រ័យដោយសារមិនទាន់បានជ្រះស្រឡះ នៅក្នុងការចេញសេចក្តីសម្រេចនេះ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចផ្អាកនូវសេចក្តី -- ប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់នេះសិន ហើយសេចក្តីសម្រេចនេះនឹងលើកទៅប្រកាសនៅពេលណាដែលការរៀបចំសេចក្តីនេះ គឺបានរួចរាល់ជាស្ថាពរទាំងស្រុង ហើយមិនមានមតិយោបល់កែលម្អលើបញ្ហានេះទៀត។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ ហើយសូមជម្រាបសួរសាជាថ្មី។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ជាបន្តនេះ ខ្ញុំបាទសូមជម្រាបសួរលោកបន្តទៀត។ កាលពីមុនសម្រាកបាយនេះ ខ្ញុំជម្រាបសួរលោកពូ ពាក់ព័ន្ធនឹងការជ្រើសរើសអ្នកដែលមករៀននេះ។ ខ្ញុំចង់ដឹងថាតើការជ្រើសរើសអ្នកដែលមករៀនហ្នឹង គឺគេផ្អែកទៅលើលក្ខខណ្ឌអីខ្លះអ្នកដែលបានអញ្ជើញមករៀនហ្នឹងបាទ។

[១៣:៣៥:០០]

**លោក ខៀវ អេន៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន សំណួរនេះចង់ ពាក់ព័ន្ធនឹងសំណួរដែលបានសួរពីពេលមុនមកថា តើការដែលរើសមករៀនហ្នឹង -- ខ្ញុំចង់បញ្ជាក់បន្ថែមបន្តិច តើរៀនហ្នឹងរៀនជាវគ្គបណ្តុះបណ្តាលក្នុងបច្ចេកទេសនោះ ឬមួយក៏រៀនអី?

**ស៖** បាទ សូមអរគុណ។ អ៊ីចេះ ខ្ញុំចង់ដឹងអ៊ីចេះ ចង់ដឹងថា តើអ្នកដែលត្រូវជ្រើសរើសមករៀនហ្នឹង គេផ្អែកទៅលើលក្ខខណ្ឌអី? ឧបមាថា បុគ្គល "ក" ត្រូវជ្រើសរើសមក។ តើគាត់ស្ថិតនៅក្នុងវណ្ណៈអីដែលគេត្រូវជ្រើសរើសគាត់មកហ្នឹង? បាទ ខ្ញុំចង់ជម្រាបសួរបញ្ហាហ្នឹងបាទ។

[១៣:៣៥:៥២]

**ធ៖** បាទ ខ្ញុំសូមគោរពលោកប្រធាន សូមឆ្លើយទៅសំណួរនេះ។ កន្លងមកដែលខ្ញុំធ្លាប់ឆ្លងកាត់ ខ្ញុំធ្លាប់ដឹងនោះគឺថា រយៈពេលហ្នឹងគឺ ភាគច្រើនដែលតម្រូវការដែលគេយកមកឲ្យធ្វើជាមនុស្សដែលដឹកនាំពេលហ្នឹងច្រើន បើនិយាយកាលនោះគេហៅថា វណ្ណភាពថ្នាក់ក្រោម។ ថ្នាក់ក្រោមហ្នឹងគឺថា អ្នក -- បើយើងនិយាយពីមុនគេថា អ្នកទ័ល អ្នកៗ គេចែកសង្គមខ្មែរកាលនោះវាខុសៗគ្នាណា។ បាទ ដល់អ៊ីចឹង គេហៅថាវណ្ណភាពថ្នាក់ក្រោម គឺអ្នកក្រ អ្នកក្រនោះច្រើនៗមានបុព្វសិទ្ធទៅលើគេពេលសម័យហ្នឹង។ ហើយដល់អ៊ីចឹង ដូចថាការចូលរៀនអីហ្នឹង ដូចខ្ញុំក៏ដោយ ដែលខ្ញុំបានមកកាន់ការងារហ្នឹង ក៏ខ្ញុំមិនដឹងថាគេរៀបចំយ៉ាងម៉េចដែរ តែគ្រាន់តែថា ហេតុអីក៏គេរុញមកកន្លែងនុ៎ងអ៊ីចេះ។ ហើយប្រវត្តិខ្ញុំហើយ ខ្ញុំអត់មានលាក់បាំងអីទាំងអស់កន្លងមកហ្នឹង ហើយដល់គេមកឲ្យធ្វើការងារហ្នឹង ក៏ធ្វើទៅតាមគេបញ្ជា គេនេះទៅ។ តែគ្រាន់សម័យនោះ គ្រាន់ដឹងថា ស្រទាប់អ្នកចេះដឹងនោះ វាមិនសូវទទួលផលទេ វាពិបាកបន្តិចក្នុងការរស់នៅ។ ហើយដល់ខ្ញុំវា មកធ្វើការងារនោះ ក៏ខ្ញុំចេះតែប្រឹងធ្វើយ៉ាងម៉េចឲ្យវាស្របនឹងសភាពការណ៍ ដែលដើម្បីរស់ក្នុងពេលនុ៎ងដែរ។ សូមអស់មតិបាទ។

[១៣:៣៧:២១]

**ស៖** បាទ អរគុណ។ ប៉ុន្តែក្នុងជំនាន់នោះគេឲ្យឈ្មោះច្បាស់លាស់ថាតើជាវណ្ណៈអធន ឬវណ្ណៈកម្មករ កសិករ ច្បាស់លាស់នោះណាបាទ។ ឥឡូវ ខ្ញុំចូលជាចំណុចមួយទៀត ថាតើអ្នកដែលបានមករៀនសូត្រហើយហ្នឹង គេបញ្ជូន -- គេទុកតែនៅក្នុងក្រសួងឃោសនាការហ្នឹងតែមួយ ឬមួយគេបញ្ជូនទៅចែកចាយទៅតាមក្រសួងនានាបន្ថែមទៀតបាទ?

**ធ៖** ខ្ញុំ បើចង់ អ៎! ចង់សួរខ្ញុំហ្នឹង ដឹងជាសួររឿងនៅក្នុងក្រសួងរបស់ខ្ញុំ ឬមួយសួរជាទិដ្ឋភាពទូទៅ? នេះសំណួរនេះខ្ញុំចាប់មិនទាន់បានអ៊ីចឹងទេណ៎ះ បាទ។ ដល់អ៊ីចឹងកន្លែងខ្លះ ដែលបើសួរក្នុងសភាពក្នុងក្រសួងខ្ញុំ ខ្ញុំឆ្លើយថាការដែលរៀនហើយគឺថា វាបម្រើតែការងារក្នុងក្រសួងហ្នឹងទេ វាសុទ្ធតែបុគ្គលដែលមនុស្សក្នុងក្រសួងហ្នឹងរៀន បាទ។ ឯវិធីអប់រំអីផ្សេងទៀត ខ្ញុំអត់ដឹង អត់យល់ទេ អាហ្នឹងរឿងក្រៅ។ នេះខ្ញុំសូមជូនប៉ុណ្ណឹង។

[១៣:៣៨:៣៨]

**ស៖** អម្បាញ់មិញ ខ្ញុំ -- លោកថា ការជ្រើសរើសមកបង្រៀនអ៊ីចេះ! ហើយខ្ញុំស្មានថា តើការងារដែលគេបង្រៀនហើយ មិនមែនទុកតែក្នុងក្រសួងទេណា! អ៊ីចឹងគេអាចចែកទៅក្រសួងផ្សេងៗ

ទៀត ព្រោះបង្រៀនហ្នឹងវាមានវគ្គពិសេសគឺថា បណ្តុះបណ្តាល៦ខែ ហើយពាក់ព័ន្ធនឹងតែឡេក្រោម។ អ៊ីចឹង ខ្ញុំសួរអម្បាញ់មិញនោះគឺថា ចង់ដឹងថា ប្រសិនមកបង្រៀនអ៊ីចឹងហើយ គេអាចចែកទៅតាមក្រសួងនានាដែរឬអត់? មានន័យអ៊ីចឹងណាលោក។

**ឆ៖** ខ្ញុំសូមឆ្លើយជូនសំណួររបស់លោកដែលបានសួរ។ ការដែលរៀនវគ្គបណ្តុះបណ្តាលនេះគឺរៀនក្នុងក្របខ័ណ្ឌក្រសួងរបស់ខ្ញុំនោះទេ ក្រសួងរបស់ខ្ញុំនៅទេបាទ។ តែគ្រាន់តែថាក្នុងហ្នឹងវាចែកៗមុខជំនាញខុសៗគ្នា។ បើអ្នកដែលរើអាអង្គលីលេខហ្នឹង គេរៀនតែខាងរើទៅ មានគ្រូគេបង្រៀនខាងរើទៅបាទ។ តែដល់អ្នករៀនខាងជួសជុលហ្នឹង គឺគិតពីរឿងអាទោសកំហុស និងឧប្បត្តិហេតុដែលម៉ាស៊ីនខូចអីហ្នឹង ខំប្រឹងរៀនអាជ្រុងហ្នឹងទៅបាទ។ នេះជាជំនាញដែលមានមកហ្នឹង គ្នាប៉ុន្មាននាក់នោះគឺថា សុទ្ធតែមានដោយឡែកៗពីគ្នាទេ គ្រាន់តែថា មួយផ្នែកមានពីរបីនាក់ៗទៅ។ ខ្ញុំសូមជូនចម្លើយប៉ុណ្ណឹង។

[១៣:៤០:០៩]

**ស៖** បាទ អរគុណលោកច្រើន។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិចដោយសារអម្បាញ់មិញអត់បានសួរសំណួរនេះ។ ខ្ញុំចង់ដឹងថា តើនៅពេលមុនរំដោះ មុនរំដោះបានន័យថា ជិតរំដោះបាន។ អ៊ីចឹងពេលដែលជិតរំដោះបានហ្នឹង លោកនៅទីតាំងណាដែរ នៅមុំណាដែរ? នៅក្នុងខេត្តកំពង់ឆ្នាំងហ្នឹង ប៉ុន្តែនៅមុំណាដែរបាទ?

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ តែសំណួរនេះ ព្រឹកមិញ ក៏ខ្ញុំដូចជាបានបញ្ជាក់ខ្លះហើយ។ ព្រោះក្នុងន័យហ្នឹង ខ្ញុំថា មុន១៧ មេសា ហ្នឹង បានសេចក្តីថា ពេលដែលឈ្នះភ្នំពេញហ្នឹង គឺថាខ្ញុំអត់ដឹងថាឈ្នះផងបាទ។ ព្រោះខ្ញុំ ខ្ញុំនៅតាមមាត់ទន្លេ តែដល់ព័ត៌មាន គឺថាអ្នកផ្សេងទៀតទៅហៅខ្ញុំមកថាឥឡូវគេចប់ហើយ គេឈ្នះភ្នំពេញហើយ ឲ្យខ្ញុំដកខ្លួនចេញពីតាមមាត់ទន្លេហ្នឹង ទៅតាមអង្គភាពដែលប្រមូលផ្តុំ តាមកងវិញ។ វាអត់ពង្រាយគ្នានៅតាមមាត់ទន្លេអីទៀតទេ។ ដល់អ៊ីចឹងទីកន្លែងដែលខ្ញុំនៅហ្នឹង គឺថាជាស្រុកកំពង់លែង ដែលជាស្រុកកំណើតខ្ញុំមុនចាស់ ហើយខេត្តៗកំពង់ឆ្នាំង។ បាទតែប៉ុណ្ណឹង។

**ស៖** តាមពិតខ្ញុំចង់ដឹងអ៊ីចេះ ចង់ដឹងថា នៅពេលដែលលោកនៅទីនោះ ពេលដែលលោកធ្វើការងារនៅទីនោះ ថាតើមានជួបលោកមេដឹកនាំធំៗហ្នឹងបានចុះទៅប្រជុំ ឬមួយចុះទៅនៅកន្លែងនោះរៀបចំប្រជុំ ពីធ្វើសេចក្តីសម្រេចអីដែរអត់ទេនៅទីនោះ? ខ្ញុំចង់ដឹងអ៊ីចឹងបាទ។

[១៣:៤២:០៦]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយថែមនូវចម្លើយខាងដើម។ ពេលដែលខ្ញុំនៅហ្នឹង គឺថាអ្នកដែលៗត្រូវប្រជុំ

ឬមួយក៏គ្រប់គ្រងខ្ញុំហ្នឹង គឺថាមានត្រឹមប្រធានដឹកនាំខ្ញុំជាថ្នាក់កងអនុសេនាធំ ប៉ុន្តែដែលខ្ពស់លើសពីហ្នឹងទៀតគឺថា មានត្រឹមវរសេនាតូចរបស់ស្រុក។ ប្រធានគេហ្នឹង ដូចថាអ្នកហ្នឹងឯងជាអ្នកដឹកនាំកម្លាំងសាច់ទ័ពហ្នឹង គឺថាអស់ត្រឹម ត្រឹមប៉ុណ្ណឹង ត្រឹមវរសេនាតូចហ្នឹង។ នេះជូនប៉ុណ្ណឹងឯង។

**ស៖** អរគុណបាទ។ លោកបានលើកឡើងថា នៅពេលដែលជម្លៀសហ្នឹង គឺលោកបានទៅទទួលអ្នកជម្លៀស ថាតើពេលដែលលោកទទួលបានអ្នកជម្លៀសដែលនៅចេញពីខេត្តហ្នឹងទៅហើយទទួលគាត់យកទៅដាក់នៅតាមឃុំ ហើយខ្ញុំចង់ដឹងថា តើពេលដែលបញ្ជូនពួកគាត់ទៅដាក់ដល់ឃុំ ដល់អីហើយហ្នឹង តើគេមានរៀបចំជាលក្ខណៈសហករណ៍ ហើយឲ្យគាត់ធ្វើអីទៀត?

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះតទៀត ក្នុងនាមដែលខ្ញុំបានឃើញនិងដឹងថា ដែលជម្លៀសប្រជាជនចេញពីនោះហើយ ចេញពីខេត្តហើយ ហើយខ្ញុំជាកម្លាំងទ័ពទេ តែគ្រាន់ថាបានជួយបញ្ជូនហ្នឹងទៅឲ្យដល់សហករណ៍។ តែការដែលខ្ញុំនៅជាប់នឹងប្រជាជនដែលនៅក្នុងសហករណ៍ហ្នឹង គឺថាខ្ញុំអត់មានទេ។ គ្រាន់តែថាបានបញ្ជូនទៅឲ្យគេហើយ តែការចាត់ចែងគឺថានៅលើខាងឃុំ ខាងមេសហករណ៍ហ្នឹងគេអ្នកគិតគូររៀបចំទៅ។ តែគ្រាន់បានដឹងត្រឹមថា កាលណោះគឺថា គេឲ្យយើងទៅជីកប្រឡាយ ជីកធ្វើអាងទឹក អាងអីសម្រាប់ខាងកសិកម្មហ្នឹង។ ហ្នឹងដឹងបានប៉ុណ្ណឹងបាទ។ សូមជូនយោបល់ប៉ុណ្ណឹងបាទ។

[១៣:៤៤:៤០]

**ស៖** អរគុណ។ ហើយពេលនោះលោកបានឮពាក្យគេហៅថា ប្រជាជនថ្មី ប្រជាជន១៧មេសា ឬប្រជាជនដូចមូលដ្ឋាន ឮពាក្យហ្នឹងដែរ? ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ ពាក្យនេះខ្ញុំបានឮ គឺថាប្រជាជន១៧មេសា ប្រជាជនមូលដ្ឋានអីគេហ្នឹងគឺជាប្រជាជនចាស់ គឺថាពាក្យហ្នឹងបានឮបាទ។ អ៊ីចឹងបានដែលខ្ញុំជម្រាបខាងដើមថា កាលដែលខ្ញុំទៅនៅភ្នំពេញហើយ ដូចខាងលោក នួន ជា គាត់ថា ឲ្យបញ្ឈប់អាពាក្យហ្នឹង ហើយមិនបាច់បែងចែកថាអានេះជាប្រជាជនចាស់ ប្រជាជនថ្មីអីទៀតទេ។ បាទ ប៉ុន្តែអាហ្នឹងខ្ញុំទៅនៅនោះហើយ តែកាលខ្ញុំនៅហ្នឹងនេះគឺថាមានឮពាក្យហ្នឹង។ បាទ អស់ហើយ។

**ស៖** ពេលដែលលោកឮអ៊ីចឹងហើយ ថាតើអ្វីដែលជាក់ស្តែងលោកដឹងថា តើគេបែងចែកពួកគាត់ឲ្យនៅជាលំដាប់លំដោយ ឬមួយជាក្រុម ជាពួក ជាក្រុមច្បាស់លាស់ ឬមួយយ៉ាងម៉េច អាហ្នឹងការអនុវត្តជាក់ស្តែង ពេលដែលលោកឮហើយ?

[១៣:៤៦:១០]

**ឆ៖** ខ្ញុំសូមឆ្លើយបន្ថែម។ ការដែលឮហើយ ការដែលគេរៀបចំប្រជាជននោះយ៉ាងម៉េចៗ ខ្ញុំមិនបានឃើញ មិនបានយល់ដឹងទេ ដោយសារអី? ដោយសារថា ខ្ញុំជាអង្គភាពទ័ព។ ហើយដូចខ្ញុំបញ្ជាក់ខាងដើមមកថា ខ្ញុំអង្កាល់ហ្នឹងក៏នៅក្នុងអាការដែលលើកទំនប់ប្រឡាយនឹងគេដែរ ដែលខ្ញុំអត់ទាន់មកភ្នំពេញនេះបាទ។ ហើយអ៊ីចឹងការងារដែលប្រជាជនទៅនៅនោះ គឺរឿងគេនោះគេចាត់ចែង ឯខ្ញុំមានកង មានអង្គភាពរបស់ខ្ញុំ ធ្វើតែការងារខ្ញុំនេះដែរ។ នេះខ្ញុំសូមជូនយោបល់ប៉ុណ្ណឹងបាទ។

[១៣:៤៦:៥៤]

**ស៖** អរគុណ ខ្ញុំសូមចូលទៅមួយចំណុចទៀត។ ពេលដែលលោកអញ្ជើញមកទីក្រុងភ្នំពេញហើយ បានធ្វើការនៅក្នុងក្រសួងឃោសនាការ។ ពេលនោះគឺលោកស្គាល់តែលោក ភាស់ ដែលក្រោយមកលោកបានស្គាល់ ភាស់ ហ្នឹងជាលោក ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីក្រសួងឃោសនាការនេះ។ ថាតើពេលដែលលោក ហ៊ូ នឹម ដែលគាត់នៅគ្រប់គ្រងហ្នឹងមានប្រធានផ្នែកជារចនាសម្ព័ន្ធនៅក្នុងក្រសួងហ្នឹងមានប៉ុន្មានផ្នែកដែរបាទ? ដូចថាក្នុងក្រសួងឃោនាការមានផ្នែកស្តាប់វិទ្យុ មានផ្នែកធ្វើឯកសារ មានផ្នែកស្អីហ្នឹង ខ្ញុំចង់ដឹងថាតើមានប៉ុន្មានផ្នែក? ហើយលោកអាចបញ្ជាក់បានទេថា តើក្នុងផ្នែកមួយៗហ្នឹងមាននរណាខ្លះដែលទទួលខុសត្រូវហ្នឹងបាទ?

**ឆ៖** ខ្ញុំសូមឆ្លើយថា បញ្ហារឿងរចនាសម្ព័ន្ធនៅក្នុងក្រសួងនេះ ខ្ញុំដូចជាឲ្យយល់ដឹងឆ្លើយវា -- នេះដោយសារខ្ញុំវាភ្លេចភ្លាំងបាត់ការចងចាំអស់មួយចំនួន។ អ៊ីចឹងដឹងស្អីដែលក្របខ័ណ្ឌការងាររបស់យើងហើយពេលនោះក៏ ខ្ញុំក៏មិនសួរទៅស្វែងយល់ស្អីដែលក្រៅពីការងារខ្លួនដែរ ព្រោះវាជាដំណាក់កាលមួយដែលត្រូវរស់ដោយៗ មិនៗឲ្យប៉ះពាល់ ដូចខ្ញុំទាក់ទងតាំងពីលើ ដល់ពេលប្រជុំគេទិតៀន គេកសាងនិយាយអ៊ីចេះអ៊ីចុះ យើងរស់ក្នុងសភាពខ្លាចគេថាឲ្យ ដល់អ៊ីចឹងខ្ញុំអត់ស្វែងយល់អីឲ្យដឹងរឿងក្រៅពីការងារខ្លួនឯងច្រើន ហើយដល់អ៊ីចឹងខ្ញុំរកឆ្លើយអត់អត់បាន។ បាទ សូមអស់មតិ។

[១៣:៤៩:០៧]

**ស៖** បាទ អរគុណលោកច្រើន។ ក្រសួងឃោសនាការនេះគឺមានការផ្លាស់ប្តូរមនុស្សគ្រប់គ្រងជាច្រើន។ បន្ទាប់ពីលោក ហ៊ូ នឹម គឺចូលមក យុន យ៉ាត ហើយបន្ទាប់ពី យុន យ៉ាត ចូលមកលោក នួន ជា។ ការគ្រប់គ្រងហ្នឹង។ ខ្ញុំចង់ដឹង ថាតើការគ្រប់គ្រងរបស់តាំងពីលោក ហ៊ូ នឹម រហូតមក យុន យ៉ាត និងលោក នួន ជា តើមានការប្រែប្រួលនៃអ្វីដែលនៅក្នុងក្រសួងហ្នឹងដែរអត់ទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ វាបើឆ្លើយទៅ ហាក់ដូចជាធ្វើការនិយាយហ្នឹងវាទ្រង់វែងបន្តិច តែខ្ញុំគ្រាន់ថា

អាចនិយាយដោយខ្លីស្រណុកថា ការដែលខ្ញុំចូលទៅដំបូងគឺលោក ហ៊ូ នឹម ដែលខ្ញុំត្រូវទៅធ្វើការដំបូង គឺថាមាន ហ៊ូ នឹម ដែលទទួលមុនគេ។ តែក្នុងពេលហ្នឹង ខ្ញុំក៏ទទួលស្គាល់ថា អង្កាល់ហ្នឹងខ្ញុំទៅក៏ខ្វះអាហារបាយស្រស់ស្រួបសម្រាប់ពេលវេលាជីវភាពហ្នឹងក៏ខ្វះដែរ។ តែខ្ញុំគ្រាន់មិនដឹងថា តើការខ្វះហ្នឹងវារយៈពេលប៉ុន្មានខែៗទេ ដែលកាលនុំងថា ដូចពាក្យយើងថាហូបបាយខ្វះ ហូបបបរហូបអីហ្នឹង ខ្ញុំក៏មានការហូបបញ្ហាហ្នឹងដែរ ហូបរបៀបអីចឹងដែរ។ បាទ ឆ្លងកាត់ការហូបហ្នឹងដែរ។ ហើយដូចជាផុតពីហ្នឹងមកដែលខ្ញុំនៅដឹងខ្លះក៏មានការហូបនំប៉ុង នំអីលាយ។ នេះខ្ញុំៗនិយាយពីដំណើរដែលខ្ញុំនៅក្នុងក្រសួងហ្នឹងបាទ។ ហើយដល់ផុតពីហ្នឹងមកទៀត គឺចាប់ផ្តើមបានហូបបាយ ដែលពេល នួន ជា មកទទួលក្រោយនេះ។ កាលហ្នឹង មិនដឹងជាប្រជាជននៅខាងក្រៅយ៉ាងម៉េចទេ ទិដ្ឋភាពខ្ញុំមិនដឹង តែគ្រាន់ទិដ្ឋភាពនៅកន្លែងខ្ញុំវាអីចឹង។ វាមានដំណើរអីចឹង។ ហើយដល់ហូបបាយហ្នឹង ហើយកាលហ្នឹងក៏កំណត់ថាឲ្យហូប ១០ថ្ងៃបង្អែមម្តង អីចេះ បង្អែមម្តង។ បញ្ហានេះមិនមែនថាលើកជាគោលការណ៍ហើយអត់អនុវត្តទេ បានធ្វើ បានអនុវត្ត មានហូបអីចឹងមែនបាទ។ រហូតដល់ពេលដែលៗមានបញ្ហាដកខ្លួនចេញពីភ្នំពេញទៅអារឿងហូបហ្នឹង។ ដល់អីចឹងដំណើរហ្នឹង ខ្ញុំមិនដឹងថាតើពីមុនមកដែលអត់ហ្នឹងវាយ៉ាងម៉េច អីយ៉ាងម៉េច ហើយដល់ពេលមកក្រោយមក វាទៅមានបាយហូបហ្នឹង ដំណើរហ្នឹងវាទៅយ៉ាងម៉េចៗ អាហ្នឹងខ្ញុំមិនដឹងទេ រឿងហ្នឹងរឿង តែគ្រាន់ដំណើរជីវភាពរស់នៅសម្រាប់ដែលខ្ញុំមកនៅភ្នំពេញហ្នឹង វាមានដំណើរការរបៀបហ្នឹង។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹងបាទ។

[១៣:៥២:២០]

**ស៖** អរគុណ។ តាមពិតខ្ញុំចង់ដឹងចំណុចថា ការគ្រប់គ្រងជាលក្ខណៈរចនាសម្ព័ន្ធ ថាតើពេលដែលរចនាសម្ព័ន្ធលោក ហ៊ូ នឹម គ្រប់គ្រង ហើយពេលរចនាសម្ព័ន្ធពេល យុន យ៉ាត គ្រប់គ្រង ហើយបន្ទាប់មកលោក នួន ជា ហ្នឹង គាត់ផ្លាស់ប្តូររចនាសម្ព័ន្ធ ផ្លាស់ប្តូរអ្នកនេះទៅធ្វើការងារនោះ អ្នកនោះធ្វើការងារនេះ ឲ្យអ្នកនេះទៅកាន់ប្រធានកន្លែងនោះវិញ តើមានការផ្លាស់ប្តូរអីចឹងដែរអត់? ហើយឬមួយមានថា ការបាត់ខ្លួនបន្តបន្ទាប់ទៀត?

**ឆ៖** បាទ សំណួរនេះខ្ញុំស្តាប់បានហើយ គឺថាខ្ញុំគ្រាន់តែ បញ្ជាក់ថារចនាសម្ព័ន្ធដែលតាមកន្លែងខ្ញុំហ្នឹង ខ្ញុំគ្រាន់តែដឹងថាកាលដែលខ្ញុំចូលមកនៅហ្នឹង គឺថាវាកម្លាំងហ្នឹងវាមានមកពីខាងបូព៌ាផង ហើយខាងបស្ចិមហ្នឹងតែខ្ញុំម្នាក់ទេ អាហ្នឹងខ្ញុំនិយាយជូនអង្គសវនាការអីចឹង។ មកខាងបូព៌ាហ្នឹងច្រើនពេលហ្នឹង ហើយកម្លាំងចាស់ដែលគេមានហ្នឹងហើយ គេនៅហើយ តែដែលបញ្ជូលមកពេលហ្នឹង គឺថាមាន

តែខ្ញុំ និងខាងបូព៌ា។ តែដល់វគ្គបណ្ដុះបណ្ដាលខាងបច្ចេកទេសហ្នឹងវាចប់ហើយ ដំណើរការធម្មតាហ្នឹង តែដល់ពេលចាប់ដក ហ៊ូ នឹម ទៅ ខ្ញុំមិនដឹងជារឿងអីៗទេ តែកម្លាំងនេះវាទៅជាមួយដែរ វាអ៊ីចេះ ដក បាត់ៗទៅ។ បើខ្ញុំមិនស្វែងយល់អីថា ព្រោះអាហ្នឹងវាជារឿងរបស់នេះ ខ្ញុំគិតតែរឿងការងាររបស់ខ្ញុំ ថា បើដកទៅ ចេះនឹកថា ហ៊ី! ដឹងបានមនុស្សណាធ្វើការ បើចេះតែដកទៅ គិតខ្លួនឯងអ៊ីចឹង។ ដល់អ៊ីចឹងចេះ តែប្រឹងខ្លួនឯងថែមទៀត។

ហើយដល់ដកទៅ ត្រូវ យុន យ៉ាត មកទទួលវិញ កាលពិតគ្រាន់តែយកមនុស្សមកបញ្ចូលកន្លែង ដែលប្រហោងហ្នឹងវិញទេ អាកន្លែងដកចេញវិញទេបាទ ដកចេញវិញទេ។ តែដល់យកមក ខ្ញុំគ្រាន់តែ ដឹងថា មកក្រោយហ្នឹង មិនដឹងជាបុគ្គលណាៗ តែគ្រាន់តែថាមនុស្សនៅក្នុងកម្លាំងរបស់ខ្ញុំ គាត់បញ្ចូល មកសុទ្ធតែក្មេងៗមកពីខាងភូមិភាគនិរតី។ នេះតាមខ្ញុំចាំបាទ ភូមិភាគនិរតី ព្រោះកម្លាំងហ្នឹង ខ្ញុំអ្នក បណ្ដុះបណ្ដាលបន្ត ដែលខ្ញុំរៀនបានពីខាងវគ្គជាមួយចិនមក ខ្ញុំចេះតែបណ្ដុះបណ្ដាលបន្ត ដោយសារគេ ដកអស់ហើយ យុន យ៉ាត ហ្នឹងក៏ប្រគល់មនុស្សដែលក្មេងៗហ្នឹងឲ្យខ្ញុំ ថាឲ្យជួយបណ្ដុះបណ្ដាលក្មេង ៗនេះដើម្បីដំណើរការការងារហ្នឹងឲ្យបានអ៊ីចេះ។ ដល់ខ្ញុំគិតតែប្រឹងអាហ្នឹងរឿងហ្នឹង។ ដល់អ៊ីចឹងរឿង មនុស្សបាត់ទៅណា ខ្ញុំអត់ដឹងរឿងទេ អ្នកដកទៅនោះ។

[១៣:៥៥:២៤]

អ៊ីចឹងខ្ញុំគ្រាន់តែឃើញ ហៅថារចនាសម្ព័ន្ធហ្នឹង គឺថាដែល ខ្ញុំក្នុងឯកសារដែលខ្ញុំបញ្ជាក់ថា ហាក់ដូចជា កាលបូព៌ា ដូចមានរឿងជាមួយខាងបូព៌ា ដូចមនុស្សចូលកាលណាដូចទៅបាត់ទៅ ឥឡូវ វាឃើញសុទ្ធមនុស្សមកពីខាងនិរតីមកវិញ។ នេះខ្ញុំគ្រាន់តែគិតអង្គាល់នុ៎ងទេ ហើយដល់អ៊ីចឹងខ្ញុំគ្រាន់ តែថា យី! វរៗ ជាប់ខ្សែខាងណាគេដកខ្សែខាងហ្នឹងៗ។ នេះគ្រាន់តែគិតខ្លួនឯង មិនឲ្យតម្លៃថាដឹងរឿង អីច្បាស់ទេ ដោយសារឃើញថាមក ម៉េចក៏ទៅវិញបាត់អស់ ហើយស្រាប់តែយកណោះ ឃើញតែខាង ណោះ។ នេះដែលខ្ញុំជូនអង្គជំនុំដើម្បីយល់ បញ្ហាដែលៗពីរឿងរចនាសម្ព័ន្ធនៅកន្លែងនុ៎ងវាអ៊ីចឹង។ ហើយ ដល់ខ្ញុំបស្ចិម ខ្ញុំតែម្នាក់ឯង ខ្ញុំនៅ ចេះតែនៅទៅ បាទ។ បាទ អ៊ីចឹងបានក្នុងឯកសារនេះខ្ញុំបានបញ្ជាក់ខ្លះ ដែលលោកមិនទាន់បានអស់ចម្ងល់ ក៏ខ្ញុំឆ្លើយបន្ថែមទៀតបាទ។ សូមអស់យោបល់។

[១៣:៥៦:៣២]

**ស៖** អរគុណច្រើន។ ខ្ញុំចង់សួរចំណុចហ្នឹងមួយចំណុចទៀត ថាតើហេតុអីបានជាបាត់ យុន យ៉ាត ទៅលោក នួន ជា មកជំនួសវិញ? តើលោកដឹងមូលហេតុចំណុចហ្នឹងដែរអត់ទេ?

**ឆ៖** បញ្ហាដែលដកលោកស្រី យុន យ៉ាត ហើយ នួន ជា មកវិញនេះ ខ្ញុំអត់មានបានដឹងរឿងអីទាំងអស់។ ព្រោះគ្រាន់តែដឹងថា យុន យ៉ាត កន្លងមកគាត់ទទួលក្រសួងមួយ--

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ការបកប្រែជាភាសាអង់គ្លេសបាននិយាយថា នួន ជា បានទទួលជំនួសនៅពេលដែល យុន យ៉ាត បាត់ខ្លួន។ នេះមិនមែនជាភស្តុតាងដែលបានប្រគល់មកអង្គជំនុំជម្រះកាលពីមុនទេ ទៅតាមឯកសារអ្វីដែលមាននោះ។

[១៣:៥៧:៤៧]

**លោក ឡោ ជុនធី៖**

អ៊ីចេះលោកប្រធាន សំណួរខ្ញុំអម្បាញ់មិញ ចង់សួរថា ហេតុអីបានលោក នួន ជា គាត់ចូលទៅជំនួស យុន យ៉ាត នៅក្រសួងឃោសនាការហ្នឹង? អ៊ីចឹងមានមូលហេតុអីកន្លែងហ្នឹងបាទ។

**ប្រធានអង្គជំនុំ៖**

សួរម្តងទៀតទៅ!

**លោក ឡោ ជុនធី៖**

អរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំចង់សួរខ្លីថាចំណុចនេះថា ហេតុអីបានជាលោក -- មូលហេតុអីបានជាលោក នួន ជា មកជំនួសកន្លែង យុន យ៉ាត ហ្នឹង? មានដឹងមូលហេតុអីដែលអត់ទេ?

[១៣:៥៨:៣៦]

**លោក ខៀវ អេន៖**

**ឆ៖** មូលហេតុដែល នួន ជា មកជំនួស យុន យ៉ាត នេះ ខាងខ្ញុំអត់មានដឹងបញ្ហាអីទេ។ បាទសូមអស់។

**ស៖** អរគុណ។ លោកអម្បាញ់មិញបានឆ្លើយពាក់ព័ន្ធនឹងខាង បានន័យថា មានមនុស្សខាងបូព៌ា មានមនុស្សខាងនិរតី មានមនុស្សខាងបស្ចិម។ ថាតើ ខ្ញុំចង់ដឹងថាតើខាងបូព៌ា នរណាខាងបូព៌ាហ្នឹង

ក្រុមបូព៌ាដែលនៅក្នុងក្រសួងហ្នឹង? តើលោកអាចជម្រាបបានទេ? ហើយមួយទៀតថាតើនរណាដែលនិរតី? លោកអាចជម្រាបបានទេបាទ?

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ។ ឯន័យដែលខ្ញុំបញ្ជាក់ថាខាងបូព៌ា ខាងនិរតីនោះ គឺខ្ញុំនិយាយពីសមាជិកដែលធ្វើការជាមួយខ្ញុំបាទ ព្រោះអ្នកដែលធ្វើការជាមួយខ្ញុំហ្នឹង គឺពេលដែលវគ្គបណ្ដុះបណ្ដាលដំបូងហ្នឹង គឺថា បើខ្ញុំចាំខាងនិរតីដូចអត់មានទេ សុទ្ធតែមកពីបូព៌ា។ ដោយឡែកតែខ្ញុំអ្នកបស្ចិមម្នាក់ខ្ញុំមកចូលធ្វើការវគ្គបណ្ដុះបណ្ដាលហ្នឹង។ ហើយដល់ពេលដូចថាដក ហ៊ូ នឹម ទៅ ពួកហ្នឹង ក៏ទៅមិនដឹងជារឿងអីដែលខ្ញុំមិនដឹងដែរហ្នឹង គេទៅៗអស់ទៅ។ ស្រាប់តែក្រោយមក ទទួល យុន យ៉ាត មកចូលក៏ខ្ញុំឃើញកម្លាំងដែលមកឲ្យខ្ញុំមកបណ្ដុះបណ្ដាលហ្នឹងបន្ត វាសុទ្ធតែមកពីខាងនិរតីអ៊ីចេះ បាទ។ ហើយដល់អ៊ីចឹង ខ្ញុំគ្រាន់តែគិតថា អ្ហ៎! ពីមុនសុទ្ធតែបូព៌ា ឥឡូវគេទៅអស់ ឥឡូវអ្នកមកថ្មីសុទ្ធតែនិរតីសួរទៅ។ ហើយដល់ខ្ញុំខាងបស្ចិមម្នាក់ឯង នៅៗប្រឈមនឹងការងារហ្នឹងម្នាក់ឯង ដល់អ៊ីចឹង ចេះតែខំធ្វើការងារដែលបម្រើ អាមុខជំនាញរបស់ឯងហ្នឹង ព្រោះវានៅតែឯង គេទៅអស់ហើយ។ ហើយអ៊ីចឹងចេះតែស្វែងយល់បន្ថែមអាស្អីដែលមិនទាន់ដឹង ចេះតែប្រឹងបន្ថែម។ នេះក្នុងន័យដែលខ្ញុំនិយាយ សំណួរមុន ខ្ញុំប៉ុណ្ណឹងបាទ។ សូមអស់មតិបាទ។

[១៤:០០:៥៧]

**ស៖** អរគុណច្រើន។ ចុះលោកស្គាល់នរណាជាមេខាងភូមិភាគនិរតីដែរ?

**ឆ៖** ខ្ញុំ មេភូមិភាគនិរតីហ្នឹង កន្លងមកដែរ ខ្ញុំបានត្រឹមតែឮទេ ឮឈ្មោះទេ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជាទីគោរព និងភាគីទាំងអស់ជាទីគោរព។

ខ្ញុំជំទាស់នូវសំណួររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ព្រោះថារហូតដល់ពេលនេះ ថាយើងនិយាយអំពីបញ្ហាក្រសួងឃោសនាការ។ ក៏ប៉ុន្តែឥឡូវនេះ យើងបែរទៅជានិយាយអំពីភូមិភាគនិរតី ដែលមិននៅក្នុងក្របខ័ណ្ឌនៃការជម្រះសេចក្ដីយើងនេះទេ។ ដូច្នេះ មិនមានពាក់ព័ន្ធនោះទេ។ អ៊ីចឹងខ្សែសំណួរ

របស់គាត់នេះ មិនសមស្របនោះទេ លោកប្រធាន។

[១៤:០២:២៤]

**លោក ឡោ ជុនធី៖**

តាមពិត សំណួរនេះ វាពាក់ព័ន្ធទៅនឹងចម្លើយអ្វីដែលសាក្សីបានឆ្លើយភ្លាប់។ អ៊ីចឹងបានជាខ្ញុំសាកសួរបន្ថែម បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តសំណួរថ្មីទៀត ព្រោះបញ្ហានេះ ដូចជាសាក្សីបានឆ្លើយរួចហើយដែរ មិនដឹង-- គាត់មិនដឹងទេ។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ថាតើនៅពេលដែលលោកមកធ្វើការនៅក្នុងក្រសួងឃោសនាការនេះ តើលោកបានចូលរួមមហាសន្និបាតរបស់បក្សដែរឬទេ? ហើយបើបានចូលរួម តើចូលរួមមហាសន្និបាតបក្សហ្នឹង នៅកន្លែងណាខ្លះ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមមានមតិ។ ការដែលចុះទៅចូលរួមនេះ គឺថាខ្ញុំមិនបានចូលរួមទេ បើថាទៅជាការរៀនអីធម្មតាតូចតាច អាហ្នឹងខ្ញុំបានទៅ។ តែរៀន វាជាការរៀនតូចតាច ទ្រង់ទ្រាយតូចតាច តែជាសន្និបាតអី គឺថាខ្ញុំអត់បានទៅ។ ម្យ៉ាងក៏អត់មានអ្នកធ្វើការ ដោយសារថាកម្លាំងកន្លែងខ្ញុំ វាមានបញ្ហាដូចខ្ញុំលើកឡើងហ្នឹង។ បាទ ដល់អ៊ីចឹង គឺថាដើរចោលអត់ -- ដល់អ៊ីចឹង នៅតែកន្លែងផ្ទាល់ អត់សូវបានដើរធ្វើទេ បាទ។ សូមអស់មតិ។

[១៤:០៤:២៧]

**លោក ឡោ ជុនធី៖**

សូមអរគុណ។ ខ្ញុំបាទ លោកប្រធាន ខ្ញុំបាទសូមបង្ហាញនូវឯកសារមួយ ដែលមានលេខ E3/1550។ លេខ ERN ខ្មែរ 0006662, លេខ ERN អង់គ្លេស 00249844, លេខ ERN បារាំង 00766902។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

ឯកសារគេអីទៅ បានប្រាប់លេខ ហើយនិងអត្តសញ្ញាណឯកសារ ឯកសារអីគេ?

**លោក ឡោ ជុនធី៖**

កាលពីព្រឹកមិញខាងសហព្រះរាជអាជ្ញាបានបង្ហាញហើយគឺថា ចម្លើយសារភាពរបស់លោក ហ៊ូ នឹម។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

[១៤:០៥:៤៩]

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំបាទ សូមអានឃ្លាមួយរបស់លោក ហ៊ូ នឹម "ខ្ញុំនឹកឃើញពេលថ្មីៗកាលឆ្លងជីវទស្សន៍បដិវត្តន៍នៅសាលាបក្សបុរីកីឡា ខែ១១ ១៩៧៦ ឮសមមិត្ត ឆយ លើកពី ភោគ ឆាយ ហើយនិយាយពីរឿងបង្កើតបក្ស"។ ចំណុចនេះ ខ្ញុំចង់ជម្រាបសួរថា តើលោកបានដឹងពីចំណុចនេះដែរឬអត់ទេបាទ?

**លោក ខៀវ អេន៖**

**ឆ៖** ចំណុចដែលខាងលោកលើកឡើងនេះខ្ញុំអត់បានដឹងទេ ព្រោះវាជារឿងរបស់ខាងគេ ខាងលើ ខាងបក្សអីហ្នឹង។ បាទ ខ្ញុំមហាជនដូច ខ្ញុំថាខ្ញុំអត់បានទៅដឹងឮអីរឿងអីចឹងៗទេ គិតតែពីរឿងបច្ចេកទេសរបស់ខ្ញុំ។ បាទ សូមអស់មតិ។

[១៤:០៧:២៩]

**ស៖** កាលពីព្រឹកមិញលោកបានលើកឡើងថា លោកបានឃើញទស្សនាវដ្ដីទង់បដិវត្តនៅក្រសួង ខ្ញុំចង់ដឹងថា តើលោកបានឃើញហ្នឹងគឺលោកបានពិនិត្យមើលទេ ហើយថាតើមានរូបរាងម៉េច ពណ៌ខាងម៉េចដែរ? បើសិនលោកបាន -- មិនបានអានបាទ។

**ឆ៖** ខ្ញុំសូមឆ្លើយ។ បើគិតមកឥឡូវខ្ញុំដូចជាចាំមិនបាន តែការពិតជាក់ស្ដែងគឺថា ខ្ញុំបានឃើញទង់នេះមែន តែដល់ខ្ញុំបញ្ជាក់ពីថាត្រូវមានទង់ប៉ុន្មានអីប៉ុន្មាន ពីរូបភាពអីវាហ្នឹង ខ្ញុំបញ្ជាក់អត់បានទេ។ ដូចថា វាចាំមិនបាន ភ្លេចអស់ហើយបាទ។ តែគ្រាន់តែដឹងថា មានយកមកឲ្យប្រែ-- មិត្តយើងនៅធ្វើការហ្នឹងគេមើល គេអីគេមើលទៅ តែខ្ញុំវាមិនបានគិតគូរចាប់អារម្មណ៍អារឿងហ្នឹង។ ហើយក៏មិនបានគិតថា អានេះត្រូវទង់ម៉េច អីម៉េច គឺថាហើយ ហើយ អត់ដឹងទេ។ នេះខ្ញុំសូមជូនប៉ុណ្ណឹងបាទ។

[១៤:០៨:៥៧]

**ស៖** អរគុណ។ ខ្ញុំជម្រាបសួរលើសំណួរមួយទៀតថា ពេលដែលលោករៀនបណ្តុះបណ្តាលពីពាក់ព័ន្ធរឿងតេឡេក្រាម អីហើយអស់។ អ៊ីចឹងពេលដែលក្រោយលោកបានរៀនសូត្រហើយគេប្រគល់ការងារសំខាន់អ្វីខ្លះជូនលោក ដូចជាការសរសេរតេឡេក្រាម បញ្ជូនទៅខាងក្រសួងមន្ទីរណាផ្សេងៗដែរឬអត់ទេបាទ?

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ ការដែលដកកម្លាំងហើយត្រូវឲ្យខ្ញុំទទួលៗរៀបចំបណ្តុះកម្លាំងថ្មី។ ខ្ញុំជូនថា ពីដំបូងខ្ញុំរៀនតែខាងជួសជុលទេ ជួសជុលអាអង្គុលីលេខហ្នឹងបាទ។ ឯការវាយអង្គុលីលេខហ្នឹង ដែលជាការវាយហ្នឹង គឺថាមានរបស់គេផ្សេង អ្នកផ្សេងទេ។ តែដោយសារតែការងារវាជាប់ហ្នឹងខ្ញុំចេះតែរៀនវ៉ៃតាមគេ។ ចេះតែរៀនបន្ថែមបាទ។ ដល់រៀនបន្ថែមទៅ ការដែលគេដកអ្នកហ្នឹងចេញទៅខ្ញុំនេះក៏ដូចជា គ្រាន់តែយល់ជាសាច់ការ តែការជាក់ស្តែងខ្ញុំអនុវត្តមិនទាន់បានល្អទេបាទ វ៉ៃមិនទាន់កើតអីស្រួលទេ។ បាទ អ៊ីចឹងក៏រៀនវ៉ៃខ្លួនឯងបន្ថែម ហើយកម្លាំងដែលគេឲ្យមកហ្នឹង ក៏បង្រៀនគេថែម ថាអាហ្នឹងគេរៀនយ៉ាងម៉េចៗហ្នឹង ប្រាប់វិធីដែលធ្លាប់បានឃើញអង្គាល់គេរៀនមុនមក។ ហើយ ខ្ញុំហ្នឹងក៏រៀនបន្ថែមតាមហ្នឹងដែរទៅ ដើម្បីស្វែងរកការយល់ដឹងបន្ថែមនៅលើអាៗគេរៀនហ្នឹង តើគេរៀនម៉េចអីម៉េចហ្នឹង យើងស្វែងយល់ថែម ព្រោះអង្គាល់ដែលរៀនជាមួយបរទេសហ្នឹង ខ្ញុំអត់បានរៀនអ៊ីចេះ។ តែដោយសារការងារជាប់នឹងនោះ ចេះតែរៀនថែមបាទ រៀនអាវិធីវ៉ៃហ្នឹង ព្រោះពីមុនរៀនតែជួសជុលទេ ដឹងតែជួសជុលទេ រៀនជាមួយគ្នា។ នេះខ្ញុំគ្រាន់តែថា ដែលខ្ញុំត្រូវបណ្តុះបណ្តាលនោះ ខ្ញុំបន្ថែមខ្លួនឯងផង បង្រៀនគេផង ដល់ពេលដកទៅហ្នឹង។ ហើយដល់ដកដែលបង្រៀនក្រោយហ្នឹងគឺថា ច្រើនតែមនុស្សដែលខ្ញុំថា សុទ្ធតែមនុស្សមកពីនិរតី ឯតួនាទីអីនោះគឺថាវានៅដដែលទេ អត់មានអីចូលទេគ្រាន់តែថា ការងារវាយើងបច្ចេកទេសប៉ុណ្ណោះ យើងនៅតែធ្វើអាប៉ុណ្ណឹង គេឲ្យមនុស្សមកថែមមក ដកចេញទៅគេឲ្យមនុស្សថែមមក យើងប្រឹងធ្វើម៉េចឲ្យអាកន្លែងហ្នឹងកុំឲ្យ ឲ្យកើត ឲ្យដំណើរការកើត។ នេះ ខ្ញុំមានមតិប៉ុណ្ណឹងជូនបាទ។

[១៤:១១:៤៥]

**ស៖** អ៊ីចេះ សំណួរខ្ញុំថា និយាយអំពីរឿងទំនាក់ទំនងរវាងការផ្ញើសំបុត្រ ឬមួយផ្ញើសារពីកន្លែងលោកទៅកន្លែងគេផ្សេង ដូចឧបមាថា ក្រសួងឃោសនាការហ្នឹងត្រូវផ្ញើសារចេញទៅនេះ តើលោកបានរៀបចំសារហ្នឹង ហើយបើលោកបានរៀបចំសារហ្នឹងជាសារអ្វីខ្លះ? ហើយផ្ញើទៅទំនាក់ទំនងជាមួយ

ក្រសួងមន្ទីរហ្នឹងតាមរយៈអី?

**ឆ៖** សំណួរនេះ ខ្ញុំជម្រាបជូន ហើយព្រឹកមិញហាក់ដូចជាបានឆ្លើយមួយចំនួនហើយ។ រឿងថាឯកសារដែលខ្ញុំចាប់បានពីអាម៉ាស៊ីននេះ គឺថាកន្លែងខ្លះគ្រាន់តែគេប្រាប់ថា អ្ហឺ! ឥឡូវអាហ្នឹងចាប់បីច្បាប់ ដល់អ៊ីចឹងយើងយកអាក្រដាសដែលតម្រូវកាបោន យកវ៉ៃចេញបីសន្លឹកហ្នឹង យើងដាក់បីទៅ ដល់វ៉ៃមក វាជិតបីទៅ ហែក ដល់ម៉ោងចប់យើងហែក យើងមូលអាក្រដាសហ្នឹងជូនទៅគេទៅ តែគេអ្នកបញ្ជូនទៅយ៉ាងម៉េចទៀត ហ្នឹងយើង វាជារឿងរបស់គេបន្តពីខ្ញុំទៀត ខ្ញុំអត់ដឹង។

**ស៖** អរគុណបាទ។ តើលោកកាលពីលោក ហ៊ូ នឹម នៅទីនោះ តើលោកមានស្គាល់កូនលោក ហ៊ូ នឹម ដែរ?

[១៤:១៣:៤២]

**ឆ៖** ខ្ញុំសូមឆ្លើយ តាមការដែលខ្ញុំនៅចាំបាន ខ្ញុំស្គាល់តែម្នាក់ឈ្មោះ សំ ហ្នឹង ហើយដំបូងហ្នឹងដែលខ្ញុំស្គាល់ហ្នឹងគឺថា ខ្ញុំមិនដឹងថាកូន ហ៊ូ នឹម ទេ តែដល់ទៅនៅយូរៗទៅថា សំ ប្រធានមន្ទីរហ្នឹង កូន ហ៊ូ នឹម។ បាន ខ្ញុំដឹងថា អូ្ហ! កូន ហ៊ូ នឹម។ នេះ ខ្ញុំចាប់អារម្មណ៍ ក្រោយពេលដែលទៅនៅយូរហើយទេ បានដឹង ជាប្រធានមន្ទីរហ្នឹងបាទ។ នេះសូមមានមតិប៉ុណ្ណឹងបាទ។

**ស៖** អរគុណ។ ចំណុចមួយទៀត ថាតើលោកបានដឹងទេ បានជួបទេ ពីការបង្ខំឲ្យព្រះសង្ឃសឹក ថាតើចំណុចនេះ លោកបានជួបប្រទះដែរ ឬអត់ទេបាទ?

[១៤:១៤:៥១]

**ឆ៖** ចំណុចរឿងព្រះសង្ឃសឹក។ អានេះវា ឯកសារអង្កាល់ដែលខាងលោក ទៅធ្វើនេះជាមួយខ្ញុំក៏ខ្ញុំបានបញ្ជាក់ដែរហើយ គឺថាខ្ញុំបានដឹងតាំងពីខ្ញុំនៅភូមិកំណើតនោះ ព្រោះភូមិនៅខេត្តឆ្ងាយដែរ។ ដល់អ៊ីចឹងគេហៅថា ជាតំបន់ដែលកាលហ្នឹងគេថា ងាយដែលបដិវត្តន៍ហ្នឹងវាកើត។ បាទ វានៅឆ្ងាយពីខេត្តទៅជនបទ។ ដូចខ្ញុំបញ្ជាក់ហើយថា នៅខាងព្រៃគ្រីឯណោះ។ ហើយដល់អ៊ីចឹង ពេលដែលទាហាន លន់ នល់ មិនទាន់ចូលមុននោះ ពី៧០មកហ្នឹង គឺថាចលនាហ្នឹងវាកើត វាបានចូលទៅដល់ភូមិខ្ញុំហ្នឹង។ បាទ ដល់ចូលទៅ គេថាមុន លន់ នល់ ហ្នឹង គឺថាព្រះសង្ឃអីដែលបួស ដែលអីហ្នឹងគឺថាគេមានឲ្យសឹក ខ្ញុំក៏ទទួលស្គាល់ការពិត ខ្ញុំនៅហ្នឹងបាទឲ្យសឹក។ ហើយបញ្ហានេះ ខ្ញុំមិនមែននេះទេ គឺថានៅភូមិកំណើតរបស់ខ្ញុំបាទ។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹងបាទ។

**ស៖** អរគុណ។ ចុះលោកបានដឹងទេ ពីពាក់ព័ន្ធថា រឿងគេហៅថា គោលនយោបាយមិនល្អ គេ

បន្តអនុវត្តដល់ពេលណាទៀត គោលនយោបាយដែលមិនល្អ។ សារធាតុៗ គោលនយោបាយ សារធាតុមិនល្អ ថាតើគោលនយោបាយសារធាតុមិនល្អហ្នឹងស្អីគេ ហើយតើគេអនុវត្តដល់ពេលណាបាទ?

[១៤:១៦:៥៧]

**ឆ៖** សំណួរនេះ ខ្ញុំដូចជារកវិធីឆ្លើយ អារឿងសារធាតុមិនល្អហ្នឹង ឆ្លើយថាម៉េច ខ្ញុំមិនដឹងថាសំណួរចង់សួរខ្ញុំ ឲ្យខ្ញុំឆ្លើយយ៉ាងម៉េច? ហើយខ្ញុំដូចជារកកន្លែងយល់ហ្នឹងអត់ឃើញ មិនដឹងឆ្លើយថាម៉េច? ពាក្យថាសារធាតុមិនល្អ ចង់សង្កត់លើអី? នេះខ្ញុំរកកន្លែងឆ្លើយជូនអត់បាន ខ្ញុំជម្រាប។

**ស៖** បាទ អរគុណ។ ខ្ញុំសូមបន្តទៀត ព្រោះពិបាកពន្យល់ដែរចំណុចហ្នឹង ព្រោះភាសាខាងកាលពីរបបកម្ពុជាប្រជាធិបតេយ្យ មានភាសាជាច្រើនដែលយើងពិបាកពន្យល់ដែរបាទ។ ចំណុចមួយទៀត ខ្ញុំចង់ដឹងដែរថា តើនៅក្នុងអ្វីដែលលោកបានធ្វើការនៅទីនោះ ហើយក្នុងមួយរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺលោកបាននៅភ្នំពេញ។ តើលោកបានដឹង ហើយដឹងថាមានមន្ទីរសន្តិសុខដែរអត់ទេនៅភ្នំពេញហ្នឹងបាទ?

**ឆ៖** នៅភ្នំពេញ រឿងមន្ទីរសន្តិសុខ ខ្ញុំបានដឹងត្រឹមតែឮ។ ការឃើញ អត់បានឃើញទេ។ ហើយការឮនេះ ក៏តាមរយៈមិត្តភក្តិដែលគេធ្វើការជាមួយហ្នឹង គេនិយាយទៅ ក៏ឮពាក្យហ្នឹងនឹងគេទៅ។ ហើយចំណុចថានៅត្រង់ណាៗ ក៏អត់ដឹងទៀត។ បាទ នេះចង់និយាយថាបានតែឮទេ ឃើញក៏មិនបានឃើញ ហើយចំណុចទីតាំងក៏អត់ដឹងទៀត។ សូមអស់មតិ។

[១៤:១៨:៥៩]

**ស៖** បាទ ខ្ញុំសូមសួរលោកមួយសំណួរទៀតថា លោកបានលើកឡើងអំពីថា មន្ទីរ៨៧០។ ខ្ញុំចង់ដឹងថាមន្ទីរ៨៧០ ជាអ្វីដែលលោកបានដឹងថាជាមន្ទីរអ្វីដែរ? ហើយនៅកន្លែងណាដែរបាទ?

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះតទៀតថា មន្ទីរ៨៧០នេះ ពាក្យនេះក៏ធ្លាប់បានឮ តែការដែលស្គាល់ទីកន្លែង ហើយការដែលបានទៅឃើញ ក៏អត់ដែលបានដែរ។ ក៏ត្រឹមតែឮអ៊ីចឹងដែរ។ អ៊ីចឹងចំណុចអីនៅទីណាៗ អត់ទេ។ ហើយគ្រាន់តែបានដឹងថា ៨៧០នេះគឺទីតាំងរបស់ថ្នាក់មជ្ឈិមដែលគាត់រស់នៅប៉ុណ្ណឹង។ បានដឹងត្រឹមប៉ុណ្ណឹងបាទ។ ខ្ញុំសូមអស់មតិ។

**លោក ឡោ ជុនធី៖**

បាទ ខ្ញុំ -- លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយសូមផ្ទេរសំណួរនេះទៅខាងសហភាគារបស់ខ្ញុំ។ ហើយលោក ខៀវ អេន ខ្ញុំបាទសូមអរគុណលោកជាច្រើនដែលបានខិតខំការរួមចំណែកក្នុង

ការឆ្លើយនៅក្នុងអង្គជំនុំជម្រះនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមព្រម ទាំងអស់លោកទាំងអស់នៅក្នុងសាលសវនាការនេះ។

[១៤:២០:៥២]

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** សូមជម្រាបសួរលោក ខៀវ អេន ខ្ញុំឈ្មោះ បេនី យេ ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អន្តរជាតិ។ ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីធ្វើការចោទសួរចំពោះរូបលោក។ ខ្ញុំសូមចាប់ផ្តើមនៅ ពេលដែល មុនពេលដែលលោកចាប់ផ្តើមធ្វើការនៅក្រសួងឃោសនាការ។ មុននេះលោកបានប្រាប់យើង ថា លោកធ្វើការនៅក្នុងកងឈ្លប ហើយនិងធ្វើជាទាហាន។ សំណួររបស់ខ្ញុំគឺចង់សួរលោកថា នៅពេល ដែលគេបង្ខំឱ្យលោកចូលទៅក្នុងកងបដិវត្តន៍ហ្នឹង តើលោកមានអាយុប៉ុន្មានឆ្នាំដែរ?

[១៤:២១:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន សូមជម្រាបសួរអស់លោក លោកស្រី ខ្ញុំគិតថាប្រហែលជាមាន បញ្ហាគឺថា លោកសាក្សីបានជម្រាបថា គាត់មិនត្រូវបានគេបង្ខំឱ្យចូលនោះ គឺថាគាត់ចូលដោយសារ មានការទម្លាក់គ្រាប់បែកខ្ទេចផ្ទះ ហើយនិងមានការដុតផ្ទះ គឺគាត់មានការស្ម័គ្រចិត្តក្នុងការចូលទៅក្នុង កងកម្លាំងបដិវត្តន៍មិនមែនត្រូវបានគេបង្ខំឱ្យចូលនោះឡើយគឺគាត់ចូលដោយសារតែមានការទម្លាក់គ្រាប់ បែក និងការកម្ទេចផ្សេងៗ។ សូមអរគុណ។

**លោកស្រី បេនី យេ៖**

តាមការកត់សម្គាល់របស់ខ្ញុំ នៅព្រឹកនេះលោកសាក្សីបានបញ្ជាក់ថា គាត់មិនមែនចូលដោយ ស្ម័គ្រចិត្តនោះទេ គឺថាគាត់ចូលចលនាហ្នឹងដោយការបង្ខំ គឺបង្ខំដោយកងកម្លាំងខ្មែរក្រហម។ ប្រហែល

ជាលោកសាក្សីអាចបញ្ជាក់ទៅលើចំណុចនេះ។ សូមអញ្ជើញលោកសាក្សីជួយបញ្ជាក់ផង។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ!

[១៤:២២:៥៦]

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយបញ្ជាក់នូវចម្ងល់នៃការដែលខ្ញុំចូលធ្វើបដិវត្តន៍នេះ។ការដែលខ្ញុំចូលនេះគឺនៅក្នុងឆ្នាំ៧៣ ក្នុងពេលដែល លន់ នល់ វ៉ៃ -- ត្រូវកម្លាំងបដិវត្តន៍ហ្នឹងវ៉ៃ តែដល់វ៉ៃហើយគឺថាផ្ទះខ្ញុំវាឆេះ ភូមិខ្ញុំឆេះអស់។ ខ្ញុំអង្គាល់ហ្នឹង ខ្ញុំប្រាប់ពីទិដ្ឋភាពដែលៗវាកើតមាន។ បានឆេះហើយ ហើយដល់អ៊ីចឹងបានប្រជាជនមកវិញនោះគឺថា ផ្ទះសម្បែងអីហ្នឹងវាអស់ ទាល់តែធ្វើខ្ទមអីនៅទាំងអស់ហ្នឹង។ ហើយដល់ខ្ញុំហ្នឹងការពិតមិនទោះជាផ្ទះឆេះក៏មិនៗជាការចង់ចូលធ្វើបដិវត្តន៍ទេ។ ព្រោះដល់ឃើញអ៊ីចឹង កាន់តែពិបាកដល់ឪពុកម្ដាយអីថែមទៀត ដែលអត់ផ្ទះអត់សម្បែង នេះខ្ញុំនិយាយពីៗការពិតជាក់ស្ដែង។ ដល់អ៊ីចឹងចម្លើយទៅនឹងសំណួរសួរដែលៗមិនទាន់ច្បាស់នេះគឺថា -- ដល់អ៊ីចឹងទិដ្ឋភាពដែលខ្ញុំចង់ហ្នឹងអត់ទេ អត់ចង់ដោយសារផ្ទះសម្បែងឆេះអស់ហើយ មិនមែនដោយសារឆេះផ្ទះសម្បែងរត់ចូលទេ អត់ទេ។ ឆេះផ្ទះសម្បែងកាន់តែកើតទុក្ខ អញអត់ផ្ទះ អត់សម្បែង ម៉ែឪ -- ដល់អ៊ីចឹងអត់ចង់ទៅទេ តែដល់ពេលគឺថាសភាពការណ៍ វាត្រូវបង្ខំ យើងនៅអត់បាន។ ដល់អ៊ីចឹងទោះយើងអត់ទាន់ទៅធ្វើទ័ពភ្លាម គេឲ្យយើងធ្វើជាឈ្លប ដូចខ្ញុំបញ្ជាក់អ៊ីចឹង ដល់អ៊ីចឹងខ្ញុំនៅជាឈ្លបសិន។ បាទ នេះជាការឆ្លងកាត់បាទ។ ជាឈ្លបសិន បានពេលហ្នឹងខ្ញុំក៏បញ្ជាក់ក្នុងឯកសារដំបូង គេចង់ឲ្យខ្ញុំធ្វើពេទ្យ ដោយសារថាខ្ញុំបានដឹងពីអក្សរខ្លះអីខ្លះហ្នឹង សរសេរអីស្រួលបួលខ្លះ តែដល់ខ្ញុំទេ ខ្ញុំថាពេទ្យខ្ញុំមិនធ្វើទេ បើនៅញ៉ុមញ៉ុមនៅហ្នឹងភូមិហ្នឹងព្រោះៗវាពិបាកពេក ដល់អ៊ីចឹងចង់ចេញឲ្យផុតពីភូមិ ដើម្បីទៅឲ្យឆ្ងាយកុំឲ្យឃើញទិដ្ឋភាពហ្នឹងអ៊ីចេះ។

[១៤:២៤:៥៨]

ដល់អ៊ីចឹង ខ្ញុំក៏ចូលធ្វើឈ្លបនៅភូមិ ហើយខ្ញុំគ្រាន់តែដឹងថា ទិសដៅគង់តែទៅទៀតទេ។ ដូចខ្ញុំនិយាយ ជាខ្សែសង្វាក់គេរៀបចំដំណើរអ៊ីចឹង។ ស្រុកយកពីឃុំ ខេត្តយកពីស្រុក អាហ្នឹងគេរុញអ៊ីចឹង។ ទោះបើយើងមិនស្ម័គ្រចិត្ត ទៅតាមដំណើរការហ្នឹង។ តែខ្ញុំមិនទាន់ទៅភ្លាម ខ្ញុំនៅឈ្លបឃុំហ្នឹង។ ដល់អ៊ីចឹង ខ្ញុំគ្រាន់តែបញ្ជាក់ឲ្យខ្លីមកវិញថា ការដែលចូលនេះ ជាទិដ្ឋភាពមួយដែលគ្រាប់បែកទម្លាក់ហើយសភាពការណ៍ហ្នឹងក៏គេត្រូវបង្ខិតបង្ខំឲ្យខ្ញុំ ហើយខ្ញុំក៏នៅមិនបានដោយឃើញទិដ្ឋភាពហ្នឹងក៏ៗទៅ តែឲ្យ

ស្រឡះខាងផ្លូវចិត្តថា ឲ្យស្ម័គ្រចិត្តទៅ អត់ទេ។ នេះខ្ញុំសូមជូនយោបល់ឲ្យខ្លីប៉ុណ្ណឹងបាទ។

**ស៖** តើនៅពេលនោះ លោកមានអាយុប៉ុន្មានឆ្នាំដែរ នៅពេលដែលលោកចូលចលនា?

**ឆ៖** ខ្ញុំ បើគិតអាយុដូចជាមិនច្បាស់ មិនប្រាកដប្រជាទេ តែគ្រាន់តែអង្កាល់៧០ ដែលខ្ញុំឈប់ទៅ ឈប់ពីរៀនដូចជាអាយុ១៧ ដប់អីហ្នឹង ១៧ឆ្នាំ។ ដល់អីចឹងវាឡើងមកថែមហ្នឹងតិចទៀតមក ពេល១ពី៧០ មក៧៣ ហ្នឹង ខ្ញុំអាចឡើងអាយុមកតាមហ្នឹងទៀត។ នេះខ្ញុំគ្រាន់តែជូនការគិតអីចឹង ព្រោះថាពេលដែលចូលហ្នឹងអត់មានគំនិតគិតអាយុឯងប៉ុនណាទេ តែដឹងថាកាលដែលឈប់រៀនឆ្នាំ៧០ហ្នឹង ខ្ញុំអាយុប្រហែលខ្ទង់១៧ឆ្នាំបាទ។ នេះសូមជូនមតិប៉ុណ្ណឹងបាទ។

**ស៖** ដើម្បីឲ្យមានការបញ្ជាក់ គឺថាលោកកើតនៅឆ្នាំ១៩៥៨ តើត្រឹមត្រូវដែរឬទេ?

[១៤:២៧:១៩]

**ឆ៖** នេះការបញ្ជាក់នេះ ខ្ញុំសូមបញ្ជាក់បន្ថែម ដោយសារថា ខាងលោកចេះតែសួរវែងឆ្ងាយទៅ ខ្ញុំបញ្ជាក់តាមហ្នឹង។ ព្រោះអាយុកាលក្នុងអត្តសញ្ញាណបណ្ណខ្ញុំនេះ ខ្ញុំបន្ថយទេ បាទ ខ្ញុំបន្ថយ។ ដល់អីចឹង ខ្ញុំប្រើតាមរូបភាពបន្ថយ ខ្ញុំហ្នឹងខ្ញុំដាក់ឆ្នាំ១៩៥៨ ឆ្នាំកំណើត។ តែអាយុដែលពិត គឺថាខ្ញុំបើនិយាយឆ្នាំខ្មែរយើង ខ្ញុំឆ្នាំម្សាញ់។ ដូច្នេះ ខ្ញុំមិនដឹងជាខ្ញុំដូចជាគិតលេខថយក្រោយវិញ មិនដឹងជាកើតនៅឆ្នាំ១៩៥២ ឬ ៥៣ អាហ្នឹងខ្ញុំអត់នេះទេ។ គ្រាន់តែ -- ដល់អីចឹងកំណើតនោះផ្សេង អត្តសញ្ញាណបណ្ណនេះផ្សេងអីចេះ។ សូមអស់មតិប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ដូច្នេះហើយទើបធ្វើឲ្យយើងយល់ច្បាស់អំពីការគណនាខុសរបស់ខ្ញុំ នៅពេលដែលយើងគណនាអំពីអាយុលោកចូលទៅក្នុងចលនា។ ឥឡូវនេះយើងពិភាក្សាអំពីរយៈពេលដែលលោកធ្វើការនៅក្រសួងឃោសនាការនិងព័ត៌មាន។ លោកបានជម្រាបប្រាប់យើងថា បន្ទាប់ពីបាត់ខ្លួនសហការីរបស់លោកមួយចំនួន លោកក៏ចាប់ផ្តើមរៀនវាយអត្ថបទទូរលេខ។ តើលោកអាចជម្រាបបានដែរឬទេថាតើខ្លឹមសារនៃទូរលេខហ្នឹង គឺមានរៀបរាប់ពីអ្វីខ្លះដែរ?

[១៤:២៩:០៣]

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ។ បើគិតអ្នករៀនវៃកាលហ្នឹង ទាំងខ្ញុំ ទាំងបុគ្គលិកដែលធ្វើការហ្នឹងខ្លះយកមក មកបង្រៀន អា, បេ, សេ, ដេ, ឲ្យតែចេះមួយចប់ វាយបាន។ អាហ្នឹងខាងបារាំងថា អា, បេ, សេ, ដេ, ឲ្យតែចេះបានពី១អានេះហ្នឹងមួយចប់ ព្យញ្ជនៈនិងស្រៈ វាចប់ វាយបាន។ ព្រោះខ្ញុំក៏មិនមានរៀនអីច្រើន គ្រាន់តែដឹងអក្សរហ្នឹងដែរ។ រៀនចេះបានតិចតួចប្រើការអីអត់កើត អត់ដឹងថាអីខុស

អីត្រូវ តែគ្រាន់តែដឹងថាអាណាហៅ “អា”, ហៅ “បេ”, ហៅ “សេ” អីហ្នឹង ចេះ។ អានបានខ្លះតិចតួច អត់ប្រើការអីជា១ធំដុំកើតទេ ហើយអ្នកដែលមករៀនហ្នឹង ដែលយកមកហ្នឹង ភាគច្រើនយកមកបង្រៀន អា, បេ, សេ, ដេ ហ្នឹងវិញទេ។ ដល់រៀនអាហ្នឹងចេះដឹងហើយ បានឲ្យរៀនវាយ។ ហ្នឹងជាបច្ចេកទេស ដែលដំណើរការមក ដល់រៀនវាយគេយកម្រាមដៃឲ្យដឹងថាអក្សរណាប្រើអក្សរអី គឺចាំម្រាមដៃវិញទេ។ ហើយដល់វាយហ្នឹង គឺថាមើលតែអត្ថបទទេ អាណាគេអានម៉េចវាយតាមអក្សរដែលគេនេះហ្នឹងទៅ អាណាត្រូវឃ្លាចុចកន្លែងឃ្លាទៅ។ នេះដែលវិធីរៀនបច្ចេកទេសរៀនជំនាន់ហ្នឹង គឺរៀនអ៊ីចឹង។ ខ្ញុំសូមមតិប៉ុណ្ណឹងពីរឿងវាយអង្គុលីលេខបាទ។ សូមអស់យោបល់។

[១៤:៣០:៤១]

**ស៖** តើលោកពិតជាបានវាយអត្ថបទទូរលេខ ដែលគេប្រើប្រាស់ដើម្បីបញ្ជូនចេញទៅក្រៅ តើមែនដែរឬទេ?

**ឆ៖** សំណួរនេះពីមុនរឿងបញ្ចេញទៅក្រៅ មិនទាន់បានឆ្លើយមិនទាន់បាន សួរដែរ តែនេះជាសំណួរមួយថ្មី។ ខ្ញុំនៅចាំបានថា ពេល នួន ជា ចូលមកហើយ បានការផ្សាយចេញក្រៅនេះបានមានការផ្សាយ។ តែការវាយស្អី១នេះ និងអត្ថបទដែលគេឲ្យមកនេះ គឺថាខាងខ្ញុំខាងបច្ចេកទេសនេះ ការពិតអត់ដឹងខ្លឹមសារអីគេយ៉ាងម៉េចទេ គ្រាន់តែថាឯកសារគេឲ្យយើងមើលទៅ ហើយយើងធ្វើតាមបែបបទគេទៅ។ តែដល់ធ្វើហើយ ស្រុកគេជឿលឿនមិនដឹងយ៉ាងម៉េចទេ តែគ្រាន់តែអង្កាល់ហ្នឹងគឺថាយើងវាយហើយ យើងធ្វើជាខ្សែអាត់ អាខ្សែអាត់ចាក់ហ្នឹង។ ព្រោះមានកន្លែង អាមានរន្ធប្រហោងហ្នឹង អាហ្នឹងចេញអក្សរ អាអត់ហ្នឹងវានេះហើយ។ ដល់អ៊ីចឹងអក្សរមួយ១ វាមានរន្ធខុសគ្នា ដល់អ៊ីចឹងធ្វើអាខ្សែអាត់ហ្នឹងចាក់ទៅ។ ហើយដល់អ៊ីចឹងអក្សរវា១ អក្សរបារាំងប៉ុន្មានតួហ្នឹង គឺថាវាមានរន្ធវាតម្រូវឲ្យអក្សរមួយ១វារន្ធខុសគ្នា ដល់អ៊ីចឹងគេប្រើអាហ្នឹងដើម្បីមកចោះអក្សរហ្នឹង ចាក់បញ្ចេញទៅ។

ហើយរឿងខ្លឹមសារអីយល់យ៉ាងម៉េច១ ខ្ញុំអត់១យល់ទេ ខ្ញុំយល់តែពីរឿងបច្ចេកទេសខ្ញុំធ្វើម៉េចឲ្យអក្សរហ្នឹងចេញក្រៅបាន បញ្ជូនទៅបាន។ នេះសូមអស់មតិ។

[១៤:៣២:២៩]

**ស៖** លោកនិយាយថា លោកគ្រាន់តែធ្វើការណែនាំនៅពេលដែលលោកធ្វើការខាងទូរលេខហ្នឹង តើអ្នកណាជាអ្នកបញ្ជា ឬក៏អ្នកណាជាអ្នកចេញនូវការណែនាំមកដល់រូបលោកនោះ?

**ឆ៖** ការដែលរៀបចំចេញហ្នឹង កាលហ្នឹងជំនាន់ យុន យ៉ាត មុនដកចេញ ដែលគាត់ប្រគល់ឲ្យ

ខ្ញុំនូវកម្លាំងថ្មីហ្នឹងហើយ គាត់ក៏ប្រាប់ថា "មិត្តឯងខំបណ្តុះបណ្តាល គឺថាដល់ខែនេះឆ្នាំនេះ យើងនឹងផ្សាយបញ្ចេញ រៀបចំផ្សាយបញ្ចេញ"។ ហើយដល់អ៊ីចឹងខ្ញុំគ្រាន់តែក្នុងន័យដែលអស់កម្លាំង ខ្ញុំខំបណ្តុះកម្លាំងនេះដើម្បីធ្វើការ។ ហើយដល់អ៊ីចឹងកំណត់ពេលវេលា និងថ្ងៃខែថាចេញថ្ងៃណាអីថ្ងៃណា ខ្ញុំៗចាំមិនបាន តែគ្រាន់តែដឹងថា ចុងៗឆ្នាំដែល យុន យ៉ាត គាត់ៗរៀបនឹងឈប់ ហើយគាត់បញ្ជូនកម្លាំងហ្នឹងមកឲ្យខ្ញុំ។ ដល់ខ្ញុំបណ្តុះបណ្តាលទៅក្រោយមកក៏មានការផ្សាយចេញបន្តទៅ។ នេះសូមមតិប៉ុណ្ណឹង។

**ស៖** តាមការបកប្រែជាភាសាអង់គ្លេសមកខាងយើងខ្ញុំ គឺបញ្ជាក់ថាមុនពេលដែល យុន យ៉ាត ត្រូវបានគេដកចេញ។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើ យុន យ៉ាត ត្រូវបានគេដកចេញ ឬមួយក៏នៅពេលដែលលោកឈប់ធ្វើការនៅក្រសួង? តើហេតុផលមួយណាដែរ?

[១៤:៣៤:១៧]

**ឆ៖** រឿង យុន យ៉ាត គាត់ចេញ ក៏ខ្ញុំអត់ដឹង អត់ដឹងថាមូលហេតុអី អត់ដែរ។ ហើយ នួន ជា គាត់មកទទួលវិញ ក៏ខ្ញុំអត់ដឹងថា មកពី យុន យ៉ាត យ៉ាងម៉េច បានតែ នួន ជា មកវិញ ក៏ខ្ញុំអត់ដឹង។ តែគ្រាន់ថាការងារដែលខ្ញុំធ្លាប់ជួបប្រទះ គឺថាវាមានដំណើររបៀបអ៊ីចឹង។ សូមចប់មតិ។

**ស៖** ឥឡូវនេះខ្ញុំចង់លើកយកនូវប្រធានបទមួយដែលយើងបានពិភាក្សារួចមកហើយ គឺទាក់ទងទៅនឹងការបាត់ខ្លួនរបស់បុគ្គលិកនៅក្រសួងរបស់លោក។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយអ្នកស៊ើបអង្កេតលោកបាននិយាយថា "មនុស្សពីររូប មួយឈ្មោះ សំ, មួយឈ្មោះ ហ៊ុន ក៏បានបាត់ខ្លួនផងដែរ"។ គឺឯកសារដែលមានលេខ E3/438, ភាសាអង់គ្លេសមានលេខ 00375873, ភាសាខ្មែរគឺមានលេខ 00373433, ភាសាបារាំងគឺមានលេខ 00426431។ ខ្ញុំចង់សួរលោកជាដំបូងអំពីមនុស្សម្នាក់ឈ្មោះ សំ។ តើ សំ ហ្នឹងគឺជាមនុស្សតែមួយដែលលោកបាននិយាយពីមុនថា ជាប្រធាន ក-៣៣ និងជាកូន ហ៊ូ នឹម នោះតើមែនដែរឬទេ?

**ឆ៖** បាទ ឈ្មោះ សំ ហ្នឹងគឺបើតាមខ្ញុំនៅចាំបានគឺថា មានតែមួយហ្នឹងទេដែលៗនៅ ក-៣៣ ហ្នឹង។ ហើយកាលហ្នឹងក៏ទទួលក្នុងនាមជាប្រធានមន្ទីរ ក-៣៣ ហ្នឹង។ បាទ សូមអស់ប៉ុណ្ណឹង។

[១៤:៣៦:៣៤]

**ស៖** ដើម្បីកំណត់ត្រា ខ្ញុំសូមកត់ត្រាថា សំ គឺត្រូវបានចុះបញ្ជីជាអ្នកទោសនៅក្នុងបញ្ជីអ្នកទោស ស-២១ ដែលបានកែតម្រូវដែលមានឯកសារលេខ E3343*(ស៊ីក)* ហើយភាសាខ្មែរ និងភាសាអង់គ្លេសមានលេខ ERN 00329840 ហើយគាត់ត្រូវបានគេចុះជាអ្នកទោសមានលេខ ៥៦១៩ ហើយ

ចុះជាកម្មាភិបាលនៃ ក-៣៣ ហើយត្រូវបានចាប់ខ្លួនចេញពីក្រសួងឃោសនាការនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ហើយសម្លាប់នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ៧៧។ ខ្ញុំចង់សួរលោកអំពីបុគ្គលម្នាក់ទៀតឈ្មោះ ហ៊ុន តើលោកចាំដែរឬទេថា ហ៊ុន ហ្នឹងគាត់ធ្វើការនៅមន្ទីរណាមួយដែរ?

**ឆ៖** បាទ ឈ្មោះ ហ៊ុន នេះក៏ធ្វើការនៅក្នុងមន្ទីរ ក-៣៣ ហ្នឹងដែរ តែគ្រាន់ថា ការងារគេដោយឡែកពីការងារខ្ញុំ។ សូមអស់មតិបាទ។

[១៤:៣៧:៥៣]

**សៈ** សូមអរគុណលោក។ តើលោកអាចជម្រាបបានដែរឬទេ រហូតមកដល់ពេលណាដែលមានការបាត់ខ្លួនបុគ្គលិកដែលមកពីខាងបូព៌ាហ្នឹង? តើគេបន្តរហូតទៅដល់ពេលណាដែរការបាត់ខ្លួននុ៎ង?

**ឆ៖** ការបាត់ខ្លួនមកពីខាងបូព៌ាហ្នឹង បើនៅក្នុងកន្លែងខ្ញុំហ្នឹង ខ្ញុំគ្រាន់តែដឹងថា មួយពេលដែលចាប់ ហ៊ូ នឹម ហើយហ្នឹង គឺពួកហ្នឹងគេចេះតែ ដូចថាយកចេញបន្តបន្ទាប់ទៅ ហើយខ្ញុំក៏មិនដឹងរឿងថារឿងអីៗ យកទៅណាមកណាខ្ញុំអត់ដឹងទេ។ ហើយក្នុងការដែលសួរខ្ញុំឆ្លើយមុន គឺក្រោយមកបានសេចក្តីថា អ្នកដែលចេញមុនហ្នឹងទៅបាត់ហើយ ដល់អ៊ីចឹងយកមនុស្សថ្មីបញ្ចូលមកនុ៎ង ពីខាងនិរតីបញ្ចូលមកវិញ អ៊ីចេះ។ ហើយដល់និរតីមកវិញ អ៊ីចឹងក្នុងៗកន្លែងហ្នឹងវាដូចថា សឹងបាត់អស់ហើយពួកខាងបូព៌ា ដូចថា គេទៅមួយសាទៅ ដូចចង់អស់។ នេះគ្រាន់តែឃើញទិដ្ឋភាពនៅក្នុងកន្លែងខ្ញុំហ្នឹងវាអ៊ីចឹង។ ហើយដល់យកខាងនិរតីមក ឯសភាពការណ៍តទៅមុខទៀងអីយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ ដឹងតែថា ក្នុងកន្លែងខ្ញុំមានមនុស្សមកថ្មីហ្នឹង ខ្ញុំគិតរឿងការងាររបស់ខ្ញុំបន្តទៀតទៅ។ នេះចប់ប៉ុណ្ណឹងបាទ។

[១៤:៣៩:២៣]

**សៈ** តើការបាត់ខ្លួនបុគ្គលិកក្រសួងហ្នឹងបន្តរហូតដល់ពេលដែលគេ -- នៅពេលដែល យុន យ៉ាត ចូលមកបន្តការងារ ហើយវាបន្តរហូតដល់ពេលដែល នួន ជា មកបន្តទៀត ឬមួយក៏យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេ ប៉ោះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់កុំឲ្យមានការយល់ច្រឡំដល់សាក្សី គឺថាគួរតែមេធាវី

ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការបែងចែកសំណួរ ឬក៏កាត់ផ្ដាច់សំណួរជាកង់ៗ ដើម្បីឱ្យសាក្សីមានភាពងាយស្រួល។

**លោកស្រី បេនី យេ៖**

**ស៖** ដូច្នេះ ខ្ញុំសូមសួរលោកតែផ្នែកដំបូង។ តើការបាត់ខ្លួនរបស់បុគ្គលិកក្រសួងហ្នឹងបន្តរហូតសូម្បីតែពេលដែល យុន យ៉ាត មកបន្តកាន់តំណែងហ្នឹង ក៏នៅតែមានការបាត់ខ្លួន ឬមួយក៏យ៉ាងណាដែរ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ។ ពេល យុន យ៉ាត ចូលមក ការបន្តបាត់ខ្លួននេះ ខាងក្រៅខ្ញុំមិនដឹងទេ តែគ្រាន់តែថា ទិដ្ឋភាពក្នុងក្រសួងហ្នឹង វាហាក់ដូចជាមានសភាពស្ងាត់មួយរយៈ។ ដោយសារអី? ដោយសារមនុស្សមក អ្នកៗដែលចេញទៅវាចេញទៅបាត់ហើយ តែអ្នកមកនោះគឺថា វាសឹងតែថា ថ្មីៗវិញអស់ហើយ ដល់អ៊ីចឹងវាៗដូចវាស្ងាត់ ដល់អ៊ីចឹងទិដ្ឋភាពក្រៅទៀត ខ្ញុំអត់ដឹង តែក្នុងកន្លែងខ្ញុំហ្នឹង គឺវាមានសភាពស្ងាត់ស្ងៀមមួយរយៈ។ នេះសូមមានមតិប៉ុណ្ណឹង។

[១៤:៤១:១២]

**ស៖** ហើយនៅពេលដែលលោកនិយាយថា គេស្ងាត់មួយរយៈហ្នឹង តើមានន័យថា ការបាត់ខ្លួនហ្នឹងចាប់ផ្ដើមសាជាថ្មីនៅពេលក្រោយមកទៀត ឬមួយក៏យ៉ាងណាដែរ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ក្រោយមកទៀតដែលខ្ញុំទទួលបានកម្លាំងពីនិរតីមកបណ្ដុះបណ្ដាលហើយនេះ គឺថានៅកន្លែងខ្ញុំដូចជា តាមខ្ញុំចាំដូចជាមិនមានការដកហូតអីមនុស្សទៀតទេ។ ឯកន្លែងមន្ទីរអីផ្សេងៗក្រៅពីមន្ទីរខ្ញុំ អាហ្នឹងខ្ញុំអត់ដឹងទេ ក្រៅពីជំនាញរបស់ខ្ញុំ តែក្នុងជំនាញរបស់ខ្ញុំក្នុងការិយាល័យដែលពាក់ព័ន្ធនឹងកន្លែងខ្ញុំហ្នឹង ដែលខ្ញុំដឹងខ្លះគឺថា ដូចមិនមានការអីប្រែប្រួល ឬបាត់អីបន្តបន្ទាប់ទៀតទេអត់ទេ។ នេះសូមមានមតិប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក ផ្ដល់នូវបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់

សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០៩ នាទី)*

[១៥:០៩:៤៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី បេនី យេះ៖**

សូមអរគុណលោកប្រធាន។ សូមអរគុណ។

**សួរដោយលោកស្រី បេនី យេះ៖**

**ស៖** មុនពេលសម្រាកនេះ យើងបានពិភាក្សាអំពីថា តើរយៈពេលនៃការបាត់ខ្លួនមនុស្សនៅក្រសួងនោះរយៈពេលប៉ុនណា? ឥឡូវនេះ ខ្ញុំចង់សួរលោកថា តើការបាត់ខ្លួននោះបន្តមានទេនៅពេលដែល នួន ជា គាត់មកទទួលបន្ទុកនៅក្រសួងនោះ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយបន្តនូវសំណួរនេះ ព្រោះអំមិញខ្ញុំបានឆ្លើយមួយសាដែរតែ រយៈពេលដែល នួន ជា គាត់មកទទួលការងារនៅក្នុងមន្ទីរ ក-៣៣ នេះ ការបាត់បង់កម្លាំងបន្ថែមក៏វាមានការស្ងប់ស្ងាត់ទៅវិញ ព្រោះអ្នកដែលមករួមធ្វើការងារក្រៅនេះ សុទ្ធតែមនុស្សទើបតែមកថ្មី។ ដល់អ៊ីចឹងអ្នកដែលបាត់បង់ទៅហ្នឹង គឺគេដកទៅណាមកណា ខ្ញុំអត់ដឹង តែដល់តែអ្នកថ្មីមកហ្នឹង គឺថាការបាត់បង់សម្រាប់អ្នកថ្មីទៀតនេះ ដូចជាមិនឃើញមានអីដែរបាត់បង់បន្ថែមទេ។ នេះតាមការដែលខ្ញុំចាំបាន។ សូមអស់មតិ។

[១៥:១២:០០]

**ស៖** ដើម្បីបំភ្លឺបញ្ហានេះ លោកប្រធានសូមអនុញ្ញាតដើម្បីអានជូនសាក្សីស្តាប់នូវសេចក្តីដកស្រង់មួយពីបទសម្ភាសន៍របស់គាត់ ជាមួយសហចៅក្រមស៊ើបអង្កេត ឯកសារ E3/438 អង់គ្លេស ERN 00375876, ខ្មែរ ERN 00373436, បារាំង ERN 00426433។ នៅលើទំព័រនេះ សាក្សីទទួលបានសំណួរដូចខាងក្រោមនេះ "រហូតដល់ពេលណាដែលនយោបាយនេះត្រូវបានយកមកអនុវត្ត?" ចម្លើយនោះឆ្លើយថា "គោលនយោបាយនេះនៅជិតដាមរហូត ទោះបីជា នួន ជា ចង់ឲ្យលែងនិយាយអំពីបញ្ហាបែងចែកប្រជាជនថ្មី និងប្រជាជនចាស់ក៏ដោយ ហើយនៅមានការបាត់ខ្លួនជាបន្តបន្ទាប់ដដែល"។ ចប់សេចក្តីដកស្រង់។

ឥឡូវនេះ លោកសាក្សី ខៀវ អេន នៅក្នុងពេលដែលលោកឆ្លើយទៅអ្នកស៊ើបអង្កេត លោកបានឆ្លើយបែបនេះ។ ថ្ងៃនេះលោកនិយាយថា នៅពេលដែល នួន ជា មកទទួលបន្ទុកថាមិនមានការបាត់ខ្លួនទេ។ តើលោកអាចបំភ្លឺចំណុចនេះជូនតុលាការបានឬទេ?

**ឆ៖** ចំណុចនេះខ្ញុំអាចបំភ្លឺជូនបាន។ បានក្នុងន័យថា នួន ជា ដែលចូលមកទទួលនៅក្នុងមន្ទីរ ក-៣៣ នេះវាជាទិដ្ឋភាពដែលបាត់បង់កម្លាំងក្នុង ក-៣៣ ហ្នឹងទៀតនេះ វាអត់មានទេ។ តែជាការឮការដឹងពីក្រៅៗខ្លះ អាហ្នឹងនៅមាន បាទនៅមាន។ ដូចថា វាដឹងជាសភាពខាងក្រៅយ៉ាងម៉េច តែវាឮថា អ្នកនេះគេដក អ្នកនោះគេដក។ បញ្ហាហ្នឹង គេឮ។ តែការឃើញថា ដកដាក់ស្លែង អាហ្នឹងអត់បានឃើញទេ។ តែពាក្យថា "អ៊ូ អ្នកនេះគេថា គេដកចេញពីកន្លែងនេះ។ អ្នកនោះ ត្រូវគេដកចេញពីកន្លែងនោះ"។ ពាក្យនេះនៅមានៗបាទ។ អ៊ីចឹងបានដែលខ្ញុំបញ្ជាក់មកវិញថា ពេលដែល នួន ជា មកហ្នឹង គឺថាកន្លែងខ្ញុំអត់មានបញ្ហាទេ។ តែដល់ខាងក្រៅហ្នឹង វានៅទិដ្ឋភាព នៅៗឮ នៅដកអ្នកនេះ ដកអ្នកនោះអី ជាទិដ្ឋភាពខាងក្រៅ តែជាការដែលខ្ញុំគិតឃើញផ្ទាល់នោះ ខ្ញុំអត់បានឃើញទេ។ អានេះជាការស្តាប់ ការដឹង ការឮពេលហ្នឹង។ ការឃើញ មិនបានឃើញទេ។ សូមអស់មតិបាទ។

[១៥:១៥:០៧]

**ស៖** តើខ្ញុំអាចប្រាប់ខ្ញុំបានទេថា តើនៅមន្ទីរណាខ្លះដែលលោកនិយាយថានៅមានបន្តការបាត់ខ្លួននោះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ តែគ្រាន់តែថានៅក្នុង ក-៣៣ហ្នឹង ក្រៅពី ក-៣៣ ទៀតគឺថាវាមានមន្ទីរដែលនៅជុំវិញរបស់ក្រសួងហ្នឹងច្រើនទៀត។ ដល់អ៊ីចឹងគេអ្នកហើរច្រើនហ្នឹង គេៗអ្នកចេញចូលទៅៗ

មន្ទីរនេះមន្ទីរនោះ គេដឹងរឿង ហើយដល់ខ្ញុំអ្នកដើរហ្នឹង ខ្ញុំអត់ដឹងទេ អត់ដឹងខ្ញុំនៅតែកន្លែង។ ហើយដល់អ៊ីចឹងឮការនិយាយអីពីគេទេ នេះសូមខ្ញុំជូនមតិប៉ុណ្ណឹងបាទ។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចូលទៅរកប្រធានបទថ្មីមួយទៀតដែលសហមេធាវីរបស់ខ្ញុំបានសួរបន្តិចមកហើយ អំពីការផ្សឹកព្រះសង្ឃ។ តើលោកអាចប្រាប់តុលាការបានឬទេថា តើនៅភូមិរបស់លោកហ្នឹងការផ្សឹកព្រះសង្ឃហ្នឹង គឺកើតឡើងនៅពេលណា? ហើយនិងការបញ្ជូនព្រះសង្ឃទៅកន្លែងការងារ ការដ្ឋានធ្វើការងារនោះបាទ?

[១៥:១៦:៣៧]

**ឆះ** ខ្ញុំសូមឆ្លើយ សំណួរនេះ បើៗគិតកាលវេលា ខ្ញុំកំណត់ឲ្យខ្ញុំកំណត់មិនបានទេ ប៉ុន្តែគ្រាន់តែថា មុនដែលខ្ញុំចេញពីភូមិនេះ ការផ្សឹកព្រះសង្ឃនេះវាជាការផ្សឹកមុនទាហាន លន់ នល់ ចូល។ បាទព្រោះខ្ញុំជម្រាបជូនថា ភូមិខ្ញុំហ្នឹងវា -- ក្នុងឯកសារខ្ញុំមានបញ្ជាក់ហើយ វាៗជាតំបន់មួយសម័យហ្នឹងគេហៅថាជា “តំបន់ប្រទាញប្រទង់ បាទ ប្រទាញប្រទង់”។ ពេលថ្ងៃទាហាន លន់ នល់ នៅទៅធ្វើបន្ទាយនៅក្នុងបន្ទាយវាដើរចេញល្បាតទៅ តែដល់យប់ខាងបដិវត្តន៍ហ្នឹងចូលៗមកក្នុងភូមិហ្នឹងវិញមក។ ដល់អ៊ីចឹងសភាពការណ៍ដែលផ្សឹកព្រះសង្ឃហ្នឹង គឺថាមុនពេលហ្នឹងៗ ដែលទាហាន លន់ នល់ មិនទាន់ចូលហ្នឹង គឺថាបដិវត្តន៍នៅគឺពេលហ្នឹងគេៗផ្សឹក គេមានការផ្សឹកព្រះសង្ឃ គឺខាងគាត់មិនឲ្យបួសមិនឲ្យអីគឺថាមាន។ តែដល់ទាហាន លន់ នល់ ចូលមកទៀតអ្នកបួសក៏ចាប់បួសវិញដែរៗ។ តែដល់ទាហាន លន់ នល់ ចាញ់ទៅពួកនេះត្រូវផ្សឹកវិញៗ។ នេះជាកាលបរិច្ឆេទពេលវេលាអី ខ្ញុំមិននេះ ប៉ុន្តែគ្រាន់តែថា កាលដែលខ្ញុំនៅ ខ្ញុំមិនទាន់ដកខ្លួនចេញមកធ្វើបដិវត្តន៍ហ្នឹង គឺថាខ្ញុំជួបទិដ្ឋភាពហ្នឹង និងសភាពការណ៍នៅក្នុងភូមិខ្ញុំអ៊ីចឹង។ សូមអស់មតិ។

[១៥:១៨:៣៥]

**សៈ** តើលោកដឹងដែរឬទេថា អ្នកណាជាអ្នកបញ្ជាឲ្យព្រះសង្ឃទាំងអស់នោះលាចាកសិក្ខាបទនោះ?

**ឆះ** ខ្ញុំសូមឆ្លើយ កាលហ្នឹងការបញ្ជាមកពីណាៗមិនដឹងទេ តែគ្រាន់តែអ្នកដែលៗធ្វើបដិវត្តន៍នៅនឹងភូមិខ្ញុំហ្នឹង ដែលគេៗមើលខុសត្រូវនៅក្នុងភូមិខ្ញុំហ្នឹង គេអ្នកបញ្ជាឲ្យសឹក។ តែជាការមានឯកសារអី មានបទបញ្ជាអីពីថ្នាក់ណាៗទៀត ខ្ញុំអត់ដឹងទេ គ្រាន់តែឃើញការដែលលោកសង្ឃត្រូវបានផ្សឹកដោយពួកអ្នកនៅខាងភូមិខ្ញុំហ្នឹង។ សូមអស់មតិប៉ុណ្ណឹងបាទ។

**ស៖** តើអ្នកនោះបានពន្យល់ដែរឬទេថា ហេតុអ្វីបានជាត្រូវផ្សឹកព្រះសង្ឃនោះ?

**ឆ៖** ខ្ញុំសូមឆ្លើយថា ការយល់ដឹងពីការផ្សឹកព្រះសង្ឃអីនេះ ខ្ញុំដូចជាមិនបានស្វែងយល់អីទេ គ្រាន់តែថាកាលហ្នឹងចេះតែគិតខ្លួនឯងថា គេឲ្យផ្សឹកព្រះសង្ឃឲ្យអី ក៏យើងមិនប៉ានជំទាស់ប៉ានអីដែរ។ គ្រាន់ថាសភាពការណ៍ត្រូវផ្សឹក អាហ្នឹងខាងគេអ្នកផ្សឹក យើងជាប្រជជន យើងអត់ប៉ាននិយាយស្តីអីពីរឿងហ្នឹងទេ គឺថាធ្វើទៅតាមដំណើរដែលៗសភាពការណ៍ក្នុងស្រុករបស់យើងវាអ៊ីចឹង វាទៅតាមដំណើរអ៊ីចឹងទៅ។ ដល់អ៊ីចឹងពីរឿងថាការយល់ខ្លួនឯង ឬមួយក៏បានរៀនពីទ្រឹស្តីអីនយោបាយអីខាងនុ៎ងថា គេមិនឲ្យនៅអ៊ីចេះអ៊ីចុះ មកពីអ៊ីចេះអ៊ីចុះ ខ្ញុំអត់បានយល់ដឹងអីច្រើនទេបាទ។ សូមអស់មតិបាទ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងចូលទៅដល់ប្រធានបទចុងក្រោយនៃសំណួររបស់ខ្ញុំ។ ចំពោះប្រធានបទនេះ ខ្ញុំចង់ដឹងថាតើលោកបានរៀបអាពាហ៍ពិពាហ៍នៅពេលណា តើរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬពេលណា?

[១៥:២១:១៤]

**ស៖** ខ្ញុំសូមឆ្លើយ។ ខ្ញុំ -- រឿងរៀបអាពាហ៍ពិពាហ៍ពេល ចង់និយាយថា តាំងពីនេះ តាំងពីខ្ញុំជួបឆ្លងកាត់មក គឺថាខ្ញុំទៅរៀបនៅតាមព្រំដែនថៃឯណោះទេ។ បើនៅក្នុងស្រុកខ្ញុំអត់នេះទេ ខ្ញុំអត់បានរៀបអីទេ គឺថាខ្លួនមួយ ដោយសារថាឃើញសង្គ្រាមអ៊ីចឹងវាពិបាកមានប្រពន្ធកូនអ៊ីចេះអ៊ីចុះ ក៏ចេះតែមិនព្រមរៀបទៅ ដល់អ៊ីចឹងក៏អាយុកាន់តែច្រើនទៅ ដល់ខ្ញុំទៅបានមានប្រពន្ធមានអីហ្នឹង គឺថាខ្ញុំនៅទទួលរៀបចំនៅខ្សែព្រំដែនណោះទេ។ នេះសូមមានមតិប៉ុណ្ណឹង។

**ស៖** តើលោកអាចបញ្ជាក់ពេលវេលាបានដែរឬទេ តើមុននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឬក៏ក្រោយពីហ្នឹង ដែលលោកបានរៀបអាពាហ៍ពិពាហ៍នោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ដោយខ្លីថា ការរៀបអាពាហ៍ពិពាហ៍ខ្ញុំនេះ គឺដែលខ្ញុំបញ្ជាក់អំមិញថានៅខាងតាមខ្សែព្រំដែន គឺពេលដែលខ្ញុំដកខ្លួនចេញពីភ្នំពេញហើយ។ ដល់អ៊ីចឹងបើគិតឆ្នាំ ដូចជា១៩៨៣ អីនេះហើយ តាមមើលខ្ញុំគិតខ្លួនខ្ញុំ។ ព្រោះខ្ញុំដឹងថា តាមអាយុកាលរបស់ខ្ញុំប្រហែលជាខ្ញុំអាយុ២៧ បាទ។ អំ! អាយុខ្ញុំ៣០ គ្រួសារខ្ញុំអាយុ២៧ បាទ បានរៀប។ សូមអស់មតិបាទ។

[១៥:២៣:០៧]

**លោកស្រី បេនី យេះ**

សូមអរគុណលោក ខៀវ អេន។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ។ សូមអរគុណដែលលោកបាន

ឆ្លើយសំណួររបស់ខ្ញុំទាំងអស់។ សូមឲ្យលោកវិលត្រឡប់ទៅលំនៅដ្ឋានវិញដោយសុវត្ថិភាព។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តើអស់លោក លោកស្រីចៅក្រមមានសំណួរសួរដល់សាក្សីរូបនេះ? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរតូចមួយ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី បើតាមលោកដឹង នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើមានផ្នែកដូចគ្នាទៅនឹងផ្នែកមួយដែលលោកធ្វើការនៅក្រសួងឃោសនាការ តើមានផ្នែកណាផ្សេងទៀតដែលទទួលបន្ទុកក្នុងការស្ដាប់ដំណឹងជាតិ -- អន្តរជាតិ សូមទោស ហើយនិងបញ្ជូនបន្តនោះ?

[១៥:២៤:១៩]

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ផ្នែកដោយឡែកទៀតដែលក្រៅពីផ្នែកខ្ញុំក្នុងការស្ដាប់ដំណឹងអីនោះ គឺបើក្រៅពីក្រសួងរបស់ខ្ញុំនោះ ខ្ញុំអត់ដឹងទេ។ តែបើក្នុងក្រសួងរបស់ខ្ញុំ ខ្ញុំគ្រាន់តែដឹងថាគេមានផ្នែករបស់គេមួយ គេស្ដាប់ជាវិទ្យុ បាទស្ដាប់ជាវិទ្យុផ្សាយសំឡេងអីចឹង។ ដល់អីចឹង ដំណឹងដែលខ្ញុំបញ្ជូនទៅអាហ្នឹង ខ្ញុំមិនៗយល់ជ្រៅអីខាងហ្នឹងទេ តែគ្រាន់តែដឹងថាគេយកទៅផ្ទៀងផ្ទាត់ជាមួយនឹងការស្ដាប់របស់គេ តើវាមានដំណឹងអីហ្នឹង វាបើគេផ្សាយដូចគ្នាហ្នឹង តើខាងយើងនេះយ៉ាងម៉េច ខាងស្ដាប់នេះយ៉ាងម៉េច។ នេះខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹងបាទ។ ហើយបើក្រៅពីក្នុងក្រសួងខ្ញុំ ខ្ញុំអត់ដឹងទៀតទេ។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំនូវចម្លើយរបស់លោកនោះទេ គឺថាការងាររបស់លោកនោះតម្រូវឲ្យមានសម្ភារៈពិសេសចាំបាច់ ហើយនិងតម្រូវឲ្យមានមនុស្សដែលមានសមត្ថភាពជាក់លាក់ដើម្បីធ្វើកិច្ចការនោះ។ ដូច្នេះខ្ញុំចង់សួរលោកឲ្យបានច្បាស់ ថាតើបើតាមលោកដឹង តើមានសម្ភារៈបែបគ្នាដូចនេះដែរមាននៅទីក្រុងភ្នំពេញ ហើយនិងមានអ្នកផ្សេងទៀតដែលមានសមត្ថភាពដូចគ្នានេះដែរនៅភ្នំពេញដូចកន្លែងរបស់លោកដែរទេ? ឬមួយក៏មានតែកន្លែងរបស់លោកមួយទេដែលមានសមត្ថភាពអាចបំពេញ

ការងារបែបនេះនោះ?

[១៥:២៦:២១]

**ឆ៖** សំណួរនេះខ្ញុំគ្រាន់តែការចាប់អារម្មណ៍របស់ខ្ញុំទេ។ ចាប់អារម្មណ៍ក្នុងន័យថា ការងារហ្នឹង ខ្ញុំអត់ដឹង ខ្ញុំគ្រាន់តែដឹងត្រឹមថា គេមានយកម៉ាស៊ីនមួយគ្រឿងមកឲ្យខ្ញុំធ្វើ ជាម៉ាស៊ីនបែបទូរពុម្ពហ្នឹងដែរ អាម៉ាស៊ីនអង្គុលីលេខហ្នឹង។ ដល់អ៊ីចឹងខ្ញុំគ្រាន់តែគិតថា សំណួរលោកចៅក្រមសួរហ្នឹង កំពុងតែគិតថា ប្រហែលជាមានកន្លែងផ្សេងទៀត តែខ្ញុំមិនដឹង ព្រោះមានម៉ាស៊ីនហ្នឹងមកឲ្យខ្ញុំធ្វើ។ នេះខ្ញុំសូមជម្រាបជូនប៉ុណ្ណឹង បាទ។

**ស៖** តើនៅក្នុងពេលណាមួយ នៃពេលដែលលោកបំពេញការងារនៅក្នុងក្រសួងឃោសនាការ លោកធ្លាប់ដឹងថាមានទំនាក់ទំនងរវាងឃោសនាការ ជាមួយនឹងក្រសួងការបរទេស? តើលោកដឹងថាមានទំនាក់ទំនងបែបនេះរវាងក្រសួងទាំងពីរនេះទេ?

**ឆ៖** ក្រសួងទាំងពីរនេះពីមុនមកខ្ញុំអត់មានដឹងអីទាំងអស់ បាទ មិនដឹងមានការទំនាក់ទំនងអីយ៉ាងម៉េចទេ។ តែពេលដែលសំណួរនេះលើកឡើង ខ្ញុំគ្រាន់តែគិតថា ពេលដែលចុងក្រោយរៀបចេញហ្នឹង រៀបចេញពីភ្នំពេញហ្នឹងមានកម្លាំងពីក្រសួងការបរទេស បញ្ជូនមកឲ្យនៅកន្លែងខ្ញុំពីរបីនាក់អ៊ីចេះ។ តែឈ្មោះអីៗ ខ្ញុំអត់ស្គាល់ទេ អត់ដឹងខាងលើគេបញ្ជូនមកប្រគល់ឲ្យខាងប្រធាននៅកន្លែងខ្ញុំហ្នឹង ហើយខ្ញុំអត់ដឹង ដល់សួរ ថាមកពីខាងក្រសួងការបរទេស។ នេះដឹងបានប៉ុណ្ណឹង ពេលចុងក្រោយរៀបចេញពីភ្នំពេញបាទ។

[១៥:២៨:៣៧]

**ស៖** ខ្ញុំគិតថា នៅក្នុងចំណោមព័ត៌មានអន្តរជាតិដែលត្រូវបានស្តាប់ ហើយនិងផ្សាយបន្តនោះ គឺថាមានព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន ដែលគាត់និយាយ ថ្លែងទៅកាន់ប្រមុខរដ្ឋបរទេស។ តើលោកដឹងទេថា ផ្នែករបស់លោកក៏ផ្សាយព័ត៌មានមួយចំនួនទៅកាន់ប្រធានគណៈប្រធានរដ្ឋ គឺលោក ខៀវ សំផន ដែរនោះ?

**ឆ៖** ខ្ញុំ -- បើមកជាភាសាបរទេសហ្នឹង ខ្ញុំបានត្រឹមធ្វើជាៗអាក្រដាសស្នាមដើម្បីបញ្ចេញទៅការយល់ដឹងនូវខ្លឹមសារហ្នឹង ខ្ញុំអត់ដឹង។ តែគ្រាន់តែថា ឯកសារហ្នឹងបញ្ជូនមកខ្ញុំហើយ ខ្ញុំធ្វើឯកសារហ្នឹងដើម្បីចាក់បញ្ចេញផ្សាយទៅ អាហ្នឹងខ្ញុំធ្វើ ខ្ញុំបានធ្វើ តែជាខ្លឹមសារអីក្នុងហ្នឹង ខ្ញុំ ក្នុងការផ្សាយបញ្ចេញបន្តហ្នឹង ខ្លឹមសារអីខ្ញុំអត់យល់ អត់ដឹងទាំងអស់។ សូមមានមតិប៉ុណ្ណឹង។

**ស៖** សំណួរចុងក្រោយលោកសាក្សី។ លោកសាក្សីក្នុងពេលដែលលោកបំពេញការងារនៅក្រសួងឃោសនាការ តើលោកធ្លាប់ឮគេនិយាយអំពីឈ្មោះ ហ៊ូ យន់ ទេ?

[១៥:៣០:០០]

**ឆ៖** ខ្ញុំធ្វើការនៅក្នុងក្រសួងឃោសនាការហ្នឹង ឈ្មោះ ហ៊ូ យន់ នេះធ្លាប់ឮៗ។ តែការស្គាល់ការឃើញរបស់គាត់ មុខគាត់យ៉ាងម៉េច រាងរៅគាត់យ៉ាងម៉េច ហើយគាត់មានតួនាទីអី ធ្វើអីអត់ដឹងទាំងអស់។ បានតែត្រឹមថា ឮឈ្មោះ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន។ ហើយថា ឈ្មោះនេះឮតាំងពីៗមិនទាន់មកនៅភ្នំពេញក៏ឮដែរ តែគ្រាន់តែថា វារហូតមកដល់នៅភ្នំពេញហើយក៏នៅតែមិនឃើញដែរឈ្មោះនេះ។ មុខអ្នក ហ៊ូ យន់ នេះអត់ អត់ដែលឃើញ ហើយអត់ដឹងថាការងារធ្វើអីផង។ សូមមានមតិប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកឮគេនិយាយអំពី ហ៊ូ យន់ តើគេមាននិយាយថា ហ៊ូ យន់ ជាជនក្បត់ដែរឬទេ?

[១៥:៣១:០៨]

**ឆ៖** ឈ្មោះ ហ៊ូ យន់ ឲ្យដឹងឮថា ជាជនក្បត់នេះ ខ្ញុំនិយាយមែនទែនខ្ញុំអត់បានដឹង ហើយក៏មិនដឹងថា ឲ្យមានការបញ្ជាក់អីមកដូចអង្គាល់ដែលខ្ញុំបញ្ជាក់ខាងដើមនៅលើសំណួរដើមពីលើរឿង ហ៊ូ នឹម នោះ គឺថា អត់មាន ខ្ញុំអត់ដឹងៗ។ តែឈ្មោះហ្នឹងបានតែឮ ហើយជាទោសកំហុសអី ក្បត់អីអីចេះអីចុះ ឮដូចឈ្មោះ ហ៊ូ នឹម នេះអត់។ នេះខ្ញុំដឹងបានតែឮតែឈ្មោះប៉ុណ្ណឹង ហើយការងារអីទាំងអស់ខ្ញុំអត់ដឹង។ ហើយការឃើញក៏អត់ដែលឃើញ។ សូមអស់មតិ។

**ស៖** តើលោកធ្លាប់ឮគេនិយាយថា បុគ្គលិកនៅក្រសួងឃោសនាការនោះ មានធ្វើអត្តឃាតដែរឬទេ?

**ឆ៖** សំណួរនេះ ខ្ញុំដូចជា ឆ្លើយមិនបាន។ វាដូចជាការភ្លេចភ្លាំង ការចងចាំរបស់ខ្ញុំហ្នឹងវាបាត់អស់ហើយ តែអង្គាល់នុំងដូចធ្លាប់មានឮខ្លះ ហើយដូចជាមិនប្រាដកប្រជា ដល់អីចឹងខ្ញុំឆ្លើយថា ពិត ឬមិនពិតក៏ឆ្លើយអត់កើត។ ស្ថិតក្នុងសភាពមួយថា ខ្ញុំជម្រាបជូនខាងលោកចៅក្រមអត់បាន ដោយសារថាដូចធ្លាប់ឮ ដូចអត់អីចេះ។ ខ្ញុំបញ្ជាក់ត្រង់អីចឹងថា ដូចធ្លាប់ឮ ដូចអត់។ ដល់អីចឹងថាឮ ក៏ថាអត់កើត ថាអត់ក៏ថា អត់កើត។ តែសំណួរនេះ ឮមកហាក់ដូចជា ដូចប្រហាក់ប្រហែល។ នេះ ដល់អីចឹងយកជាការអត់កើត ខ្ញុំសូមថា ខ្ញុំអត់ចងចាំកន្លែងនេះ។ សូមអស់មតិបាទ។

[១៥:៣៣:១៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៥:៣៣:៤៨]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន ហើយជម្រាបសួរលោក ខៀវ អេន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំជា -- ឈ្មោះ សុន អរុណ ជាមេធាវីការពារលោក នួន ជា។ ខ្ញុំថ្ងៃនេះមានសំណួរមិនជាច្រើនទេ សូមសួរលោកដូចតទៅនេះ៖ ត្រង់ឯកសារលេខ E3/438 សំណួរដែលចៅក្រមស៊ើបអង្កេតបានសួរទៅលោក ហើយលោកបានឆ្លើយមកចៅក្រមស៊ើបអង្កេតវិញ។ ចៅក្រមស៊ើបអង្កេតសួរថា “តើការធ្វើសន្និបាតធំៗ ដែលលោកមិនបានចូលរួមនោះ មានការចូលរួមពីមនុស្សសំខាន់ៗដូចជា ខៀវ សំផន, នួន ជា, អៀង សារី ដែរឬទេ?”

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ការដែលធ្វើសន្និបាតសំខាន់ៗ មែនទែនថ្នាក់ដឹកនាំផ្សេងៗខ្ញុំអត់បានដឹងទេ ហើយសូម្បីតែខ្លួនខ្ញុំ ក៏ខ្ញុំមិនដែលបានទៅចូលរួមសន្និបាតឯណា ជាធំដុំមានថ្នាក់ដឹកនាំធំៗដែរ អត់ទេ។ ហើយអ៊ីចឹង ការយល់ ការឃើញ ការដឹង ខ្ញុំអត់ដឹងទេ តែបើក្នុងក្រសួងខ្ញុំពេលសូម្បីតែសន្និបាត ដែលទ្រង់ទ្រាយធំពេលខ្លះ ខ្ញុំអត់បានចូលផង ខ្ញុំនៅតែការងារខ្ញុំ។ ហើយកាលហ្នឹងវា ខ្ញុំជាមហាជនទៀត ដល់អ៊ីចឹងការដែល ការងារអីរឿងសន្និបាតធំៗហ្នឹងគឺថា ខ្ញុំហ្នឹងគឺថា ត្រូវនៅមើលការងារជាចាំបាច់ ច្រើនជាងអ្នកដែលមានការពាក់ព័ន្ធជាមួយ ដូចបញ្ជាក់ខាងដើមថាជាបក្ខជន ជាយុវកកហ្នឹង ពួកហ្នឹងគេច្រើនទៅមានមុខអីចេញទៅធ្វើការ ឯខ្ញុំភាគច្រើន គឺមិនសូវបានចេញទៅណា

មកណាទេ នៅរឿងការងារហ្នឹងច្រើន ហើយប្រជុំអីរឿងផ្សេងៗខ្ញុំអត់សូវបានចូលរួមទេ។ សូមអស់មតិ។

[១៥:៣៦:១៦]

**ស៖** អរគុណ។ សំណួរបន្ត "កន្លងមកពេលដែលលោក ហ៊ូ នឹម នៅធ្វើការ ខ្ញុំមិនដឹងថាគាត់មានឋានៈត្រឹមណាទេក្នុងបក្ស ហើយការប្រជុំគឺដឹកនាំដោយ ហ៊ូ នឹម តែក្រោយពេលចាប់ ហ៊ូ នឹម ហើយ យុន យ៉ាត បានចូលមកជំនួសគាត់ និងក្រោយមកទៀត នួន ជា ក៏បានមកជំនួស យុន យ៉ាត"។ សួរថា លោកឆ្លើយថា នួន ជា បានមកជំនួស យុន យ៉ាត ពាក្យជំនួសនេះ មានន័យថា ជំនួសខាងក្រសួងពីព្រោះអី ហ៊ូ នឹម មុនដំបូងគាត់កាន់ក្រសួង គាត់ជាក្នុងឋានៈជារដ្ឋមន្ត្រីបើតាមឯកសារ ហើយ យុន យ៉ាត ក៏ជារដ្ឋមន្ត្រីដែរ។ ដល់ហើយ នួន ជា មកជំនួស យុន យ៉ាត ហ្នឹងក្នុងឋានៈជាស្ដីជារដ្ឋមន្ត្រីបើតាមលោកដឹង លោកធ្លាប់ធ្វើការក្រោម នៅក្នុងក្រសួងហ្នឹង លោកជារដ្ឋមន្ត្រីក្រសួងឃោសនាការអ៊ីចឹង ឬក៏ជំនួស ធ្វើអ្វីៗផ្សេង?

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ។ ខ្ញុំការដឹងពីការប្តូរផ្លាស់នេះ ខ្ញុំគ្រាន់តែឃើញថា ពេលដក ហ៊ូ នឹម ចេញទៅ យុន យ៉ាត គាត់មកទទួល ហើយ យុន យ៉ាត មកធ្វើការនៅហ្នឹងព្រឹកល្ងាចៗអ៊ីចឹង ហើយខ្ញុំៗគិតថា ហើយពេលប្រជុំអីហ្នឹងគេៗប្រជុំគេសន្និបាតអីៗហ្នឹង គេហៅពីហ្នឹងទៅៗចូលរួមជាមួយខាងសិក្សាអប់រំហ្នឹង ព្រោះខាងនេះខាង ហ៊ូ នឹម នោះថា ខាងព័ត៌មាន និងឃោសនាការបាទ។ ហើយដល់ក្រោយមកទៀត យុន យ៉ាត ក៏បាត់ទៅ ឈប់ឃើញសកម្មភាពមកធ្វើការមក ក៏ឃើញ លោក នួន ជា មកវិញ។ ដល់អ៊ីចឹងខ្ញុំក៏គិតថា ដំណាក់កាលប្ដូរផ្លាស់ហ្នឹង មិនដឹងតួនាទីគាត់ទទួលយ៉ាងម៉េចៗ តែគ្រាន់សកម្មភាពបុគ្គលដែលមកធ្វើការហ្នឹង ឃើញផុតពីមួយទៅមួយមក ហើយបាត់មួយទៅឃើញមួយមកទៀតអ៊ីចេះ។ ដល់អ៊ីចឹង ជារការចាត់តាំងរៀបរយអីខាងលើ ខ្ញុំអត់ដឹងទេ តែគ្រាន់តែមកឃើញសកម្មភាពអ៊ីចឹង ហើយដល់នេះខ្ញុំគ្រាន់តែចែកជាបីដំណាក់អ៊ីចឹង ពី ហ៊ូ នឹម មក យុន យ៉ាត ពី យុន យ៉ាត មក នួន ជា។ តែគ្រាន់អង្គាល់ យុន យ៉ាត ដឹងថា អ្នកទាំងពីរនេះ បញ្ចូលក្រសួងទាំងពីរនេះបញ្ចូលបានធ្វើការជាមួយគ្នា បានទៅប្រជុំអីជាមួយគ្នារវាងក្រសួងទាំងពីរហ្នឹង ដែល ហ៊ូ នឹម ដកហើយហ្នឹង យុន យ៉ាត មកទទួលអប់រំអីនៅហ្នឹង ណែនាំអី តែដល់ យុន យ៉ាត ឈប់ទៀត ឃើញលោក នួន ជា គាត់មកហើយដល់មក យុន យ៉ាត ហ្នឹងក៏លែងឃើញការងារហ្នឹងមកទៀត ផ្អាកមក។ នេះជាចម្លើយរបស់ខ្ញុំបញ្ជាក់ជូនបានប៉ុណ្ណឹង។

[១៥:៣៩:៥១]

**ស៖** អរគុណ។ ពេលដែល ហ៊ូ នឹម គាត់នៅ ហើយគេដក ហ៊ូ នឹម ទៅ យុន យ៉ាត គាត់មករបៀបធ្វើការហ្នឹង របៀបធ្វើការក្នុងឋានៈជាអ្នកគ្រប់គ្រងក្រសួងហ្នឹង ដូចគ្នាទេ? ឧទាហរណ៍ថា ថ្ងៃហ្នឹងធ្វើការ -- ដូចថារាល់ថ្ងៃហ្នឹងមកធ្វើការមកពេញថ្ងៃ ពេញម៉ោង ពេញអីអ៊ីចឹង រាល់ពេល រាល់វេលាអីទេ? ហើយដល់ នួន ជា មកនោះ ជំនួស យុន យ៉ាត នោះថាតើធ្វើការដូចគ្នាទេ? ពេញម៉ោង ពេញពេលវេលាទេ ឬក៏គ្រាន់តែមកមួយភ្លែតៗ មើលនាយអាយបន្តិចបន្តួចអ៊ីចឹង ហើយត្រឡប់ទៅវិញ ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមឆ្លើយ ខ្ញុំគិតពីពេលហ្នឹង ខ្ញុំនិយាយថា សកម្មភាពការងារ ដូចជាមិនខុសគ្នាទេ បាទ មិនខុសគ្នាទេ។ ព្រោះអាហ្នឹងដឹងខាងលើៗហ្នឹង គាត់រវល់អីយ៉ាងម៉េច អីយ៉ាងម៉េច តែគ្រាន់តែថា គាត់បានមកអើតមកហើយ ពេលខ្លះគាត់ទៅបាត់ទៅ។ ថ្ងៃស្អែកជួនអត់មក ជួនខានស្អែកអីឃើញមក មកអ៊ីចឹងទៅ គាត់ទៅបាត់ទៅ។ ហើយដល់អ៊ីចឹងការងារខ្ញុំ ខ្ញុំនៅតែការងារខ្ញុំ គាត់ជួបខាងណាៗ ខ្ញុំអត់ដឹងទេ។ តែគ្រាន់តែខ្ញុំបានបញ្ជាក់ពីខាងដើមមកថា វាប្រែប្រួលៗ តែរឿងការហូបចុកដែលខ្ញុំនៅកន្លងមកទេ ពី -- ខ្ញុំបានបញ្ជាក់ខាងដើមហើយ។ កាលឃើញសកម្មភាពប្រែប្រួលប៉ុណ្ណឹងទេ និងការដែលរស់នៅហ្នឹងការងារហ្នឹង ដូចមិនឃើញមានអីប្រែប្រួលច្រើនទេ សឹងថាប្រហាក់ប្រហែលស្រដៀងៗគ្នា ឃើញបាត់ៗ ដូចតែគ្នាបាទ។ សូមអស់មតិ។

[១៥:៤១:៤៨]

**ស៖** ក្រោយពេលដែលចាប់ ហ៊ូ នឹម ហើយអ្នកដែលចូលរួមបណ្តុះបណ្តាលជាមួយខ្ញុំ ក៏ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ។ សួរថា ពាក្យថា "ចាប់ លោក ហ៊ូ នឹម និងអ្នកចូលបណ្តុះបណ្តាលជាមួយលោកនោះ បានចាប់ខ្លួនជាបន្តបន្ទាប់ដែរ"។ ចុះពាក្យ "ចាប់ ថាចាប់នោះ" លោកចង់និយាយថា យ៉ាងម៉េច ចាប់? ធម្មតាពាក្យ "ចាប់" នេះបើតាមច្បាប់ ឬក៏តាមរបៀបខាងតុលាការក្តី ខាងក្រសួងសមត្ថកិច្ចក្តី "ចាប់" មានន័យថា "គេដាក់ខ្នោះ គេចង ឬក៏គេមានអាវុធមកនាំមនុស្សហ្នឹងទៅ" ដែលលោកដឹង ឬក៏លោកបានឃើញនឹងភ្នែក ថាចាប់ ហ៊ូ នឹម ហ្នឹងចាប់របៀបម៉េច?

**ឆ៖** ខ្ញុំសូមឆ្លើយ ការចាប់ ហ៊ូ នឹម ខ្ញុំមិនបានឃើញទេ តែគ្រាន់តែថា គេមកយកគាត់ទៅ ក៏ខ្ញុំមិនបានដឹង។ តែដល់បាត់ច្រើនថ្ងៃពេក ក៏ចេះតែសួរថា អ្ហែ! គាត់ទៅណា មកណា។ ហើយដល់ក្រោយមកគេថា គេចាប់។ រួចដល់អ៊ីចឹង ខ្ញុំពាក្យៗថា "ចាប់ៗ" នេះគឺថាវាប្រើតាំងពីមុនមកហ្នឹង ព្រោះកាលហ្នឹង ជំនាន់ហ្នឹង គេថាខ្លះថា ដកចេញទៅរៀនសូត្រហ្នឹង តែការពិតខ្លះគេចាប់យកទៅហ្នឹង តែគេដក

ចេញទៅ គេថា គេអត់ប្រាប់ថា ចាប់ទេ តែគេដកទៅស្រួល ហៅឲ្យទៅរៀន តែគេដកលែងឲ្យមកវិញបណ្តោយ។ ដល់អ៊ីចឹងអាពាក្យ និងនិយមន័យនៅក្នុងច្បាប់អីហ្នឹង អាហ្នឹងវាម្យ៉ាង។ តែពាក្យភាសារបស់ប្រជាជន ដែលទម្លាប់និយាយ ទម្លាប់ហៅនោះ វាឲ្យទៅតាមភាសាតំបន់មួយៗ គេអាខ្លះនិយាយអ៊ីចេះ អាខ្លះនិយាយអ៊ីចុះទៅ។ រួចដល់ន័យខ្ញុំនិយាយហ្នឹង ក៏ក្នុងន័យថា បើចាប់ដកនេះទៅហើយ បានគេថា លើកពីនេះទៅ ឯណោះហើយ។ វាជាការចាប់យកចេញហើយ។ វាដូរកន្លែងហើយ ដកពីនេះយកនៅឯណោះ។ ដល់អ៊ីចឹងចាប់លើកមនុស្សនេះ ទៅឯណោះ។ ដល់អ៊ីចឹង ចាប់នេះ គ្រាន់តែថាចងឬមិនចងអីមិនដឹង តែវាផ្ទេរ វារើកន្លែងចេញ វាដូរកន្លែងហើយ។ គេក្នុងន័យ ខ្ញុំបញ្ជាក់ជូនបានប៉ុណ្ណឹងទេ។ តែដល់ខាងអស់លោកឲ្យន័យ និយមន័យអីយ៉ាងម៉េចទៀត។ អាហ្នឹងខ្ញុំ ខ្ញុំគ្រាន់តែថា ន័យដែលចាប់វា អង្កាល់ហ្នឹងវាមានច្រើន។ ដូចខ្ញុំថា គេចាប់ហ្នឹង ពេលខ្លះគេហៅទៅរៀន គេអត់ថាចាប់ផង។ មិនដឹងអ្នកនោះមានកំហុសអីផង អាហ្នឹងខ្ញុំគ្រាន់តែលើកឧទាហរណ៍ទេ ដែលធ្លាប់ឮនោះ ថាទៅបាត់។ បាត់ដល់ពេលនេះ គេចាប់បាត់ហើយ អ៊ំូគេចាប់បាត់ហើយ។ តែអង្កាល់ទៅហ្នឹង មានមកចាប់ចងឯណាគេហៅទៅរៀន។ នេះខ្ញុំជូនជាការឆ្លងកាត់ដែលខ្ញុំដឹងបាទ។ តែក្នុងច្បាប់អីៗ អាហ្នឹងជារឿងមួយនៅក្នុងសាលក្រមអី គេត្រូវការពាក្យពេចន៍ហ្នឹងឲ្យវាច្បាស់លាស់ត្រឹមត្រូវ។ នេះខ្ញុំសូមជូនមតិបានប៉ុណ្ណឹង។

[១៥:៤៥:០១]

**សៈ** អរគុណលោកសាជាថ្មី។ សំណួរបន្ថែមទៅទៀត ខ្ញុំសួរថា គេ -- លោកសាក្សីបានឆ្លើយជម្រាបទៅខាងលោកចៅក្រមស៊ើបអង្កេតថា “គេបានបង្ហាញចម្លើយសារភាពរបស់ ហ៊ូ នឹម ដែលគេចោទថាគាត់ជាប់ពាក់ព័ន្ធនឹង សេ.អ៊ី.អា” ពេលនោះលោកសាក្សីផ្ទាល់បានឃើញចម្លើយសារភាពរបស់លោក ហ៊ូ នឹម ផ្ទាល់ទេ? ដែលលោកឆ្លើយជាមួយនឹងចៅក្រមស៊ើបអង្កេតថា បានឃើញចម្លើយសារភាពនុ៎ង តើបានឃើញ ដែលបានឃើញទេ កាលនៅធ្វើការក្តីដែលលោកមានជម្រាបទៅតុលាការថ្មីៗនេះថា ពេលឡើងទៅធ្វើសិក្ខាសាលាជាមួយនឹង យុន យ៉ាត ១បានឧទ្ទិសរឿងប្រវត្តិរបស់ ហ៊ូ នឹមអ៊ីចឹងទៅ តើលោកបានឃើញ បានឮ បានឃើញផ្ទាល់ ចម្លើយសារភាពរបស់លោក ហ៊ូ នឹម ហ្នឹងទេ?

**ឆៈ** ខ្ញុំសូមឆ្លើយនឹងសំណួរលោកដែលបានសួរមកថា សំណួរនេះខាងដើមក៏បានបញ្ជាក់តែខ្លាចថា ខ្ញុំឆ្លើយហើយនៅមិនទាន់ ថាច្បាស់លាស់ក្បោះក្បាយអីទៀត ខ្ញុំក៏បញ្ជាក់ថែម។ ចម្លើយនេះជាក្រដាសស្នាមខ្ញុំមិនបានទៅកាន់នឹងដៃខ្ញុំផ្ទាល់ ហើយមកឃើញទេ គ្រាន់ថាក្នុងជាអង្គប្រជុំអ៊ីចឹង ឧបមាថាខាងគណៈអធិបតីគាត់នៅអ៊ីចឹង គាត់លើកថា “នេះជាចម្លើយរបស់ ហ៊ូ នឹម អីចេះចុះហ្នឹង” អាហ្នឹង

បាន។ តែឲ្យទៅឃើញឯកសារខ្លឹមសារហ្នឹងយ៉ាងម៉េច ឲ្យផ្សព្វផ្សាយមកដែលឲ្យឃើញជាក់លាក់ហ្នឹង នៅហ្នឹងដៃខ្ញុំហ្នឹង អត់បានឃើញទេ។ បាទ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹងបាទ។

[១៥:៤៧:២៥]

**សៈ** ចៅក្រមបានសួរលោក លោកបានឆ្លើយៗថា ជំនាន់នោះខ្ញុំគ្រាន់តែដឹងថា រវាងភូមិភាគបូព៌ា និងនិរតីមានបញ្ហា តែខ្ញុំមិនដឹងថាខាងណាចាប់ខាងណានោះទេ។ តែជាទូទៅ អ្នកមកពីខាងបូព៌ា គេមិនសូវទុកចិត្ត -- មិនសូវទុកនៅទេ ហើយច្រើនរើសមនុស្សមកជំនួសការងារវិញ គឺមិនពីភូមិភាគនិរតី។ សូមលោកសាក្សីបញ្ជាក់ជូនតុលាការអំពីហេតុផលដូចពាក្យខាងលើនេះផងថា ហេតុអ្វីបានជាដូច្នេះ? បើលោកដឹងច្បាស់លាស់ ការផ្លាស់ប្តូរនេះ តើចេញបញ្ជាពីថ្នាក់ណាមក ឬភូមិភាគទាំងពីរនោះគេយល់ព្រមគ្នា ដើម្បីផ្លាស់ប្តូរគ្នា?

[១៥:៤៨:២៧]

**ផៈ** ខ្ញុំសូមឆ្លើយសំណួរនេះបន្ថែម និងចម្លើយដែលខ្ញុំបានបញ្ជាក់មកហើយ។ ការចាត់ចែងខាងលើខ្ញុំមិនបានដឹងទេបាទ តែគ្រាន់តែជាសកម្មភាពជាក់ស្តែងដែលខ្ញុំរស់នៅ ខ្ញុំរស់នៅដែលមានរួមមានវគ្គបណ្តុះបណ្តាលខាងបច្ចេកទេសដំបូងហ្នឹង ខ្ញុំឃើញសុទ្ធតែបូព៌ា។ ហ្នឹងខ្ញុំបានបញ្ជាក់ប្រាប់អ៊ីចឹងហើយ។ ហើយខ្ញុំជាបស្ចិមនេះ។ តែដល់ពេលដកទៅ មានបញ្ហាខាងលើអីយ៉ាងម៉េចៗ អីខ្ញុំអត់ដឹងទេ តែគ្រាន់តែដឹងថា ពេលដែល ហ៊ូ នឹម ដកទៅ ពួកអ្នកដែលមានវគ្គជាមួយខ្ញុំរៀនខាងបច្ចេកទេសហ្នឹង គេដកចេញទៅដែរ។ ហើយកម្លាំងចាស់មួយចំនួនដែលនៅដែលមុនខ្ញុំទៅទៀតហ្នឹង អ្នកហ្នឹងក៏ទៅបាត់ដែរទៅ។ ដល់អ៊ីចឹងខ្ញុំគ្រាន់តែបញ្ជាក់ថែមថា ក្រោយមក ពេល ហ៊ូ នឹម ចេញហើយ យុន យ៉ាត គាត់មកទទួល ហើយដល់មកទទួល មនុស្ស ដែលមកប្រគល់ឲ្យខ្ញុំសម្រាប់បង្រៀនខាងបច្ចេកទេសឲ្យដំណើរការនេះ មនុស្សមកពីនិរតីទាំងអស់។ ហើយដល់អ៊ីចឹងខ្ញុំក៏គិតថា ពេលដែលខាងលើចាត់ចែងយ៉ាងម៉េចមិនដឹងទេ តែគ្រាន់តែបូព៌ាទៅៗអស់រលីង ហើយស្រាប់តែឃើញសុទ្ធតែនិរតីមកវិញហើយម៉េច? នេះគ្រាន់តែគិតក្នុងចិត្តខ្លួនឯងទេ តែមិនប៊ានិយាយថា សភាពការណ៍អ៊ីចេះអ៊ីចុះអីយ៉ាងម៉េច អាហ្នឹងខ្ញុំអត់ដឹងទេរឿងខាងលើ ខ្ញុំគ្រាន់តែមានការទទួលកម្លាំងហ្នឹង យកមកបំពេញការងារដែលគេប្រគល់ឲ្យខ្ញុំ។ សូមអស់មតិបាទ។

**សៈ** អរគុណ។ លោកបានជម្រាបតាំងពីព្រឹកមិញរហូតមកថា "ការផ្លាស់ប្តូរបីជំនាន់ តាំងពី ហ៊ូ នឹម មក យុន យ៉ាត, យុន យ៉ាត មក នួន ជា។ នួន ជា បានទទួលកាន់ការនៅក្រសួងហ្នឹង ចុងឆ្នាំ

១៩៧៨ រហូតដល់វៀតណាមចូល"។ ខ្ញុំសួរថា មុនពេល នួន ជា បានឡើងជំនួស យុន យ៉ាត នោះ លោកដឹងថា នួន ជា មានមុខងារធ្វើអ្វីទេ?

[១៥:៥១:២១]

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ។ មុន នួន ជា ទៅចូលទទួលខុសត្រូវនៅក្នុងមន្ទីរហ្នឹង ក្រសួងហ្នឹង ក៏ខ្ញុំដឹងដែរ ដឹងថា នួន ជា ជាបុគ្គលបន្ទាប់ពី ប៉ុល ពត។ អ្នកដឹងហ្នឹង មិនមែនដឹងឃើញជាឯកសារអីទេ តែគេហៅថាមិត្តភក្តិដែលស្គាល់អ្នកធ្វើការដែលខ្លះគេជាបក្ខជន ខ្លះគេជាសម្ព័ន្ធអីៗហ្នឹងគេនិយាយអ៊ីចេះ។ ឯខ្ញុំបានទៅរៀនសូត្ររៀនអី ក្នុងវគ្គអ៊ីចឹងៗឲ្យដឹងឲ្យស្គាល់នោះ អត់ទេ។ ហើយដែលដឹងមួយទៀត គឺរឿងថាគាត់ហ្នឹងជាគណៈអចិន្ត្រៃយ៍។ ដល់គណៈចិន្ត្រៃយ៍ហ្នឹងក៏មិនបានទៅចូលរួមវគ្គរៀនសូត្រអីដែរ គ្រាន់ថាវិទ្យុប្រកាស អ៊ីចឹងទៅស្តាប់ទៅ អូ! គាត់ ឈ្មោះ នួន ជា ហ្នឹងជាគណៈអចិន្ត្រៃយ៍ នេះដឹងបានប៉ុណ្ណឹងបាទ។

**ស៖** អរគុណណាស់។ ក្រៅពីលោកដឹងថា នួន ជា ជាគណៈអចិន្ត្រៃយ៍ លោកមានដឹងថា គាត់មានមុខងារអ្វីផ្សេងពីហ្នឹងទៀតទេ?

**ឆ៖** តាមដែលខ្ញុំដឹង តែដូចជាវាមិនប្រាកដប្រជាបានទេ តែខ្ញុំគ្រាន់តែថា ការដែលដឹង ហើយមិនទាន់ភ្លេចនៅ ថាគាត់តំណាងឲ្យខាងសភា តែមិនដឹងជាកម្រិតណា អីកម្រិតណា គាត់គណៈអចិន្ត្រៃយ៍ហ្នឹង គឺថាក្នុងន័យថាសភា។ នេះដឹងបានតែប៉ុណ្ណឹងទេ មែនទែនឲ្យខ្លឹមសារអីច្រើនជាងអត់មានដឹងទេ។ តែអង្គាល់ហ្នឹងសភាដឹងគេរៀនចំយ៉ាងម៉េចៗ អត់ៗដឹងទេ អានេះវាការងាររបស់រដ្ឋាភិបាលជំនាន់ហ្នឹង ខ្ញុំអត់យល់ អត់ដឹងទេ។ សូមអស់មតិបាទ។

[១៥:៥៣:២១]

**ស៖** អរគុណណ៎ា។

**ឆ៖** បាទ។

**ស៖** លោកដឹងទេ លោកបានធ្វើការងារ បើនិយាយជាមន្ត្រីទៅ ដូចជាមន្ត្រីថ្នាក់គ្រាន់បើដែរ លោករៀនចេះដឹងមួយចំនួនដែរ អក្សរសាស្ត្រអីក្តី នៅក្នុងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង គេចែកជាយ៉ាងម៉េច លោកមានបានដឹងខ្លះទេ? ឧទាហរណ៍ថា មានបក្ស មានរដ្ឋបាល មានអីអ៊ីចឹង លោកមានដឹងខ្លះទេ រឿងអស់នេះ?

**ឆ៖** ខ្ញុំការងារនេះ ខ្ញុំមិនបានយល់អីជ្រៅជ្រះទេ ព្រោះកន្លងមក ដែលខ្ញុំគ្រាន់តែដឹងថាអង្គាល់

ជំនាញ់ហ្នឹង គេថាមានក្នុង មានក្រៅ ចង់និយាយថាខាងក្នុងនោះ គឺស្អី? ជួរបក្ស ជួរសម្ព័ន្ធ។ ហើយដល់ក្រៅ គឺថាអ្នកសម្ព័ន្ធ -- មហាជនសុទ្ធសាធហ្នឹង គឺថាយើងដឹងតែរឿងធ្វើការងារតាមគេរៀបចំ ក្នុងផ្ទៃក្នុងបក្សហ្នឹងគេរៀបចំយ៉ាងម៉េច យើងមហាជនហ្នឹង យើងធ្វើ។ នេះដឹងត្រឹមប៉ុណ្ណឹង វាអត់ដឹងថាយ៉ាងម៉េចឲ្យជ្រាលជ្រៅទៀត អត់ទេ។ ព្រោះពេលប្រជុំខ្លះ កាលហ្នឹង គ្រាន់ដឹងថាប្រជុំ ខ្លះគេប្រជុំផ្នែកខាងសម្ព័ន្ធ គេៗប្រជុំសុទ្ធតែអ្នកសម្ព័ន្ធ ឯយើងអត់មានអីផង យើងអត់បានទៅប្រជុំទេ។ គ្រាន់តែការងារកាលនុ៎ងវាអ៊ីចឹង ហើយផ្ទៃបក្ស ខាងបក្សគេប្រជុំទៅ យើងមហាជន យើងនៅដោយឡែកទៅ យើងគិតតែរឿងការងាររបស់យើងទៅ។ ហើយដល់អ៊ីចឹងរឿងខ្ញុំជ្រៅជ្រះអីទៅរឿងហ្នឹង ខ្ញុំអត់ដឹងៗ គ្រាន់ថាដឹងត្រឹមថាមានបក្សជន មានសម្ព័ន្ធ និងខ្ញុំជាមហាជនហ្នឹង ខ្ញុំដឹងតែការងារដែលគេប្រគល់ឲ្យខ្ញុំធ្វើ តាម -- តែគ្រាន់តែដឹងថា មហាជនហ្នឹងមិនមានតួនាទីអីធំដុំទេ អ្នកដែលៗបក្ខជន និងសម្ព័ន្ធនោះ បានគេចាត់តាំងថា អានេះត្រូវទទួលក្រុម ទទួលផ្នែកនេះផ្នែកនោះអី អាហ្នឹងបានមាន បើយើងច្រើនតែអនុវត្តហ្នឹង គឺថាជាមហាជនសុទ្ធសាធ។ នេះសូមមានមតិប៉ុណ្ណឹង។

**ឆ៖** សូមអរគុណ។ តាំងពីលោកឆ្លើយនូវសំណួរ តាំងពីចៅក្រមស៊ើបអង្កេតរហូតដល់ព្រះរាជអាជ្ញា រហូតដល់ខាងដើមបណ្ដឹងរដ្ឋប្បវេណីក្ដី លោកតែងតែនិយាយថាលោក នួន ជា ជំនួសលោក -- អ្នកស្រី យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងអប់រំហ្នឹង។ លោកប្រើពាក្យលោក នួន ជា ជារដ្ឋមន្ត្រីក្រសួងៗ ឃោសនាការ ព័ត៌មាន និងអប់រំ លោកដឹងពាក្យហ្នឹងពីណាមក ឬលោកឮគេហើយលោកថាតាមគេទេ?

[១៥:៥៦:៤៦]

**ឆ៖** សំណួរនេះខ្ញុំហាក់ដូចជាស្ដាប់មិនយល់ គាត់សួរ នួន ជា ជាពាក្យនេះ ព្រោះៗក្នុងន័យដែលខ្ញុំឆ្លើយមកគឺថា នួន ជា អ្នកមកជំនួសបន្តបន្ទាប់ ដែលក្រសួងកន្លងមក ហ៊ូ នឹម អ្នកទទួលខាងក្រសួងឃោសនា និងព័ត៌មាន យុន យ៉ាត ជាក្រសួងអប់រំ សិក្សាអប់រំ ហើយដល់ដក ហ៊ូ នឹម ទៅ យុន យ៉ាត នេះទទួលពីរនេះបញ្ចូលគ្នា។ ហើយដល់ យុន យ៉ាត ផ្អាកហើយបាន នួន ជា មកជំនួសក្នុងនាមថា យុន យ៉ាត អត់ឃើញមកធ្វើការ ខ្ញុំឃើញតែ នួន ជា ហ្នឹងគាត់មកជំនួសម្ដង។ តែជាការមកទទួលក្ដាប់ក្រសួងអីហ្នឹងយ៉ាងម៉េចទៀត ខ្ញុំ អ៊ីចឹងបានសំណួរនេះ ខ្ញុំស្ដាប់មិនទាន់យល់។

**ស៖** សូមទោស ខ្ញុំ -- ប្រហែលលោកស្ដាប់សំណួរ ខ្ញុំអាចច្រឡំ។ ខ្ញុំចង់សួរ ចំណុចខ្ញុំចង់សួរថាអ៊ីចេះថា រដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន មុនដំបូង ហ៊ូ នឹម បន្ទាប់មក យុន យ៉ាត គាត់មាន

បញ្ចូលក្រសួងឃោសនា និងព័ត៌មានហ្នឹង ជាមួយនឹងក្រសួងអប់រំ វាមានន័យថា ក្រសួងពីរចូលគ្នាតែមួយ។ ដល់ នួន ជា មកកាន់ គឺកាន់ក្រសួងទាំងពីរហ្នឹងដែរ អ៊ីចឹងទេ? បើខ្ញុំមិនខុសទេ។ កាន់ក្រសួងចូលគ្នាទាំងពីរហ្នឹងណា៎ ដូច យ៉ុន យ៉ាត អ៊ីចឹងណា៎។ ហើយបើៗអ៊ីចឹងទេ មានន័យថាលោក នួន ជា គាត់ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ឃោសនា ហើយនិងអប់រំ។ ពាក្យនេះជាពាក្យមួយដែលគេសរសេរជាផ្លូវការជាឯកសារជាក្រដាសស្នាម ធ្វើប្រើចុះឡើងជាផ្លូវការ ឬក៏លោកឮគេនិយាយតៗគ្នាទេ ដែល នួន ជា ថា នួន ជា រដ្ឋមន្ត្រី?

[១៥:៥៨:៥០]

**ឆ៖** ខ្ញុំសូមឆ្លើយ។ នួន ជា ដែលមកនេះ ហើយ យ៉ុន យ៉ាត ទៅវិញនេះ គឺ យ៉ុន យ៉ាត គាត់ទៅគ្រប់គ្រងក្រសួងគាត់ដដែល បាទគាត់នៅដដែលទេ។ តែ នួន ជា គាត់មក ក៏មិនមានឯកសារណាខ្ញុំបានឃើញថា នួន ជា ហ្នឹងមកជារដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មានអី អត់មានទេ។ តែគ្រាន់តែដឹងថាក្រសួងហ្នឹងជាអតីតក្រសួងឃោសនាការ និងព័ត៌មានចាស់។ ដល់អ៊ីចឹងពេលដែល យ៉ុន យ៉ាត ដកចេញទៅវិញហើយ ឃើញ នួន ជា មកក៏ៗ ក្នុងន័យដែលអ្នកឲ្យ តែគ្មានឯកសារណាបានឃើញ ឬមួយក៏ទទួលថាគាត់ជាៗ អ្នកទទួលខុសត្រូវខាងហ្នឹងឲ្យពេញឯកសារ ដែលខ្ញុំបានឃើញអីអត់ទេ។ គ្រាន់តែដឹងថាគាត់មកទទួល អ៎ ក្រសួងយើងចាស់មុនជាក្រសួងព័ត៌មាន និងឃោសនាការ ដល់អ៊ីចឹងគ្រាន់តែគិតថា គាត់មកតំណាងឲ្យក្រសួងហើយ។ អានេះគិតតាមបុគ្គលម្នាក់ៗរៀងខ្លួនទេ។ នេះសូមមានមតិប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ហើយលោកមេធាវីអស់សំណួរនៅ ឬក៏នៅសំណួរ?

**លោក សុន អរុណ៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសមល្មមសម្រាកហើយ ដោយសារអង្គជំនុំជម្រះមានបញ្ហាបន្តិចជម្រាបជូនភាគី។ ដូច្នេះរង់ចាំបន្តនៅថ្ងៃស្អែកចុះ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ហើយអរគុណសាក្សី ស្អែកជួបគ្នាសាថ្មីបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ដើម្បីបានព័ត៌មានច្បាស់លាស់ អង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីជម្រាបជូនព័ត៌មានមួយចំនួនទៅដល់ភាគី។ សូមអញ្ជើញលោកស្រីចៅក្រម!

[១៦:០០:៤៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធានបានសូមឱ្យខ្ញុំបង្ហាញដល់ភាគីថា ទាក់ទងទៅនឹងអ្វីដែលយើងចង់ស្តាប់ចម្លើយផ្ទាល់មាត់នៅលើបញ្ហាមួយចំនួន ដោយថា ខ្ញុំត្រូវធ្វើបែបនេះដោយសារថា ការប្រាស្រ័យទាក់ទងជាភាសាខ្មែរគឺ លោកប្រធានគាត់មិនមានឱកាសដើម្បីឆ្លើយតបទាន់ពេល។ ស្ថានភាពបច្ចុប្បន្នគឺថា លោក អៀង សារី មិនទាន់មានសុខភាពល្អទេ ហើយលោក គាត់នៅទទួលការព្យាបាលនៅមន្ទីរពេទ្យនៅឡើយ។ អង្គជំនុំជម្រះចាត់វិធានការដើម្បីទទួលបានមតិពីអ្នកជំនាញខាងវេជ្ជសាស្ត្រទាក់ទងទៅនឹងការធ្វើរោគវិនិច្ឆ័យគាត់ ហើយនិងធ្វើកោសល្យវិនិច្ឆ័យតបវិញដើម្បីទាក់ទងទៅនឹងសុខភាពរបស់គាត់។

[១៦:០១:៤៦]

អង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់ក្រុមមេធាវីការពាររបស់លោក អៀង សារី ដែលលោកបានឆ្លើយតបទៅនឹងការបោះបង់សិទ្ធិរឿងសាក្សីមួយចំនួនដែលត្រូវមកផ្តល់សក្ខីកម្ម។ ក៏ប៉ុន្តែមានបញ្ហាបន្ទាន់មួយចំនួនដែលៗបង្ហាញថា អាចនឹងមានបញ្ហារយៈពេលវែង ដែលយើងមិនអាចបន្តរយៈពេលទៅ ហើយដោយមានសាក្សីមួយចំនួន ប៉ុន្តែមិនមានសាក្សីផ្សេងទៀត ហើយវាមិនអាចនឹងសមស្របដោយមានប្រសិទ្ធភាពនឹងបន្តទៅបាន។ ហើយទាក់ទងទៅនឹងសាក្សី 428 នោះ មេធាវីបានចង្អុលបង្ហាញថា មានឆន្ទៈនឹងបោះបង់សិទ្ធិរបស់ជនរង -- ជនជាប់ចោទក្នុងការចូលរួម។ មេធាវីការពារក្តីបានចង្អុលបង្ហាញថា ខ្លួនចង់ដកសិទ្ធិនៃការ ដកមកវិញនូវការបោះបង់សិទ្ធិនោះ ហើយបានបង្ហាញពីរយៈពេលវែងនេះ ថាតើយើងនឹងបន្តនីតិវិធីដូចម្តេចពីចំណុចពេលនេះទៅនោះ។ ដោយជាក់ស្តែងគឺជាសេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះថាតើត្រូវស្តាប់សាក្សីណាមួយទៅតាមលំដាប់លំដោយនោះ។ រីឯយើងក៏វាយតម្លៃ ឱ្យតម្លៃទៅលើសំណើរបស់ភាគីដែរ ទាក់ទងទៅនឹងថា តើបញ្ហាណាដែលជាមូលដ្ឋានជាងគេបំផុតនោះទាក់ទងទៅនឹងថា តើត្រូវចាត់វិធានការដូចម្តេចដើម្បីបន្តការជំនុំជម្រះ។

[១៦:០៣:២៨]

ហើយយើងមិនដាក់ថា ជាការស្នើយោបល់ថា អង្គជំនុំជម្រះបានពិភាក្សារួចហើយនោះទេ។ ពីព្រោះថា យើងចង់ឲ្យមានការពិភាក្សាដោយចំហទៅលើបញ្ហានេះ។ ហើយខ្ញុំកត់សម្គាល់ផងដែរថា ថ្មីៗនេះក្រុមមេធាវីការពារក្ដីលោក អៀង សារី នឹងដាក់សំណើ ហើយក្រុមមេធាវីលោក ខៀវ សំផន ក៏គាំទ្រដែរ។ ដូច្នេះ ដោយជាក់ស្ដែងគឺថា ភាគីក៏បានគិតថាតើត្រូវបន្ដនីតិវិធីនៅអនាគតនោះដោយវិធីណា។ ដូច្នេះអង្គជំនុំជម្រះបានសម្រេចថា ស្ដាប់សំណើផ្ទាល់មាត់ ឬក៏សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ជាសាធារណៈទាក់ទងនឹងថា តើបញ្ហារបស់លោក អៀង សារី នឹងត្រូវយកមកដេញដោលពិភាក្សាគឺថាអាចនឹងទាក់ទងទៅនឹងបញ្ហានេះ នឹងត្រូវធ្វើឡើងក្រោយពីការស្ដាប់សាក្សីមួយចំនួន និងសវនាការលើកឯកសារ ដោយមានការយល់ស្របពីលោកប្រធាន ដែលថាយើងចង់បាននោះ គឺថា បន្ទាប់ពីកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយត្រូវបានអានដែលទាក់ទងទៅនឹងផ្នែកនៃសវនាការនេះ ឬក៏ទាក់ទងទៅនឹងរឿងក្ដី ០០២/០០១ នោះ។

[១៦:០៤:៥៣]

ឥឡូវនេះ កាលវិភាគឲ្យបានជាក់លាក់នោះ គឺថាអាចនឹងចាប់ផ្ដើមនៅពេលណានោះ មិនទាន់ច្បាស់ទេ គឺថាអាចនឹងយើងនឹងកំណត់បានទាក់ទងទៅនឹងស្ដាប់មតិភាគីទាំងអស់ មុននឹងសម្រេចទាក់ទងទៅនឹងការស្ដាប់សក្ខីកម្មរបស់សាក្សីបច្ចុប្បន្ននេះសិន។

លោកប្រធានខ្ញុំយល់ថា ខ្ញុំបាននិយាយពីបញ្ហាសំខាន់ៗមួយចំនួនហើយ តើទាំងអស់នេះអាចឆ្លើយតបទៅនឹងអ្វីដែលលោកប្រធានចង់ឲ្យខ្ញុំនិយាយដែរឬទេ?

**ប្រធានអង្គជំនុំ៖**

គ្រប់គ្រាន់ហើយ។

បាទ ឥឡូវនេះ ដល់កិច្ចដំណើរការសវនាការនៅថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាក កិច្ចដំណើរការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្ដធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០២ ខែតុលា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅស្អែកនេះ អង្គជំនុំជម្រះនឹងបន្ដស្ដាប់សក្ខីកម្មសាក្សី ខៀវ អេន ដែលនឹងបន្ដសួរដេញដោល ដោយក្រុមមេធាវីការពារក្ដីលោក នួន ជា ហើយនិងមេធាវីពីរក្រុមទៀត។ សូមភាគី និងសាធារណជនជ្រាប។

លោក ខៀវ អេន ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនចប់នៅឡើយទេ សវនាការត្រូវបន្ដធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោក មកបន្ដផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដោយ

ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផង ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំគាត់ទាំងពីរនាក់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*